ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ ១ មករា - មីនា ឆ្នាំ២០០៩ តម្លៃ ១.៥០០រ

## ការវិភាគស្ថានភាពយុវជននៅកម្ពុជា: បញ្ហាប្រឈម ការយល់ដឹង និងឱកាសសំរាប់យុវជន

ដោយ បណ្ឌិត Rebecca F. Catalla និងលោក គីម សុធន*

### សេចក្តីផ្តើម

កម្ពុជាជាប្រទេសមានប្រជាជនវ័យក្មេងជាងគេនៅអាស៊ីអាគ្នេយ៍ ដោយមានប្រជាជនក្នុងក្រុមអាយុ ១០-២៤ឆ្នាំ ដល់ទៅ ៣៦% នៃប្រជាជនសរុប ។ ខុសប្លែកពីប្រទេសឯទៀតនៅអាស៊ីអាគ្នេយ៍ កម្ពុជានៅមិនទាន់ទាញផលចំណេញបានពីលក្ខណៈប្រជាសាស្ត្រអំណោយផលដែលមានប្រជាជនអ្នកធ្វើការយ៉ាងច្រើន និងប្រជាជនក្នុងបន្ទុកជាមនុស្សចាស់ និងកូនក្មេងតែមួយចំនួនតូច ។ ទោះបីមានកំណើនសេដ្ឋកិច្ចខ្ពស់នាពេលថ្មីៗក្តី ក៏យុវជនត្រូវប្រឈមមុខនឹងកំណើនការប្រកួតប្រជែងដើម្បីទទួលបានការងារ និងឱកាសសេដ្ឋកិច្ចឯទៀត ដែលបានដាក់សំពាធជាប់រហូតទៅលើសេវានិងធនធានសាធារណៈ ក្នុងវិស័យអប់រំ និងថែទាំសុខភាព ។



សិស្សវ័យក្មេងម្នាក់មកពីសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ កំពុងធ្វើការងារជាជាងអគ្គិសនីនៅខេត្តព្រះសីហនុ ។

បញ្ហានានាដែលយុវជនកម្ពុជាកំពុងប្រឈមមុខសព្វថ្ងៃ ជាប់ទាក់ទងគ្នាខ្លាំងណាស់ ។ ឧទាហរណ៍ បញ្ហាខាងការងាររបស់យុវជន មានចំណងទាក់ទងមិនអាចកាត់ផ្តាច់បានជាមួយនឹងលទ្ធភាពទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញ ។ យុវជននៅក្នុងគ្រួសារធូរធារ ហាក់ដូចមានលទ្ធភាពទទួលបានការសិក្សា និងសេវាថែទាំសុខភាព ល្អជាងយុវជនជាកូនចៅគ្រួសារក្រីក្រ ។ លំនាំនេះហាក់ដូចមានជាបន្តពីមួយជំនាន់ទៅមួយជំនាន់ ដោយសារគ្មានការកសាងគោលនយោបាយអំណោយផលដល់អ្នកក្រ ដើម្បីលុបបំបាត់ការផ្ទេរភាពក្រីក្រពីមួយជំនាន់ទៅមួយជំនាន់បែបនេះ ។

គោលនយោបាយជាតិពហុវិស័យ និងគ្រប់ជ្រុងជ្រោយស្តីពីយុវជន គឺជាតំរូវការពិតប្រាកដណាស់ សំរាប់ជួយតំរែតំរង់ការធ្វើផែនការយុទ្ធសាស្ត្ររយៈពេលវែង ដែលត្រូវផ្តោតលើការវិនិយោគក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាសេវាថែទាំសុខភាព និងការបំផុសចំណាប់អារម្មណ៍ ។

ការវិភាគស្ថានភាពយុវជន មានគោលបំណងផ្តល់ព័ត៌មានដល់អ្នកកសាងគោលនយោបាយ និងដៃគូអភិវឌ្ឍន៍នានា ក្នុងការកសាងគោលនយោបាយជាតិស្តីពីយុវជន ព្រមទាំងគោលនយោបាយ និងកម្មវិធីតាមវិស័យផ្សេងៗ ដើម្បីជួយដល់យុវជនកម្ពុជា ។ ការវិភាគនេះ ខិតខំកំណត់ពីឧបសគ្គខាងធនធានមនុស្ស ហិរញ្ញវត្ថុ និងអង្គការចាត់តាំង ដែលរារាំងការ

* បណ្ឌិត Rebecca F. Catalla ជាទីប្រឹក្សាខាងស្រាវជ្រាវនៅ CDRI ហើយលោក គីម សុធន ជាអ្នកស្រាវជ្រាវនៅផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ របស់ CDRI ។ ភស្តុតាង និងការរៃរកញែកជាច្រើននៅក្នុងអត្ថបទនេះ គឺយកចេញពីការសិក្សា "ការវិភាគស្ថានភាពយុវជន" របស់ CDRI ដែលជាការសិក្សាស៊ីជម្រៅលើកដំបូងគេពាក់ព័ន្ធនឹងយុវជន ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណចំពោះ បណ្ឌិត Brett Ballard អតីតទីប្រឹក្សាផ្នែកស្រាវជ្រាវនៅ CDRI សំរាប់ការចូលរួមចំណែករបស់គាត់ក្នុងការស្រាវជ្រាវនេះ ។

## មាតិកា

ការវិភាគស្ថានភាពយុវជននៅកម្ពុជា ......................................១
ការកសាងសមត្ថភាពសហគមន៍អនុវត្តគំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រ ក្នុងតំបន់អាងទន្លេសាប ......................................៧
ភាពក្រីក្រ និងស្ថានភាពខុសគ្នានៃកុមារនៅកម្ពុជា ......................................១១
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ......................................១៦
– ស្ថានភាពក្នុងប្រទេស ......................................១៨
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ......................................២៤

អនុវត្តសិទ្ធិរបស់យុវជនឱ្យបានពេញលេញ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើក្រុមជនដែលងាយរងគ្រោះបំផុត និងត្រូវផាត់ចេញពីសង្គម ។ ការវិភាគនេះ ក៏មានកំណត់និយមន័យ និងញែកឱ្យដាច់រវាងក្រុមខុសៗគ្នា និងបញ្ហាប្រឈមផ្សេងៗដែលពួកគេជួបប្រទះ ។ ការវិភាគនេះ ផ្អែកលើទិន្នន័យបានពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៤ និងឯកសារមានស្រាប់មួយចំនួនទៀត ។ អ្នកស្រាវជ្រាវក៏បានពិភាក្សាតាមក្រុមស្នូលជាមួយយុវជន និងឪពុកម្តាយ ព្រមទាំងធ្វើសំភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះនៅក្នុងសំណាកមួយតូចមាន ៦ភូមិដែលបានជ្រើសរើស ដោយមានគោលដៅនៅក្រុងភ្នំពេញ និង ៥ខេត្ត ដើម្បីប្រមូលទិន្នន័យបែបគុណភាពសំរាប់ការវិភាគខាងស្ថិតិ និងការវិភាគនៅការិយាល័យ ។

## ស្ថានភាពយុវជនក្នុងបរិបទសេដ្ឋកិច្ច និងសង្គម

បញ្ហាប្រឈម និងឱកាសនានាដែលយុវជន និងយុវនារីនៅកម្ពុជាកំពុងជួបប្រទះ ត្រូវតែធ្វើការស្វែងយល់ យោងតាមកំណើនសេដ្ឋកិច្ចយ៉ាងលឿន ប៉ុន្តែមានការកាត់បន្ថយភាពក្រីក្រមិនច្រើន និងកំណើនវិសមភាព ។ កំណើនសេដ្ឋកិច្ច ក៏បានបង្កការផ្លាស់ប្តូរប្រជាសាស្ត្រគួរកត់សំគាល់នៅក្នុងសង្គមផងដែរ ដោយសារប្រជាជនក្មេងៗ មានចំនួនកាន់តែច្រើន និងមានចលនាបំលាស់ទីកាន់តែខ្លាំង ។ ការពិភាក្សានៅខាងក្រោម ផ្តល់នូវលទ្ធផលវិភាគតាមបទពិសោធន៍ជាក់ស្តែង លើបញ្ហាពាក់ព័ន្ធនឹងយុវជន ដោយយោងតាមនិន្នាការ អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចនៅកម្ពុជា ។

### *ការងារ*

បញ្ហាសំខាន់បំផុតមួយដែលយុវជន និងយុវនារីនៅកម្ពុជាកំពុងប្រឈមមុខគឺបញ្ហាការងារ ។ កម្លាំងពលកម្មនៅកម្ពុជា កំពុងកើនឡើង ប្រហែល ៣០០.០០០នាក់ក្នុងមួយឆ្នាំ និងអាចកើនរហូតដល់ ៤០០.០០០នាក់/ឆ្នាំនាអនាគតដ៏ខ្លី ។ ការងារថ្មីៗភាគច្រើនស្ថិតក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងការសាងសង់ ។ ប៉ុន្តែវិស័យទាំងនេះលូតលាស់មិនលឿនគ្រប់គ្រាន់ដើម្បីស្រូបយកចំណូលកម្លាំងពលកម្មថ្មីដ៏ច្រើនបែបនេះឡើយ ។ ហេតុនេះយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដូចមានបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ បានកំណត់ជំហាននានាដើម្បីអភិវឌ្ឍវិស័យកសិកម្មឱ្យក្លាយជាក្បាលម៉ាស៊ីនទី៣នៃកំណើន បន្ទាប់ពីវិស័យកាត់ដេរ និងទេសចរណ៍ ក្នុងគោលដៅបង្កើតឱកាសការងារទាំងក្នុងកសិដ្ឋាន និងក្រៅកសិដ្ឋាន ។ ប៉ុន្តែ ការងារក្នុងកសិដ្ឋាន ជួបឧបសគ្គដោយសារកម្មសិទ្ធិដីធ្លីមិនច្បាស់លាស់ កង្វះឥណទានថោកៗប្រើប្រាស់បាន ធាតុចូលនិងសេវាកម្មមានលក្ខណៈដាច់ដោយដុំ កង្វះហេដ្ឋារចនាសម្ព័ន្ធ និងដំណើរការទីផ្សារអន់ខ្សោយ ។ ការងារក្រៅកសិដ្ឋាន ហាក់ដូចមានសក្តានុពលច្រើន ប៉ុន្តែត្រូវប្រឹងប្រែងថែមទៀត ដើម្បីជំរុញការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម (SME) និងវិនិយោគលើវិស័យកសិ-ពាណិជ្ជកម្ម ។

ជាបន្ថែមលើវិនិយោគក្នុងវិស័យដ៏ជាក់លាក់នៃសេដ្ឋកិច្ច ដើម្បីស្រូបយកកម្លាំងពលកម្មដែលកើនឡើង ក៏ត្រូវផ្តោតការយកចិត្តទុកដាក់ត្រៀមរៀបចំយុវជន និងយុវនារី ឱ្យមានជំនាញដ៏ចាំបាច់សំរាប់ការងារមិនមែនបែបប្រពៃណី ដែលកាន់តែមានច្រើនឡើងក្នុងទីផ្សារពលកម្មនៅកម្ពុជា ។ ដោយសារសេដ្ឋកិច្ចកម្ពុជា បានផ្លាស់ប្តូរទៅតាមបរិបទនៃការប្រកួតប្រជែងក្នុងតំបន់ និងសាកលលោក ដូច្នេះ ពលករវ័យក្មេងត្រូវការ ការអប់រំត្រឹមត្រូវ ជំនាញ និងសមត្ថភាព ដើម្បីប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចសមាហរណកម្មក្នុងតំបន់ ។ នាបច្ចុប្បន្ន កម្មវិធី/វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ នៅមិនទាន់គ្រប់គ្រាន់ សំរាប់ដោះស្រាយកំណើនតំរូវការខាងសេវាកម្ម និងផលិតកម្មនៅឡើយទេ ។ ឧទាហរណ៍ នៅកម្ពុជា ដោយសារការធ្វើប្រពលវប្បកម្ម និងពិពិធកម្មផលិតកម្មក្នុងវិស័យកសិកម្ម ដូច្នេះត្រូវពឹងផ្អែកកាន់តែច្រើនទៅលើគ្រឿងយន្ត និងការដឹកជញ្ជូន ដែលទាមទារឱ្យមានជំនាញខាងគ្រឿងយន្តដើម្បីធ្វើការថែទាំ និងជួសជុល ។ ឱកាសទាំងនេះ គួរគួបផ្សំដោយឥណទានថោកៗអាចប្រើប្រាស់បាន សំរាប់គាំទ្រដល់ការបង្កើតសហគ្រាសខ្នាតតូច និងមធ្យម ។

ការវាយតំលៃរយៈពេលវែងគ្រប់ជ្រុងជ្រោយពីគន្លង និងវិស័យរួមផ្សំនៅក្នុងកំណើន និងការអភិវឌ្ឍន៍ប្រទេសកម្ពុជាដល់ឆ្នាំ២០២៥ និងតទៅមុខទៀត ដែលមានការបែងចែកតាមតំបន់ភូមិសាស្ត្រ និងការវាយតំលៃពីតំរូវការជំនាញការងារជាដើម នឹងជួយអោយអ្នករៀបចំផែនការ និងអ្នកកសាងគោលនយោបាយ (ដោយបានពិគ្រោះយោបល់ និងរួមសហការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនផង) អាចចាប់ផ្តើមធ្វើការពិភាក្សាពីប្រភេទវិនិយោគដែលវិស័យសាធារណៈ និងឯកជន ត្រូវធ្វើក្នុងការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ បញ្ហានេះ ទាមទារនូវគោលនយោបាយ និងផែនការ សំរាប់បន្សុំកម្មវិធីអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅនឹងតំរូវការក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា ដែលនឹងវិវត្តទៅមុខ ។

### *ការអប់រំ*

មានការយល់ស្របគ្នាជាទូទៅថា ការអប់រំជួយជំរុញកំណើនសេដ្ឋកិច្ចតាមរយៈកំណើនផលិតភាព ការទទួលបានជំនាញ និងអាកប្បកិរិយាថ្មីៗ ក៏ដូចជាការទទួលបានចំណេះដឹងបន្ថែម ។ ការអប់រំក៏មានតួនាទីកាន់តែរឹងមាំក្នុងការកាត់បន្ថយភាពក្រីក្រ និងវិសមភាពប្រាក់ចំណូល ។ ក្នុងនេះ អនក្ខរកម្មគឺជាសន្ទស្សន៍សំខាន់បំផុតមួយនៃភាពក្រីក្រ ហើយវិសមភាពនៃលទ្ធភាពទទួលបានការអប់រំ ក៏មានទំនាក់ទំនងជាមួយវិសមភាពប្រាក់ចំណូលដែរ (World Bank, 2006a) ។ ការស្រាវជ្រាវបានបង្ហាញទៀតថា វិនិយោគក្នុងការអប់រំកុមារី ផ្តល់ផលចំណេញ ខ្ពស់ជាងវិនិយោគក្នុងការអភិវឌ្ឍន៍ណាទៀតទាំងអស់ ។ ទោះបីទទួលបានការអប់រំផ្លូវការតែប៉ុន្មានឆ្នាំក្តី ក៏ស្ត្រីហាក់ដូច ធ្វើផែនការគ្រួសារបានកាន់តែច្រើន ថយកំណើតកូន ចេះស្វែងរកសេវាថែទាំសុខភាពមុនពេល និងក្រោយពេលសំរាលកូន ផ្តល់អាហារូបត្ថម្ភកាន់តែល្អឱ្យកូនៗ យកកូនទៅចាក់ថ្នាំបង្ការយ៉ាងត្រឹមត្រូវ និងផ្តល់ការថែទាំសុខភាពសមស្របឱ្យកូនៗ ។

ផែនការយុទ្ធសាស្ត្រសំរាប់ការអប់រំ (២០០៦-២០១០) បានបញ្ជាក់ពីកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលធានានូវការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំសំរាប់យុវជនគ្រប់រូប ។ គេឃើញថា មានការកើនឡើងនូវចំនួនសាលាបឋមសិក្សា និងអនុវិទ្យាល័យ អត្រាចុះឈ្មោះចូលរៀននៅកំរិតអនុវិទ្យាល័យ និងអត្រាអក្ខរកម្មមនុស្សពេញវ័យ (អាយុ ១៥-២៤ឆ្នាំ) ។ សន្ទស្សន៍ចំបងសំរាប់វាស់វែងការរីកចំរើន គឺចំណាយរបស់ជាតិលើការអប់រំបានកើនឡើងយ៉ាងទៀងទាត់ តាំងពីឆ្នាំ២០០០មក ។ មូលនិធិ ត្រូវបានបែងចែកជាសំខាន់សំរាប់ការអប់រំកំរិតបឋមសិក្សា និងអនុវិទ្យាល័យ សំរាប់សាលារៀននិងសំភារៈសិក្សា និងសំរាប់ការបណ្តុះបណ្តាលគ្រូៗ ។ ផែនការសកម្មភាពអាទិភាព ក៏បានជំរុញ

ឱ្យកុមារី និងយុវជនទន់ខ្សោយ ចូលរួមបានកាន់តែច្រើនក្នុងការអប់រំ ។

អនុបាតសាលាបឋមសិក្សាធៀបនឹងមធ្យមសិក្សា បានកើនដល់ ៧,៦ នៅឆ្នាំ២០០៥ ។ នៅឆ្នាំ២០០៤ មានតែ ១៤ស្រុកប៉ុណ្ណោះដែលគ្មានអនុវិទ្យាល័យ និង ៤៥ស្រុកដែលគ្មានវិទ្យាល័យ ។ សូចនាករគន្លឹះមួយដែលបង្ហាញពីលទ្ធភាពទទួលបានការអប់រំ គឺចំងាយទៅសាលារៀន ។ ចំងាយនេះប្រែប្រួលជាខ្លាំង ទៅតាមវិស័យ និងក្រុមបញ្ចភាគប្រាក់ចំណូល (income quintile) ។ ចំងាយជាមធ្យម សំរាប់គ្រួសារក្រីក្របំផុតគឺ ៧,៦៦គ.ម ប៉ុន្តែសំរាប់ក្រុមបញ្ចភាគធូរធារបំផុត (២០%ធូរធារបំផុត) គឺ ៣,០៩គ.ម ដែលបង្ហាញពីបន្ទុកចំណាយជាពេលវេលា និងការដឹកជញ្ជូនធំជាងសំរាប់គ្រួសារក្រីក្រ ។ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាលារៀនជាច្រើន ក៏បានប្រសើរឡើងដែរ ។ ឪពុកម្តាយសិស្សយល់ឃើញថា សាលារៀនមានបង្គន់ប្រសើរជាងមុន ហើយសំភារៈនៅតាមថ្នាក់រៀនក៏មានគុណភាពល្អជាងមុនដែរ ។ សហគមន៍ជាទូទៅក៏យល់ឃើញថា មានការប្រែប្រួលប្រសើរឡើងនូវលទ្ធភាពបានប្រើប្រាស់ ក្នុងនេះមានទាំងសាលារៀន ការចុះឈ្មោះចូលរៀនដោយឥតគិតថ្លៃ និងគោលនយោបាយអប់រំអំណោយផលដល់អ្នកក្រ ។

ទោះបីទទួលបានជោគជ័យយ៉ាងច្រើនដូច្នេះក្តី ក៏គុណភាព ប្រសិទ្ធភាព និងវិសាលភាពនៃការអប់រំ ប្រែប្រួលខុសគ្នាទៅតាមតំបន់ ។ លទ្ធភាពទទួលបានការអប់រំសំរាប់គ្រប់កំរិត នៅតែមានកំរិតទាប នៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល ដែលមានប្រជាជនក្រីក្រ និងក្រីក្របំផុតជាច្រើនកំពុងរស់នៅ ។ បន្ទុកចំណាយ រួមទាំងប្រាក់កំរៃក្រៅផ្លូវការផង នៅតែជាឧបសគ្គ ហើយក្រុមយុវជនងាយរងគ្រោះនានាច្រើនតែចូលរៀនយឺត រឺមានអាយុច្រើនជាងអាយុធម្មតាសំរាប់កំរិតសិក្សានីមួយៗ ។ យុវជន និងយុវនារីនៅក្នុង ២ក្រុមបញ្ចភាគទាបបំផុត ត្រូវប្រឈមមុខនឹងបញ្ហាច្រើនណាស់ទាក់ទិននឹងការអប់រំកំរិតមធ្យមសិក្សា ។ កំណើនការចុះឈ្មោះចូលរៀននៅមធ្យមសិក្សាអាចមើលឃើញយ៉ាងច្បាស់សំរាប់សិស្សទាំងពីរភេទ សំរាប់ទីតាំងភូមិសាស្ត្រ និងក្រុមសេដ្ឋកិច្ច-សង្គមកិច្ចខុសៗគ្នា ប៉ុន្តែគំលាតបានកើនឡើងរវាងទីក្រុង និងជនបទ និងរវាងក្រុមបញ្ចភាគក្រីក្របំផុត និងធូរធារបំផុត ។ អត្រាបន្តការសិក្សា គឺជាក្តីបារម្ភដ៏ធំមួយ ពីព្រោះវាជាកត្តាគន្លឹះសំរាប់រយៈពេលវែង ។ គ្រួសារក្រីក្រមានហានិភ័យខ្ពស់នៃការឈប់រៀន ដោយសារកត្តាសហគមន៍ និងកត្តាបុគ្គលផ្សេងៗ ។ ជាលទ្ធផល ការអប់រំសរុបដែលទទួលបាន នៅមានកំរិតទាប ហើយការសំរេចគោលដៅនៃការអប់រំមូលដ្ឋានជាសាកលនៅឆ្នាំ២០១៥ ត្រូវជួបការលំបាក ។ អត្រាអនក្ខរកម្មក្នុងក្រុមអាយុ១៥-២៤ឆ្នាំ នៅតែមានកំរិតខ្ពស់ ជាពិសេសសំរាប់កុមារី ។

បញ្ហាប្រឈមក៏នៅមានច្រើនទៀតដែរ ។ តើប្រព័ន្ធអប់រំអាចជួយអ្វីខ្លះដើម្បីបណ្តុះសីលធម៌ចាំបាច់ ដែលយុវជនត្រូវការ ដើម្បីកសាង និងចូលរួមចំណែកនៅក្នុងសង្គមប្រជាធិបតេយ្យសម័យទំនើប និងជួយធានាឱ្យមានអភិបាលកិច្ចល្អ? ម្យ៉ាងទៀត តើអ្នកធ្វើផែនការក្នុងជួររដ្ឋាភិបាល និងអ្នកពាក់ព័ន្ធចំបងៗ ត្រូវធ្វើការរួមគ្នាយ៉ាងណា ដើម្បីធានាឱ្យការអប់រំមានគុណភាព និងបរិមាណសមស្របល្អទៅនឹងទីផ្សារពលកម្ម? ក្នុងនេះ កម្មវិធីសិក្សាត្រូវត្រួតពិនិត្យនិងរៀបចំឡើងវិញ ដោយដាក់បញ្ចូលនូវមុខវិជ្ជាខាងវិទ្យាសាស្ត្រ និងគណិតសាស្ត្រច្រើនថែមទៀត ដើម្បីជួយបង្កើនជំនាញដោះស្រាយបញ្ហា ដែលអាចជួយពលករធ្វើការសំរេចចិត្ត និងធ្វើការងាររួមគ្នាជាក្រុម ព្រមទាំងវគ្គសិក្សាមានការអនុវត្តជាក់ស្តែងកាន់តែច្រើន ដើម្បីកសាង/ពង្រឹងជំនាញខាងកសិកម្ម និងជំនាញវិជ្ជាជីវៈ ។

វិធានការសំរាប់បង្កើនការចូលរួមរបស់គ្រួសារក្រីក្រ និងកុមារី រួមមាន ការផ្តោតធនធានជួយដល់សាលារៀន នៅតាមសហគមន៍ក្រីក្រនៅជនបទ ការផ្តោតឧបត្ថម្ភធនជួយឱ្យអ្នកក្រនិងកុមារីបានរៀនសូត្រ ការចូលរួមរបស់សហគមន៍នៅក្នុងសេចក្តីសំរេចចិត្តផ្សេងៗរបស់សាលារៀន ឧបត្ថម្ភធននិងការលើកទឹកចិត្តសំរាប់ការអប់រំកំរិតមធ្យមសិក្សានិងឧត្តមសិក្សា ការរៀបចំកម្មវិធីសិក្សាឱ្យស្របតាមតំរូវការនៅមូលដ្ឋាន យុទ្ធនាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីពីការរួមបញ្ចូលនូវកុមារី ជនពិការ និងយុវជនងាយរងគ្រោះ ។ សំរាប់យុវជនមិនចូលរៀនសាលា ការបណ្តុះបណ្តាលជំនាញ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ អាចមានប្រសិទ្ធភាពចំណាយខ្ពស់បំផុត តាមរយៈការកែលំអវិធីកំណត់គោលដៅ និងការរៀបចំឱ្យកម្មវិធីនានាមានសេវាកម្មផ្សេងៗជួយបំពេញបន្ថែម និងស្របតាមតំរូវការនៃទីផ្សារពលកម្មនៅមូលដ្ឋាន ។ កម្មវិធីទាំងនេះកាន់តែមានប្រសិទ្ធភាពល្អ បើសិនមានរួមបញ្ចូលទាំងការបណ្តុះបណ្តាលភ្ជាប់នឹងការងារ និងការជួយឧបត្ថម្ភនិយោជិត ក៏ដូចជាលទ្ធភាពទទួលបានឥណទានថោកៗអាចប្រើប្រាស់បាន ដើម្បីជួយដល់អាជីវករវ័យក្មេងក្នុងការបង្កើតសហគ្រាសខ្នាតតូច និងមធ្យម ។

កម្មវិធីសិក្សាមិនផ្លូវការដែលផ្តល់អក្ខរភាព និងជំនាញមូលដ្ឋានមួយចំនួនដល់មនុស្សពេញវ័យ និងយុវជនបោះបង់ការសិក្សា អាចជួយដោយផ្ទាល់ដល់ការបង្កើនប្រាក់ចំណូលគ្រួសារ និងជះឥទ្ធិពលវិជ្ជមានជាខ្លាំង ទៅលើស្ថានភាពសុខភាពគ្រួសារ ។ លទ្ធផលដែលសិក្សាកាមជាមនុស្សពេញវ័យបានរាយការណ៍ជាទូទៅ គឺអារម្មណ៍ទទួលបានសិទ្ធិអំណាច សមត្ថភាពធ្វើសកម្មភាពដោយមានទំនុកចិត្តលើខ្លួនឯងនៅក្នុងវេទិកាសាធារណៈផ្សេងៗ និងការដើរទាន់ការវិវត្តក្នុងសម័យថ្មី ។

### *ការថែទាំសុខភាព*

ការវិវត្តយ៉ាងច្រើនក្នុងសង្គមនិងវប្បធម៌ គួបផ្សំនឹងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅកម្ពុជា បានធ្វើឱ្យយុវជនជួបប្រទះនឹងស្ថានភាពមានហានិភ័យផ្សេងៗ ព្រមទាំងជួយពង្រឹងសមត្ថភាពពួកគេក្នុងការដោះស្រាយ ។ ចំណាកស្រុករបស់យុវជនដោយគ្មានក្រុមគ្រួសារទៅជាមួយដើម្បីស្វែងរកការងារ និងការអប់រំ បានបង្កើនហានិភ័យ មានបញ្ហាសុខភាពបន្តពូជ និងទង្វើប្រថុយគ្រោះថ្នាក់នាំឱ្យឆ្លងកាមរោគ (STD) ញៀនថ្នាំ រឺប្រព្រឹត្តអំពើហិង្សាខាងយេនឌ័រ ។ ប៉ុន្តែបញ្ហាកាមរោគ និងសុខភាពបន្តពូជ ការមានគភ៌ដោយគ្មានបំណង និងការរំលូតកូនរបស់យុវនារីក្នុងក្រុមអាយុពី ១៥ឆ្នាំ ទៅ ១៩ឆ្នាំជាដើម មិនមែន កើតមានឡើងដោយសារតែចំណាកស្រុក ឬក៏សុទ្ធតែជាបាតុភូតនៅទីក្រុងនោះទេ ។ លទ្ធភាពបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ កំពុងធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថ និងបង្កើតរបៀបរស់នៅបែបថ្មីនៅទូទាំងប្រទេស ។

ហានិភ័យផ្នែកសុខភាពដ៏ធ្ងន់ធ្ងរមួយចំនួន រួមមាន ការជក់បារី ការប្រើប្រាស់គ្រឿងញៀន (សុរា ថ្នាំញៀន) និងការឆ្លងមេរោគហ៊ីវ ឬជំងឺអេដស៍ ។ ទិន្នន័យនៅឆ្នាំ២០០៤ បង្ហាញថា ៧,៣%នៃយុវជនយុវនារីអាយុពី១៥-២៤ឆ្នាំ ជាអ្នកជក់បារី ។ ប៉ុន្តែរឿងនេះហាក់ដូចជាបញ្ហារបស់បុរស ពីព្រោះមានបុរស ១៣,៦% ជាអ្នកជក់បារី រីឯនារីវិញ មានតែ ០,៨% ប៉ុណ្ណោះ ។ យុវជនមិនចូលសាលារៀន មានអត្រាជក់បារីខ្ពស់ជាងយុវជនចូលសាលារៀន ដោយមានអត្រា ៩,២% ធៀបនឹង ០,៦% ។ ម្យ៉ាងទៀត ១៤,២% នៃយុវជនយុវនារីអាយុពី ១១-១៨ឆ្នាំ ធ្លាប់ហូបសុរា ហើយបើគិតតាមយេនឌ័រ

វិញ មានបុរស ២០,៩% ជាអ្នកហូបសុរា ធៀបនឹង ៧,៤% សំរាប់នារី ។ ស្រដៀងគ្នានឹងការជក់បារីដែរ យុវជនយុវនារីមិនចូលសាលារៀន មានភាគរយអ្នកហូបសុរា (១៥,៩%) ខ្ពស់ជាង យុវជនយុវនារីចូលសាលារៀន (១២,១%) ។សូចនាករគួរឱ្យបារម្ភមួយគឺ យុវជនយុវនារីជាច្រើននិយាយថាពួកគេបានហូបសុរាជាលើកដំបូង នៅអាយុ ១២ឆ្នាំ ហើយមូលហេតុនៃការហូបសុរាតាំងពីវ័យក្មេងបែបនេះ គឺដោយសារសំពាធពីមិត្តភក្តិ និងការធ្វើតាមរបៀបរស់នៅបែបថ្មីរបស់មនុស្សពេញវ័យ ។

ការផលិត ការលក់ និងការប្រើថ្នាំញៀន កំពុងក្លាយជាបញ្ហាស្មុគស្មាញ និងរីកដុះដាលពាសពេញផ្ទៃប្រទេស ។ ថ្វីបើមានភស្តុតាងខ្លះៗបង្ហាញថា ចំនួនអ្នកប្រើប្រាស់ថ្នាំញៀនខុសច្បាប់អាចថយចុះក្តី ប៉ុន្តែបញ្ហាប្រើប្រាស់ថ្នាំញៀនសព្វថ្ងៃ មិនមែនជាបាតុភូតដែលកើតមានតែនៅទីក្រុងនោះទេ ព្រោះវាបានរាលដាលទៅកាន់តំបន់ជនបទ និងតំបន់ដាច់ស្រយាលរួចទៅហើយ ។ អ្នកប្រើប្រាស់ថ្នាំញៀនភាគច្រើន ជាជនគ្មានការងារធ្វើ អ្នករកស៊ីផ្លូវភេទ កម្មករធ្វើការក្នុងឧស្សាហកម្មដែលប្រើពលកម្មច្រើន (ផ្នែកសំណង់ កាត់ដេរ បើកបររថយន្តតាក់ស៊ីឬរថយន្តដឹកទំនិញ) ព្រមទាំងកុមាររស់នៅតាមចិញ្ចើមថ្នល់ផងដែរ ។ ជាង ៨០% នៃអ្នកប្រើប្រាស់ថ្នាំញៀនដែលបានរកឃើញមានអាយុតិចជាង២៦ឆ្នាំ ។គួរកត់សំគាល់ថាគេពិបាករកឃើញពួកនេះណាស់ ដូច្នេះហើយក៏ពិបាកនឹងរាប់ឱ្យដឹងចំនួនជាក់លាក់ដែរ ។

កម្ពុជាសំរេចបានជោគជ័យយ៉ាងសំខាន់ក្នុងការបង្ការការឆ្លងមេរោគហ៊ីវ/ជំងឺអេដស៍ ។ ចំនួនអ្នកផ្ទុកមេរោគហ៊ីវក្នុងក្រុមអាយុ ១៥-៤៩ឆ្នាំ បានថយចុះពី ៣,០% នៅឆ្នាំ១៩៩៧ មកត្រឹម ១,០% នៅឆ្នាំ២០០៣ ។ មានក្រុមជាក់លាក់មួយចំនួនដែលទំនងជាមានអត្រាកើតជំងឺអេដស៍ច្រើន បើធៀបនឹងក្រុមដទៃ ។ អ្នកដែលមានហានិភ័យខ្ពស់ជាងគេក្នុងការឆ្លងជំងឺអេដស៍ គឺនារីរកស៊ីផ្លូវភេទ បុរសរួមភេទជាមួយបុរសដូចគ្នា និងអ្នកប្រើប្រាស់ថ្នាំញៀនដោយការចាក់ ហើយពួកនេះភាគច្រើនមានវ័យក្មេងៗ ។ តួលេខប៉ាន់ស្មាននៅឆ្នាំ២០០៦ បង្ហាញថា ក្នុងចំណោមនារីរកស៊ីផ្លូវភេទ ដែលទៅមណ្ឌលពិនិត្យសុខភាពមុនឆ្លងទន្លេ មាន ១២,៦% ផ្ទុកជំងឺអេដស៍ ធៀបនឹង ២១,៤% នៅឆ្នាំ២០០៣ ។ក្នុងចំណោមនារីផ្ទុកមេរោគអេដស៍នៅឆ្នាំ២០០៦ មាន ៧,២% មានអាយុតិចជាង ២៥ឆ្នាំ ។ មានសញ្ញាមួយចំនួនបង្ហាញថា អត្រាខ្ពស់នៃការឆ្លងជំងឺនេះ ប្រហែលកំពុងរីករាលដាលទៅកាន់ក្រុមប្រជាសាស្ត្រផ្សេងៗទៀត ។ ជាឧទាហរណ៍ ក្នុងចំណោមស្ត្រីមានគភ៌អាយុពី ១៥-២៤ឆ្នាំ មានអ្នកផ្ទុកជំងឺអេដស៍ចំនួន ០,៤១%នៅឆ្នាំ២០០៦ ធៀបនឹង ០,៣៦% នៅឆ្នាំ២០០៣ ។ នាបច្ចុប្បន្ន ៤៣%នៃករណីឆ្លងមេរោគអេដស៍ថ្មីទៀត ស្ថិតក្នុងចំណោមនារីរៀបការរួចដែលមានអាយុពី ១៥-២៤ឆ្នាំ ដែលភាគច្រើនឆ្លងជំងឺនេះពីប្តីរបស់ខ្លួន ។

ចំណេះដឹង និងចំណាប់អារម្មណ៍ពីជំងឺអេដស៍ មានកំរិតខ្ពស់នៅកម្ពុជា ។ យោងតាមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ប្រជាជនទូទៅប្រហែល ៩០% ធ្លាប់បានដឹងពីបញ្ហាជំងឺនេះ ហើយប្រហែលពី ៨៨% ទៅ ៩៨% នៃប្រជាជនអាយុពី ១៥-២៤ឆ្នាំ មានចំនេះដឹងពីជំងឺនេះ ។ អង្កេតពីសុខភាព និងប្រជាសាស្ត្រនៅកម្ពុជា ឆ្នាំ២០០៥ រកឃើញថា ៩៨,៣% នៃបុរស និង ៩៨,៧% នៃនារី ក្នុងអាយុពី ១៥-២៤ឆ្នាំ ធ្លាប់បានលឺពីជំងឺអេដស៍ ប៉ុន្តែទិន្នន័យរបស់ RHIYA នៅឆ្នាំ២០០៦ បង្ហាញថា អត្រានេះខ្ពស់ដល់ ១០០% ។ ប្រហែល ៧២,៤% នៃបុរស និងនារីវ័យក្មេង បានដឹងយ៉ាងហោចណាស់មួយវិធីដែរដើម្បីបង្ការការឆ្លងជំងឺអេដស៍ ។ ទូរទស្សន៍ជាប្រភពព័ត៌មាន មានប្រជាប្រិយភាពបំផុត ហើយប្រភពដទៃទៀតរួមមាន វិទ្យុ មិត្តភក្តិ និងសាលារៀន (២៧,៧%) ។ ប្រភពផ្សេងពីនេះរួមមាន សារព័ត៌មាន ទស្សនាវដ្តី ខិត្តប័ណ្ណ ប៉ូស្ទ័រ អ្នកធ្វើការផ្នែកសុខភាព ព្រះសង្ឃ ការប្រជុំក្នុងសហគមន៍ ឳពុកម្តាយ ដៃគូ អ្នកអប់រំ និងអ្នកជិតខាង ។ ប៉ុន្តែមានការស្រាវជ្រាវផ្សេងៗទៀតបង្ហាញថា ក្រុមជនជាតិភាគតិចនៅតំបន់ដាច់ស្រយាល ឬនៅតំបន់ភ្នំ បានដឹងពីជំងឺអេដស៍ តិចតួចជាងក្រុមដទៃទៀតដែលមានអាយុដូចគ្នា ។

មនុស្សសឹងតែគ្រប់គ្នាបានដឹងពីវិធីទំនើបបង្ការកុំឱ្យមានកូន (យ៉ាងតិចបំផុត ១វិធី) ហើយដោយឡែកសំរាប់មនុស្សក្នុងអាយុពី ១៥-៤៩ឆ្នាំ គឺមានប្រហែល ៩៩% ។ ប៉ុន្តែសំរាប់នារីក្នុងក្រុមអាយុ ១៥-១៩ឆ្នាំ និង ២០-២៤ឆ្នាំ មាន ២,៥% និង ២,៤% ប៉ុណ្ណោះដែលប្រើប្រាស់វិធីទំនើបនេះ ធៀបនឹង ១,៤% និង ១៣,៤% ដែលនៅតែប្រើប្រាស់វិធីបុរាណ ។ មានឳពុកម្តាយ និងមនុស្សចាស់ទៀតកាន់តែច្រើនដែលយល់ស្របឱ្យនារីវ័យក្មេងៗទៅចូលរួមក្នុងការពិភាក្សាពីបញ្ហាផ្លូវភេទ ហើយជំហរនេះបានធ្វើឱ្យការពិភាក្សាពីសុខភាពបន្តពូជ កាន់តែមានលក្ខណៈបើកចំហ និងអាចជួយជំរុញដល់ការថែទាំសុខភាពផ្លូវភេទនិងបន្តពូជ ផែនការគ្រួសារ និងការរំលូតកូនដោយសុវត្ថិភាព ។

ចំណេះដឹងផ្នែកសុខភាព និងសូចនាករជាច្រើន បង្ហាញពីការប្រែប្រួលប្រសើរឡើងយ៉ាងច្រើន ប៉ុន្តែនិន្នាការវិជ្ជមាននេះ ហាក់ដូចមិនកើតមានចំពោះក្រុមបន្ទាប់បន្សំ (marginalised groups) កុមារតាមចិញ្ចើមថ្នល់ ឬយុវជនទន់ខ្សោយនោះទេ ។ អ្នកដែលមានហានិភ័យខ្ពស់ជាងគេបំផុត គឺបុរសវ័យក្មេងនៅជនបទដែលបានបោះបង់ការសិក្សា ហើយអាចអត់ការងារធ្វើ ។ ចំណុចនេះបង្ហាញពីតំរូវការកំណត់គោលដៅឱ្យកាន់តែចំក្រុមបន្ទាប់បន្សំ និងប្រឈមគ្រោះថ្នាក់ ដោយយកចិត្តទុកដាក់ថែមទៀតទៅលើទីតាំងភូមិសាស្ត្រ ។ ស្ថាប័នរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលនានា ត្រូវតែបន្តការងារតស៊ូមតិ បង្កើនចំណាប់អារម្មណ៍ និងពង្រីកកម្មវិធីអប់រំសុខភាពដល់ក្រុមយុវជន ក្រុមគ្រួសារ និងសហគមន៍ ។ អាជ្ញាធរមូលដ្ឋាន អង្គការផ្អែកលើសហគមន៍ វត្តអារាម សាលារៀន និងអ្នកផ្គត់ផ្គង់សេវាសង្គម (អ្នកធ្វើការផ្នែកវេជ្ជសាស្ត្រ) សុទ្ធតែមានតួនាទីសំខាន់ត្រូវបំពេញ ។ ហើយចំណេះដឹង និងចំណាប់អារម្មណ៍ពីថ្នាំញៀនដែលច្បាប់ហាមឃាត់ គឺមានកំរិតខ្ពស់ណាស់ ។

### *ភាពងាយរងគ្រោះ*

និយមន័យធំទូលាយនៃពាក្យ ភាពងាយរងគ្រោះ អាចយកតាមសេចក្តីថ្លែងការណ៍គោលនយោបាយរបស់រដ្ឋាភិបាលស្តីពី តំហែទាំមួយបែបទៀតសំរាប់កុមារ (MoSVY 2006) ។ កុមារដែលមានភាពងាយរងគ្រោះ ត្រូវបានបែងចែកជា ក្រុមកុមារត្រូវការការគាំពារជាពិសេស និងក្រុមកុមារស្ថិតក្នុងហានិភ័យ ។ កុមារដែលត្រូវការការគាំពារជាពិសេស រួមមាន កុមារកំព្រា កុមារត្រូវគេបោះបង់ចោល កុមាររងឥទ្ធិពល រឺឆ្លងជំងឺអេដស៍ កុមារទទួលរងការរំលោភបំពាន (ខាងផ្លូវភេទ រាងកាយ និងផ្លូវចិត្ត) កុមារនៅតាមចិញ្ចើមថ្នល់ កុមារមិនដើរតាមគន្លងច្បាប់ កុមាររងគ្រោះដោយការធ្វើអាជីវកម្ម (អាជីវកម្មផ្លូវភេទ ឬទំរង់ផ្សេងៗនៃពលកម្មប្រកបដោយគ្រោះថ្នាក់) កុមារពិការ កុមារញៀនថ្នាំ និងកុមារដែលមិនទទួលបានតាមតំរូវការជាមូលដ្ឋាននៃរូបរាងកាយ ។

ភាពងាយរងគ្រោះ អាចផ្សារភ្ជាប់នឹងភាពក្រីក្រ ការផាត់ចេញពីសង្គម សុខភាពផ្លូវកាយ/ផ្លូវចិត្ត អំពើហិង្សា និងការរំលោភបំពាន ។ ភាពងាយរងគ្រោះ ក៏អាចផ្សារភ្ជាប់នឹងចំណាកស្រុកដែរ ព្រោះវាកាន់តែធ្វើឱ្យកុមារក្នុងគ្រួសារក្រីក្រ ត្រូវប្រឈមកាន់តែខ្លាំងនឹងភាពគ្មានផ្ទះសំបែង អំពើហិង្សា និងការរំលោភបំពាន ។

*ភាពក្រីក្រ និងការផាត់ចេញពីសង្គម*

យុវជន-យុវនារីដែលរស់នៅក្នុងគ្រួសារក្រីក្រ គឺជាក្រុមមួយងាយរងគ្រោះបំផុតនៅក្នុងសង្គមកម្ពុជា ។ ពួកគេមានចំនួនដល់ទៅ ២៦% នៃប្រជាជនសរុប ដោយមានប្រហែល ៣៥% កំពុងរស់នៅក្រោមខ្សែបន្ទាត់ក្រីក្រ ព្រោះពួកគេប្រកបរបរកសិកម្មដែលពឹងផ្អែកលើទឹកភ្លៀង ហើយត្រូវជួបអសន្តិសុខស្បៀងជារឿយៗ ។ ពួកគេច្រើនតែទទួលបានការអប់រំតិច និងមានលទ្ធភាពតិចតួចឬគ្មានសោះដើម្បីទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ពួកគេរស់នៅក្នុងគ្រួសារដែលជំពាក់បំណុលគេតតឈប់ឈរ និងមានមនុស្សក្នុងបន្ទុកច្រើន ។ គ្រួសារទាំងនេះ មានធនធានដីធ្លីកាន់តែតិចទៅៗ និងមានឱកាសការងារតិចតួច ។ការផាត់ចេញពីសង្គមដែលផុសចេញពីពិការភាព លក្ខណៈជនជាតិ និងភាពដាច់ស្រយាល កាន់តែធ្វើឱ្យភាពងាយរងគ្រោះ និងភាពក្រីក្រធ្ងន់ធ្ងរឡើង ។

*សុខភាពផ្លូវកាយ និងផ្លូវចិត្ត*

កុមាររស់តាមចិញ្ចើមថ្នល់ ជាក្រុមមួយងាយរងគ្រោះបំផុតនៅកម្ពុជា ។ ពួកគេងាយរងគ្រោះដោយបញ្ហាជាច្រើនខាងផ្លូវកាយនិងផ្លូវចិត្ត ខ្វះលទ្ធភាពដោះស្រាយតំរូវការជាមូលដ្ឋាន និងត្រូវប្រឈមនឹងគ្រោះថ្នាក់ជាច្រើនទៀត ដូចជា ការធ្វើអាជីវកម្មផ្លូវភេទ អំពើហិង្សា និងការប្រើប្រាស់ថ្នាំញៀន ជាដើម ។ ចំនួនកុមាររស់នៅតាមចិញ្ចើមថ្នល់ អាចកើនរហូតដល់ ២០% ជារៀងរាល់ឆ្នាំ ដោយសារចំណាកស្រុកពីជនបទមកទីក្រុង ។ មនុស្សវ័យក្មេងប្រមាណ ១០.០០០ ទៅ ២០.០០០នាក់ កំពុងធ្វើការនៅតាមចិញ្ចើមថ្នល់ ក្នុងនេះមានពាក់កណ្តាលជានារី ។

ការបាត់បង់ឪពុកម្តាយ មានផលប៉ះពាល់ទៅលើប្រាក់ចំណូលគ្រួសារ និងការអប់រំ ។ យោងទៅតាមទិន្នន័យនៃអង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០០៥ កុមារអាយុក្រោម ១៨ឆ្នាំ ប្រមាណ ៩% ជាកុមារកំព្រាឪពុក ឬម្តាយ ឬទាំងឪពុកម្តាយ ។ ចំនួនកុមារកំព្រាដោយសារជំងឺអេដស៍ បានកើនឡើងគួរឱ្យតក់ស្លុតដល់ប្រមាណ ៥៥.០០០នាក់ ឬ ១០,៩% នៃចំនួនកុមារកំព្រាទាំងអស់នៅឆ្នាំ២០០១ ។ គេប៉ាន់ស្មានថា នៅត្រឹមឆ្នាំ២០០៥ កុមារកំព្រានៅកម្ពុជា ២០,៧% ប្រហែលបានបាត់បង់ឪពុកម្តាយដោយសារបញ្ហាជំងឺអេដស៍ ។

*អំពើហិង្សា និងការរំលោភបំពាន*

មនុស្សវ័យក្មេង អាចធ្លាប់ជួបប្រទះអំពើហិង្សា និងការរំលោភបំពាន ច្រើនជាងក្រុមមនុស្សឯទៀតនៅកម្ពុជា ។ ភាពក្រីក្រ ជំងឺផ្លូវចិត្ត ការញៀនស្រា និងល្បែងស៊ីសង សុទ្ធតែពាក់ព័ន្ធដល់អំពើហិង្សាក្នុងគ្រួសារ ដែលជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅលើមនុស្សវ័យក្មេង ។ មនុស្សវ័យក្មេងដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ ត្រូវរស់នៅក្នុងភាពភ័យខ្លាច ។ ពួកគេច្រើនតែក្រៀមក្រំចិត្ត ងាយប្រព្រឹត្តអំពើមិនគប្បី មានអារម្មណ៍បែកខ្ញែកនៅពេលសិក្សា និងត្រូវបោះបង់ការសិក្សា ឬរត់ចេញពីផ្ទះទៀតក៏មាន ។ អំពើហិង្សាក្នុងគ្រួសារ ជាកត្តារួមផ្សំមួយដែលធ្វើឱ្យគ្រួសារចុះក្រ ដោយសារការខូចខាតទ្រព្យសម្បត្តិ និងបន្ទុកចំណាយទាក់ទងនឹងការព្យាបាលរបួស និងការបាត់បង់ផលិតភាព ។

ឧក្រិដ្ឋកម្ម និងការរំលោភសេពសន្ថវៈ គឺជាទិដ្ឋភាពមួយទៀតនៃភាពងាយរងគ្រោះ ។ បច្ចេកវិទ្យាមានចំណែកមួយក្នុងរឿងនេះ ដូចជា វត្តមានភាពយន្តអាសអាភាស និងប្រព័ន្ធអ៊ិនធឺណិត ដែលហាក់ដូចបានរួមចំណែកខ្លះដែរក្នុងករណីបទល្មើសផ្លូវភេទមួយចំនួន ។

*ចំណាកស្រុក*

បុរសស្ត្រីវ័យក្មេងដែលចាកចេញពីសហគមន៍ជនបទ ទៅរកការងារនៅទីក្រុង ត្រូវជួបបញ្ហាជាច្រើន ដូចជាការញៀនស្រា និងការប្រើប្រាស់ថ្នាំញៀន អំពើហិង្សារបស់ពួកជនអន្ធពាល បទឧក្រិដ្ឋ និងការរំលោភសេពសន្ថវៈជាដើម ។ បុរសស្ត្រីវ័យក្មេងមួយចំនួន ប្រកាន់យកឥរិយាបថ ដែលធ្វើឱ្យពួកគេប្រឈមមុខនឹងជំងឺអេដស៍ និងកាមរោគ ។ មនុស្សវ័យក្មេងដែលធ្វើចំណាកស្រុកឆ្លងដែន រឹតតែងាយរងគ្រោះនឹងអំពើឆបោក ការចាប់ខ្លួន ការធ្វើការងារមានគ្រោះថ្នាក់ដល់សុខភាព និងគ្មានការថែទាំ (ដូចជាការងារបាញ់ថ្នាំសំលាប់សត្វល្អិតនៅប្រទេសថៃ) ។ អ្នកខ្លះត្រូវជួបប្រទះនឹងការប្រើប្រាស់ថ្នាំញៀន ដែលអាចជួយឱ្យពួកគេធ្វើការបានច្រើនម៉ោង ។ នារីមួយចំនួនត្រូវគេធ្វើអាជីវកម្មខាងផ្លូវភេទ និងចាប់បង្ខំឱ្យធ្វើពេស្យាចារ ។

## ការចូលរួម និងសិទ្ធិ

កាលណាបុរសស្ត្រីវ័យក្មេងមានភាពងាយរងគ្រោះខ្ពស់ ឱកាសចូលរួមអនុវត្តសិទ្ធិ/កាតព្វកិច្ចជាពលរដ្ឋរបស់ពួកគេ មានកំរិតទាប ។ ការអប់រំជាកត្តាគន្លឹះសំរាប់ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច/សង្គម និងកិច្ចការជាពលរដ្ឋនាថ្ងៃខាងមុខ ។ ប៉ុន្តែសំរាប់យុវជនក្រីក្រ ក្រីក្រខ្លាំង និងងាយរងគ្រោះ ការអប់រំ គឺជាការដោះដូរជាមួយនឹងសកម្មភាពសេដ្ឋកិច្ចគ្រួសារ ។ ក្នុងករណីជាច្រើន ភាពក្រីក្រជារបាំងធំបំផុតដែលរារាំងការចូលរួមរបស់យុវជន ។

នៅជនបទកម្ពុជា សំលេងរបស់យុវជនមិនទាន់បានបញ្ចូលច្រើនទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋានទេ ។ ជារឿយៗ យុវជនមានអារម្មណ៍ត្រូវគេមើលរំលងនៅក្នុងដំណាក់កាលដំបូងនៃការធ្វើផែនការ ប៉ុន្តែត្រូវគេរំពឹងថានឹងចូលរួមជាកំលាំងពលកម្មក្នុងគំរោងអភិវឌ្ឍន៍ ។ ជាទូទៅ យុវជនកម្រមានគេហៅទៅចូលរួមក្នុងការប្រជុំភូមិណាស់ ព្រោះចាស់ៗយល់ថា យុវជនមានបទពិសោធន៍តិចក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ ម៉្យាងទៀត យុវជនជាច្រើនបានបង្ហាញថា ពួកគេមិនចាប់អារម្មណ៍ក្នុងការចូលរួមប្រជុំទេ ពីព្រោះវាជាតួនាទីរបស់អ្នកដឹកនាំភូមិ និងចាស់ៗក្នុងភូមិដែលត្រូវធ្វើការសំរេចចិត្ត ។ ក្នុងករណីទាំងពីរខាងលើ យុវជនភាគច្រើនមិនសូវមានអារម្មណ៍ ធ្វើជាម្ចាស់ក្នុងដំណើរការធ្វើផែនការអភិវឌ្ឍន៍ឡើយ ។

ការសំរេចចិត្តលើការអភិវឌ្ឍន៍សហគមន៍នៅកំរិតមូលដ្ឋានភាគច្រើន ពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធ ដូចជា សាលារៀន ផ្លូវថ្នល់ ប្រឡាយទឹក និងធារាសាស្ត្រ រីឯទិដ្ឋភាពសង្គមសំរាប់ការអភិវឌ្ឍន៍យុវជនវិញ មានការយកចិត្តទុកដាក់តិចតួច ។ ដូច្នេះត្រូវបំផុសការចូលរួមរបស់យុវជនក្នុងការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន ហើយនេះគួរជាចំណុចគន្លឹះមួយនៃគោលនយោបាយជាតិសំរាប់យុវជន ។

ការស្ម័គ្រចិត្តរបស់យុវជន គឺជាសមាសភាគដ៏ចំបងមួយក្នុងការបង្កើតមូលធនសង្គម និងពង្រឹងការជួយគ្នាទៅវិញទៅមក ។ ប៉ុន្តែយុវជនជាច្រើនតែងប្រៀបធៀបការងារស្ម័គ្រចិត្ត ទៅនឹងការងារគ្មានប្រាក់ឈ្នួល ។ នៅមានសញ្ញាមួយចំនួនបង្ហាញថា ការងារស្ម័គ្រចិត្តអាចដំណើរការទៅបាន នៅពេលមានការគាំទ្រសមស្របពីអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសហគមន៍ ។ កាលណាឱកាសធ្វើការស្ម័គ្រចិត្ត មានគួបផ្សំដោយការអភិវឌ្ឍន៍វិជ្ជាជីវៈ ឬជំនាញ ពេលនោះយុវជនមានសេចក្ដីសង្ឃឹមច្រើនអាចរកបានការងារល្អ ក៏ដូចជា អាចចូលរួមកាន់តែច្រើនក្នុងការងារជាពលរដ្ឋ ។

សេវាកម្មសហគមន៍សំរាប់យុវជន ក៏នៅតែខ្វះខាតជាទូទៅដែរ ។ ជារឿយៗ ឪពុកម្ដាយ និងអ្នកដឹកនាំភូមិ ចាត់ទុកការលេងកីឡាជាក្រុម និងសកម្មភាពស្រដៀងគ្នាទៀតថាជាការខ្ជះខ្ជាយពេលវេលា និងការប្រើប្រាស់ធនធានដ៏កំរមិនត្រឹមត្រូវ ។ ពួកចាស់ទុំ និងថ្នាក់ដឹកនាំភូមិ ត្រូវស្វែងយល់ និងឱ្យតំលៃដល់ការចូលរួមរបស់យុវជននៅក្នុងកិច្ចការសង្គម និងកិច្ចការជាពលរដ្ឋ ។

## ការធ្វើផែនទី

ការធ្វើផែនទីថ្នាក់ជាតិស្ដីពីអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដែលធ្វើការក្នុងវិស័យសុខាភិបាល និងអប់រំ បានបង្ហាញថា ការគ្របដណ្ដប់ជាលក្ខណៈភូមិសាស្ត្រនៅមានចន្លោះប្រហោងច្រើន ។ បណ្ដាខេត្តនៅតាមព្រំដែន ដូចជា ខេត្តស្ទឹងត្រែង ឧត្តរមានជ័យ មណ្ឌលគីរី រតនគីរី ព្រះសីហនុ ស្វាយរៀង ព្រះវិហារ និងពោធិ៍សាត់ ទទួលបានគំរោងជំនួយ តិចជាងបណ្ដាខេត្តនៅតំបន់វាលទំនាបកណ្ដាល និងតំបន់តាមដងទន្លេមេគង្គ និងតំបន់ទន្លេសាប ។ ទោះបីថ្មីៗនេះមានការពង្រីកប្រព័ន្ធដឹកជញ្ជូន និងទូរគមនាគមន៍ក្ដី ក៏សេវាអប់រំ និងសុខាភិបាលនៅតាមតំបន់ដាច់ស្រយាល នៅតែមានការអភិវឌ្ឍន៍យឺតដដែល ។

មូលហេតុមួយនៃស្ថានភាពបែបនេះ គឺបណ្ដាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ មាននិន្នាការផ្ដោតការខំប្រឹងប្រែងទៅលើតំបន់ដែលងាយចូលទៅដល់ ពីព្រោះបើគិតតាមចំណាយក្នុងមួយឯកតា ការផ្ដល់សេវានៅតំបន់មានដង់ស៊ីតេមនុស្សច្រើន វាមានប្រសិទ្ធភាពខ្ពស់ជាងនៅតំបន់ដាច់ស្រយាល ។ រឿងនេះប្រហែលជាមូលហេតុ ដែលរដ្ឋាភិបាលមិនដាក់មណ្ឌលសុខភាព និងសាលារៀន នៅតាមតំបន់ដាច់ស្រយាលដែលមានប្រជាជនតិចតួច និងរស់នៅរាយប៉ាយ ។ ប៉ុន្តែបើសិនគេមានគោលដៅកាត់បន្ថយភាពក្រីក្ររបស់យុវជន ដូច្នេះត្រូវមានអន្តរាគមន៍យ៉ាងច្រើននៅតាមតំបន់ដាច់ស្រយាលទាំងនោះ ដែលមានប្រជាជនវ័យក្មេងត្រូវប្រឈមមុខជារឿយៗ នឹងភាពងាយរងគ្រោះ ជាពិសេសទាក់ទិននឹងបញ្ហាការងារ ការអប់រំ និងសុខភាព ។

វាអាចមានការដើរមិនទាន់គ្នាមួយរវាង ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងអន្តរាគមន៍ផ្ដល់ជំនួយ ។ ឧទាហរណ៍ នៅពេលច្រកចេញចូលទៅកាន់តំបន់ណាមួយបានអភិវឌ្ឍរួចហើយ គេត្រូវការពេលវេលាមួយចំនួនទៀត ដើម្បីធ្វើផែនការសំរាប់អន្តរាគមន៍ដ៏ជាក់លាក់ និងការគៀងគរប្រមូលធនធាន ។ រឿងនេះបង្ហាញពីតំរូវការអន្តរាគមន៍ដែលមើលឃើញឆ្ងាយ និងគិតគូរជាមុនពីការកែលំអច្រកចេញចូល ។ ការងារនេះត្រូវមានព័ត៌មាន និងការសំរបសំរួលល្អប្រសើរនៃផ្នែករដ្ឋបាល ។ រដ្ឋាភិបាលអាចត្រូវបំពេញតួនាទីកាន់តែសកម្មក្នុងការលើកទឹកចិត្តដល់បណ្ដាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ឱ្យធ្វើអន្តរាគមន៍នៅតាមតំបន់ដែលទទួលបានជំនួយតិច ។

អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងភ្នាក់ងាររដ្ឋាភិបាល សុទ្ធតែមានឧត្ដមភាពរៀងៗខ្លួន ។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាល តែងមានឧត្ដមភាពជាលក្ខណៈទន់ភ្លន់ ងាយបត់បែន ផ្ដោតឱ្យចំក្រុមគោលដៅដែលពិបាកឈោងដល់ ចំណែកឯអង្គការអន្តរជាតិមានឧត្ដមភាពលើផ្នែកធនធាន និងសមត្ថភាពបច្ចេកទេស ។ ខាងរដ្ឋាភិបាល ជារឿយៗមានឧត្ដមភាពលើផ្នែកព័ត៌មាន ការគ្របដណ្ដប់ លទ្ធភាពទទួលបានព័ត៌មាន និងអាណត្តិតាមផ្លូវច្បាប់ ដើម្បីធ្វើសកម្មភាព ។ តួអង្គនីមួយៗត្រូវសំរបសំរួល និងពិគ្រោះយោបល់គ្នា ដើម្បីផ្ដល់ឱ្យយុវជននូវធាតុចូល និងសេវាកម្មផ្សេងៗ ដែលបំពេញឱ្យគ្នាបានល្អ ។

សកម្មភាពដូចខាងលើមានសារៈសំខាន់ ជាពិសេសសំរាប់ការកាត់បន្ថយភាពក្រីក្រ ពីព្រោះតំបន់ទាំងនេះច្រើនតែមានភាពក្រីក្រខ្ពស់ជាងតំបន់ឯទៀតដែលបានទទួលអន្តរាគមន៍ច្រើន ។ ម៉្យាងទៀត ចំណាយលើឧបត្ថម្ភធនសំរាប់សេវាថែទាំសុខភាព ហាក់ដូចមានផលប៉ះពាល់ច្រើនដល់ការកាត់បន្ថយភាពក្រីក្រ ។ ការគាំទ្រលើផ្នែកអប់រំ ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ ច្រើនតែផ្ដោតលើការអប់រំកំរិតបឋមសិក្សា ជាជាងកំរិតមធ្យមសិក្សា ។ ក្នុងពេលសព្វថ្ងៃរឿងនេះហាក់ដូចជាសមស្របហើយ ពីព្រោះគេត្រូវធ្វើយ៉ាងណាឱ្យមានសិស្សចុះឈ្មោះចូលរៀន និងបញ្ចប់ការសិក្សាកំរិតបឋមសិក្សា កាន់តែច្រើនឡើង ហើយវានឹងបង្កើនតំរូវការ ការអប់រំកំរិតអនុវិទ្យាល័យជាបន្ទុមកទៀត ។

អន្តរាគមន៍ក្នុងផ្នែកឯទៀត ហាក់ដូចកើតមានហើយ ដូចជា ការចូលរួមអនុវត្តសិទ្ធិ/កាតព្វកិច្ចជាពលរដ្ឋ របបប្រជាធិបតេយ្យ សិទ្ធិមនុស្ស ការតស៊ូមតិ និងការប្រយុទ្ធប្រឆាំងនឹងអាជីវកម្មផ្លូវភេទនិងការជួញដូរកុមារ ។ ផ្នែកសិទ្ធិកុមារ បទល្មើសរបស់កុមារ អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាជាប់ទាក់ទងនឹងយេនឌ័រ ហាក់ដូចអនុវត្តបានសមស្របក្នុងតំបន់មេគង្គកណ្ដាល និងតំបន់ទន្លេសាប ចំណែកឯតំបន់នៅតាមជាយដែនវិញ ហាក់ដូចដោះស្រាយមិនបានល្អទេ ។ ដោយឡែកខេត្តកំពង់ស្ពឺ ក៏ត្រូវបានចាត់ចូលក្នុងតំបន់ដោះស្រាយមិនបានល្អដែរ ។

យោងតាមកត្តាពេលវេលា និងធនធានមានកំរិត ការធ្វើផែនទីអាចគ្រាន់តែសំរាប់វាយតំលៃពីចំនួនអន្តរាគមន៍នៅតាមខេត្តប៉ុណ្ណោះ ដោយគ្មានបញ្ជាក់ពីទំហំលទ្ធផល ឬឆ្លុះបញ្ចាំងស៊ីជំរៅពីឥទ្ធិពលនៃអន្តរាគមន៍នោះឡើយ ។ ឧទាហរណ៍ គំរោងមួយដែលសំដៅជួយយុវជន ៥០នាក់ ក្នុង ២ឃុំ និងកម្មវិធីមួយទៀតសំរាប់ជួយយុវជន ៥០០នាក់ ក្នុង ២០ឃុំ ត្រូវបានចាត់ទុកអន្តរាគមន៍តែមួយ ។ ការធ្វើផែនការលំអិត នឹងគ្រប់ជ្រុងជ្រោយ អាចជួយបញ្ជាក់ច្បាស់ពីអន្តរាគមន៍នានានៅកំរិតស្រុក ឬឃុំ ។

## ឯកសារយោង

*សូមមើលឯកសារយោងក្នុងអត្ថបទភាសាអង់គ្លេស*

# ការកសាងសមត្ថភាពសហគមន៍អនុវត្តគំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រក្នុងតំបន់អាងទន្លេសាប —លទ្ធផលរកឃើញខ្លះៗបានពីអង្កេតជាមូលដ្ឋាន

*ដោយ កុយ រ៉ា និង អែម សូវ៉ានី*[១]

## ១. សេចក្តីផ្តើម

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានធ្វើការសិក្សាសំខាន់ៗ ២ ស្តីពីភាពក្រីក្រនៅកម្ពុជា ។ នៅឆ្នាំ២០០១ វិទ្យាស្ថានបានបង្ហើយការវាយតំលៃពីភាពក្រីក្រ នៅ ២៤ភូមិ ក្នុង ៦ខេត្ត នៅជុំវិញបឹងទន្លេសាប (Ballard 2007) និង ការសិក្សាពីការចាកផុតភាពក្រីក្រ (Moving Out of Poverty Study: MOPS) ដែលបានពិនិត្យស៊ីជំរៅលើ ៩ភូមិ ក្នុងតំបន់កសិ-អេកូឡូស៊ីទាំងបួននៃជនបទកម្ពុជា គឺមានវាលទំនាបបឹងទន្លេសាប វាលទំនាបទន្លេមេគង្គ តំបន់ភ្នំ/ខ្ពង់រាប និង តំបន់ឆ្នេរ (Fitzgerald & So 2007) ។ ការសិក្សាទាំងពីរ បានបង្ហាញពី កត្តាកំណត់ និង កត្តារួមផ្សំនានា ដែលនាំឱ្យមានភាពក្រីក្រ និងបានផ្តល់មតិខាងគោលនយោបាយមួយចំនួន សំដៅកាត់បន្ថយភាពក្រីក្រ ។

នៅខែមករា ២០០៩ CDRI បានបង្ហើយការសិក្សាមួយទៀតដើម្បីស្រាវជ្រាវពី កត្តានានាដែលជួយកសាងសមត្ថភាពសហគមន៍ដើម្បីអនុវត្តគំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រ នៅតំបន់ជុំវិញបឹងទន្លេសាប ។ ការសិក្សានេះ ក៏ពិនិត្យផងដែរពីកត្តាកំនត់ផ្សេងៗនៃភាពក្រីក្រ ព្រមទាំងចំណេះដឹង និងសមត្ថភាពរបស់សហគមន៍នៅ ១១ភូមិ ក្នុង ៥ខេត្ត នៅជុំវិញបឹងទន្លេសាប ។ វិធីសាស្ត្រស្រាវជ្រាវដែលបានប្រើប្រាស់ គឺមាន (១) ការធ្វើចំណាត់ថ្នាក់ទ្រព្យធនសង្គម, (២) ការពិភាក្សាតាមក្រុមស្តូលអំពី សកម្មភាពចិញ្ចឹមជីវិត និងទ្រព្យសកម្មរបស់សហគមន៍ និង (៣) ការប្រើបញ្ជីសំនួរស្រង់ព័ត៌មានពីជីវភាព ចំណូលចំណាយ ទ្រព្យសកម្ម ការប៉ះទង្គិច និងដីកសិកម្ម របស់គ្រួសារនីមួយៗ ។ ការសិក្សានេះមានគោលដៅកំណត់ពីចំនេះដឹង សកម្មភាពចិញ្ចឹមជីវិត និងស្ថានភាពក្រីក្រ នៅតាមភូមិនានា ។ ម្យ៉ាងទៀតការសិក្សាក៏ព្យាយាមកំនត់នូវ ចំណេះដឹងដែលត្រូវមានដើម្បីកែលំអ របៀបរបបរកចិញ្ចឹមជីវិតរបស់គ្រួសារនានា ។

ការសិក្សាទទួលថវិកាពី មូលនិធិជប៉ុនសំរាប់ការកាត់បន្ថយភាពក្រីក្រ (Japan Fund for Poverty Reduction) និងគ្រប់គ្រងដោយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ។ការសិក្សាបានធ្វើឡើងលើ ៦៣៨គ្រួសារក្រីក្រ និង ក្រីក្រណាស់ជ្រើសចេញពីក្នុងចំណោម ១៥៩០គ្រួសារ ក្នុង ៨ភូមិដែលមានអនុវត្តគំរោង ២ របស់ ADB ពោលគឺ គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប (Tonle Sap Environmental Management Project: TSEMP) និង គំរោងជីវភាពមានចីរភាពនៅបឹងទន្លេសាប (Tonle Sap Sustainable Livelihoods Project: TSSLP)[២] ។ គំរោង TSEMP បានចប់រួចរាល់នៅខែធ្នូ ២០០៨ រីឯគំរោង TSSLP គ្រោងបញ្ចប់នៅខែមិថុនា ២០១០ ។ ដូច្នេះការសិក្សានេះនឹងប្រើការជាមូលដ្ឋានសំរាប់វាស់វែងកំណែលំអជីវភាព ភាពក្រីក្រក្នុងមូលដ្ឋាន ដែលផុសចេញពី ការអនុវត្តគំរោងទាំងពីរខាងលើ ។ អង្កេតក៏បានធ្វើឡើងក្នុង ៣ភូមិទៀតដែលគ្មានគំរោង TSEMP ទេ សំរាប់ធ្វើការប្រៀបធៀប ។ អត្ថបទនេះ បង្ហាញពីលទ្ធផលរកឃើញជាដំបូងៗក្នុងការសិក្សានេះ ។

## ២. កត្តាកំណត់ភាពក្រីក្រនៅក្នុងភូមិសិក្សា

លោក Jalilian (2008) ដោយសំអាងលើឯកសារ Weiss and Khan (2006) បានវែកញែកថា កត្តាកំណត់ភាពក្រីក្រ មាន ៣ប្រភេទធំៗ:

- កត្តាបុគ្គលផ្ទាល់ខ្លួន: រួមមាន ជំនាញទាប អក្ខរកម្មអន់ខ្សោយ ទំហំគ្រួសារធំ កង្វះទ្រព្យសកម្ម និង អាចមានបញ្ហាខាងយេនឌ័រ និងខាងជនជាតិ ថែមទៀត ។
- កត្តាទីតាំង: រួមមាន លទ្ធភាពបានប្រើប្រាស់តិចតួចនូវហេដ្ឋារចនាសម្ព័ន្ធសង្គមនិងរូបវ័ន្ត ដូចជា ផ្លូវថ្នល់ ទឹកភ្លើង សេវាថែទាំសុខភាព និងការអប់រំ ។
- កត្តារចនាសម្ព័ន្ធ : រួមមាន ភាពខ្សត់ខ្សោយនៃ ព័ត៌មានពីទីផ្សារ ប្រព័ន្ធហិរញ្ញវត្ថុ និងឥណទាន ។

លទ្ធផលរកឃើញជាដំបូងៗ ជាពិសេសបានពីការពិភាក្សាក្នុងក្រុមស្តូល បង្ហាញពីកត្តាកំណត់ភាពក្រីក្រមួយចំនួន ក្នុងចំណោមគ្រួសារដែលបានសិក្សា ។ កត្តាទាំងនោះរួមមាន ស្ថានភាពផ្ទះសំបែង ដីធ្វើកសិកម្ម ការដឹកជញ្ជូន ប្រភពកំលាំងធ្វើកសិកម្ម ប្រភពថាមពល លទ្ធភាពរកបានសាច់ប្រាក់ឬឥណទាន និង ប្រភពចំណូល ។ កង្វះទ្រព្យសកម្ម និងកង្វះលទ្ធភាពទទួលបានឥណទានសំរាប់សកម្មភាពចិញ្ចឹមជីវិត ជាដើម ជាកត្តាចំបងៗដែលរុញច្រានគ្រួសារឱ្យធ្លាក់ខ្លួនក្រីក្រ ។ គ្រួសារក្រីក្រណាស់នៅក្នុងភូមិមានដីតិចជាង ១ហិកតា រីឯគ្រួសារធូធារអាចមានដល់ ២ ទៅ ១៥ហិកតា ។ ម្យ៉ាងទៀត គ្រួសារក្រីក្រ និងក្រីក្រណាស់ ពុំមានលទ្ធភាពទទួលបានឥណទានសំរាប់ធ្វើផលិតកម្មទេ ប៉ុន្តែ អាចទទួលបានកំចីតូចៗសំរាប់ដោះស្រាយធុរៈបន្ទាន់ផ្សេងៗ ។ ប្រភពចំណូលគ្មានស្ថិរភាពដូចជា ការលក់ពលកម្មនៅតាមភូមិលើដីគោក និងការនេសាទទ្រង់ទ្រាយតូចដោយប្រើឧបករណ៍នេសាទបែបបូរាណនៅតាមភូមិបណ្តែតទឹក ក៏បានរុញច្រានឱ្យគ្រួសារធ្លាក់ខ្លួនក្រីក្រដែរ ។

## ៣. ស្ថានភាពក្រីក្រនៅក្នុងភូមិសិក្សា

ការធ្វើចំណាត់ថ្នាក់ទ្រព្យធន ក៏បានបង្ហាញពីស្ថានភាពក្រីក្រនៅក្នុងភូមិនីមួយៗដែរ គឺ នៅក្នុងភូមិទាំង ១១ ដែលបានសិក្សា មាន គ្រួសារក្រីក្រ និង

១ កុយ រ៉ា ជាអ្នកស្រាវជ្រាវខាងបរិស្ថាននិងធនធានធម្មជាតិ និង អែម សូវ៉ានី ជាអ្នកគ្រប់គ្រងខាងចំនេះដឹងដើម្បីអភិវឌ្ឍន៍ នៅ CDRI ។ របាយការណ៍ពេញលេញនៃអង្កេតជាមូលដ្ឋាននេះ នឹងចេញផ្សាយនៅខែមីនា ២០០៩ ។

២ ព័ត៌មានបន្ថែមលើ TSEMP និង TSSLP មានចុះក្នុង http://www.adb.org/Projects/Tonle_Sap/livelihoods.asp, accessed on January 2009.

ក្រីក្រណាស់ ចំនួន ៣២% និង ២០% ក្នុងចំនោមគ្រួសារសរុប ១៥៩០គ្រួ ។

គួរកត់សំគាល់ថា ចំនួនសំណាកគ្រួសារក្រីក្រ និងក្រីក្រណាស់ ក្នុងភូមិនីមួយៗ គឺខុសគ្នាពីចំនួនពិតប្រាកដ (តារាងលេខ១) ។ ការសិក្សានេះបានព្យាយាមធ្វើសំភាសន៍ជាមួយគ្រួសារក្រីក្រ និងក្រីក្រណាស់ទាំងអស់ ប៉ុន្តែដោយសារការប្រមូលទិន្នន័យធ្វើឡើងនៅចំពេលដែលអ្នកភូមិរវល់ ឬមានអ្នកភូមិខ្លះបានធ្វើចំណាកស្រុកបណ្តោះអាសន្នទៅកាន់ព្រំដែនខ្មែរ-ថៃ ដូច្នេះយើងក៏មិនអាចជួបនឹងជនមុខសញ្ញាត្រូវធ្វើសំភាសន៍ទាំងនោះបាន ។

ភូមិបង្គល និង ភូមិតាដោក ស្ថិតនៅលំដាប់ថ្នាក់ទី១ និង ទី២ បើគិតតាមចំនួនគ្រួសារក្រីក្រ និងក្រីក្រណាស់ ដែលមាននៅក្នុងភូមិ ដោយមានគ្រួសារ ៩៦% និង ៩៤% ស្ថិតក្នុងប្រភេទទាំងពីរនេះ ។ រីឯភូមិត្នោតកំបុត និង ភូមិដូនទ្រ ដែលស្ថិតក្នុងខេត្តសៀមរាប គឺមានគ្រួសារក្រីក្រ និងក្រីក្រណាស់ តិចជាងគេបំផុត ត្រឹមតែ ២៤% ។

នៅមុនពេលធ្វើអង្កេត មានគ្រួសារក្រីក្រ និងក្រីក្រណាស់ មួយចំនួនបានធ្វើចំណាកស្រុកទៅកាន់ព្រំដែន ឬ ទៅប្រទេសថៃ ។ ភូមិព្រែកក្រួចក្នុងខេត្តបាត់ដំបង និង ភូមិស្រីរង៉ែតក្នុងខេត្តកំពង់ធំ មានគ្រួសារក្រីក្រ និងក្រីក្រណាស់ ធ្វើចំណាកស្រុកច្រើនជាងគេបំផុតដល់ទៅ ៣៨% និង ៣៣% ។

ប្រជាជនធ្វើចំណាកស្រុកដោយសារមូលហេតុចំបង ៣ : (១) កសិកម្មផ្តល់ផលតិចដោយសារគ្រោះធម្មជាតិដូចជា ភាពរាំងស្ងួត និងទឹកជំនន់, (២) សត្វល្អិត ឬសត្វផ្សេងទៀត បំផ្លាញដំណាំ និង (៣) វត្តមានបណ្តាញក្នុងភូមិដែលជួយសំរួលដល់ការធ្វើចំណាកស្រុក ។

គ្រួសារភាគច្រើនដែលធ្វើចំណាកស្រុកទៅកាន់ព្រំដែន តែងចូលរួមក្នុងសកម្មភាពកសិកម្មដូចជា ការច្រូតកាត់ជាដើម រីឯជនចំណាកស្រុកទៅប្រទេសថៃ គេចូលរួមក្នុងការងារសំណង់ និងការងារបេះផ្លែឈើ ។

គេបានរាយការណ៍ថា ជនចំណាកស្រុកទៅធ្វើការជាកម្មករសំណង់នៅប្រទេសថៃ អាចរកចំណូលបាន ២០.០០០រៀល (២០០បាត) ក្នុង១ថ្ងៃ សំរាប់បុរស និង ១៦.០០០រៀល សំរាប់នារី ។ ចំពោះជនចំណាកស្រុកទៅថៃធ្វើជាអ្នកបេះផ្លែឈើវិញ គេបានប្រាក់កំរៃប្រហាក់ប្រហែលនឹង អ្នកដែលធ្វើការងារច្រូតស្រូវ ប្រមូលផលដំឡូង ពោត និងសណ្តែកនៅតាមព្រំដែនដែរ គឺ ១២.០០០រៀល/ថ្ងៃ ប៉ុន្តែត្រូវរ៉ាប់រងបន្ទុកចំណាយលើការធ្វើចំណាកស្រុកថែមទៀត ។

## ៤. ចំណេះដឹង ជំនាញ និង សមត្ថភាព នៅក្នុងភូមិសិក្សា

កំរិតអប់រំរបស់អ្នកឆ្លើយសំភាសន៍ក៏ជួយបំភ្លឺពីសមត្ថភាពក្នុងការទទួលបាន និង ប្រើប្រាស់នូវ ចំនេះដឹង និងជំនាញ ក្នុងការចិញ្ចឹមជីវិតដែរ ។ លទ្ធផលរកឃើញពីមុន បង្ហាញថា អ្នកឆ្លើយសំភាសន៍មានមិនដល់ ២% ទេ ដែលបានរៀនចប់មធ្យមសិក្សា (ថ្នាក់ទី ១២) និងមាន ៥៣% បានបញ្ចប់កំរិតបឋមសិក្សា (ថ្នាក់ទី ៦) និង ៣៥% ទៀត មិនដែលបានចូលរៀនសាលាឡើយ ។ តួលេខនេះបញ្ជាញថា ពួកអ្នកឆ្លើយសំភាសន៍មានកំរិតសិក្សាទាបជាទូទៅ ។ ដោយសារពួកគេជាមេគ្រួសារ ដូច្នេះពុំមានឱកាសនឹងបានចូលរៀនទៀតឡើយ ។

លោក អែម បានពិនិត្យឡើងវិញពីនិយមន័យពាក្យ ចំនេះដឹង និងបានផ្តល់មតិថា ក្នុងបរិបទនៃការសិក្សានេះ ចំនេះដឹង គឺជាពត៌មានដែលមាន

**តារាង ១: ចំនួនគ្រួសារក្រីក្រ និង ក្រីក្រណាស់ សរុបនៅតាមភូមិនីមួយៗ**

| ភូមិ | គ្រួសារសរុបក្នុងភូមិ | គ្រួសារក្រ និងក្រណាស់ក្នុងភូមិ | | គ្រួសារក្រ និងក្រណាស់ អវត្តមានក្នុងពេលអង្កេត | | ចំនួនគ្រួសារក្រ និងក្រណាស់ មានវត្តមានក្នុងពេលអង្កេត | គ្រួសារក្រ និងក្រណាស់បានសំភាស | |
|---|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | | ចំនួន | ភាគរយ |
| ក្រពើពុល | 107 | 80 | 75 | 25 | 31 | 55 | 54 | 98 |
| តាដោក | 105 | 99 | 94 | 0 | 0 | 99 | 81 | 82 |
| ឬស្សីតាម៉ន | 214 | 93 | 43 | 0 | 0 | 93 | 80 | 86 |
| បង្គល | 69 | 66 | 96 | 0 | 0 | 66 | 56 | 85 |
| ផ្សារលើ | 91 | 54 | 59 | 10 | 19 | 44 | 44 | 100 |
| ព្រែកក្រួច | 243 | 78 | 72 | 30 | 38 | 48 | 48 | 100 |
| ដូនទ្រ | 169 | 40 | 24 | 4 | 10 | 36 | 36 | 100 |
| ភូមិបី | 107 | 61 | 57 | 7 | 11 | 54 | 54 | 100 |
| ត្នោតកំបុត | 194 | 46 | 24 | 7 | 15 | 39 | 39 | 100 |
| ពាមបាំង | 119 | 76 | 64 | 10 | 13 | 66 | 66 | 100 |
| ស្រី រង៉ែត | 172 | 119 | 69 | 39 | 33 | 80 | 80 | 100 |
| **សរុប** | **1590** | **812** | **56** | **132** | **16** | **680** | **638** | **94** |

ប្រភព: អង្កេតរបស់ CDRI នៅខែមករា ២០០៩

ប្រយោជន៍សំរាប់ការធ្វើសកម្មភាព ឬសំរាប់ការរកចិញ្ចឹមជីវិត ។ ចំពោះជំនាញវិញ វាជួយឱ្យគេអាចប្រើប្រាស់ចំណេះដឹងដើម្បីផលិតធាតុចេញអ្វីមួយ រីឯសមត្ថភាព វាបង្កើតលទ្ធភាពផលិតបាននូវធាតុចេញ ដែលមានបរិមាណ និងគុណភាពខុសពីមុន ។ និយមន័យនេះផ្ដល់គំនិតថា អ្នកមានចំនេះដឹងមិនមែនសុទ្ធតែអាចផលិតធាតុចេញ តាមការកំនត់រាល់ៗលើកនោះទេ ប៉ុន្តែអ្នកមានជំនាញ និងមានសមត្ថភាពអាចធ្វើខុសពីនេះបាន ។ ចំណេះដឹង និងជំនាញ អាចពិនិត្យឃើញច្បាស់តាមរយៈមុខរបរ និងប្រភពចំណូល រីឯសមត្ថភាព អាចកំណត់បានតាម លទ្ធភាពដោះស្រាយបញ្ហាផ្សេងៗ ដែលផុសឡើងពី សកម្មភាពចិញ្ចឹមជីវិត ។

លទ្ធផលរកឃើញជាដំបូងៗ បង្ហាញថា អ្នកភូមិនៅជុំវិញបឹងទន្លេសាប ចិញ្ចឹមជីវិតដោយប្រកបរបរចំបងៗ ៥ យ៉ាង និង មាន ១៦ប្រភពចំណូល ។ មុខរបរទាំង ៥យ៉ាង គឺមាន ការនេសាទ ការចិញ្ចឹមសត្វ ការដាំដំណាំលក់យកប្រាក់ ការដាំដុះស្រូវ និងការលក់ពលកម្ម ។ ប្រភពចំណូលទាំង ១៦ គឺមាន ការនេសាទ ការលក់ពលកម្មដាំដុះស្រូវ ការដាំដំណាំលក់យកប្រាក់ ការដំណើរការមុខរបរដោយខ្លួនឯង ការដាំដុះស្រូវ ការលក់ពលកម្មធ្វើសំណង់ ការលក់ពលកម្មធ្វើការងារមិនមែនកសិកម្ម ការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល ការងាររដ្ឋ រឺ ការងារក្រុមហ៊ុន ការលក់ពលកម្មឱ្យឡូត៍នេសាទ ការងារចំណាកស្រុក ការផលិតបន្លែនិងផ្លែឈើ ការចិញ្ចឹមសត្វ ការរស់នៅក្នុងបន្ទុកគេ (អនិស្សរភាព) ការងារក្នុងរោងចក្រកាត់ដេរ ការងារក្នុងអាជីវកម្មតាមមូលដ្ឋាន និងការបេះប្រមូលផលព្រៃឈើ ។ របរចិញ្ចឹមជីវិត និងប្រភពចំណូលទាំងនេះ បង្ហាញពីវត្តមានចំណេះដឹង និងជំនាញពាក់ព័ន្ធជាច្រើន ។

ដូចនេះ ការកែលំអប្រភពចំណូល ឬផលិតកម្មស្បៀងអាហារ អាចជួយបង្កើនចំណេះដឹង និងជំនាញ និង/ឬ ការផ្ដល់ ចំណេះដឹង និងជំនាញសមស្របថ្មី ហើយកសិករក៏អាចកសាងសមត្ថភាពដោយខ្លួនឯង ដើម្បីបង្កើនផលិតផល ។ ប៉ុន្តែ ការពង្រឹងសកម្មភាពចិញ្ចឹមជីវិត មិនមែនបញ្ចប់ដោយការកែលំអ និងការផ្ដល់ចំណេះដឹង និងជំនាញនោះឡើយ ។ ការសំខាន់មួយទៀតគឺត្រូវលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិឱ្យមានចីរភាព តាមរយៈគំរោងផ្សេងៗ និងគោលនយោបាយអំណោយផលដល់អ្នកក្រ ។

## ៥. កត្តាប៉ះពាល់ដល់ស្ថានភាពក្រីក្រនៅក្នុងភូមិសិក្សា

មានកត្តាច្រើនទៀតដែលអាចចូលរួមកាត់បន្ថយភាពក្រីក្រ ។ ដើម្បីកែលំអផលិតភាពកសិកម្ម លោក អែម (២០០៨) ដោយយោងដល់ឯកសាររបស់ Swanson (1985) បានបញ្ជាក់ថា គ្រួសារកសិករនីមួយៗអាចមានជំនួយគាំទ្រជាច្រើន ដូចជា ការស្រាវជ្រាវ សេវាផ្សព្វផ្សាយបច្ចេកទេស គោលនយោបាយ និងផែនការរដ្ឋាភិបាល ការអប់រំ ឥណទាន ធាតុចូលកសិកម្ម និងព័ត៌មានទីផ្សារជាដើម ។ ការគាំទ្រទាំងនេះគឺជាកត្តារួមចំណែកដោយផ្ទាល់ និងដោយប្រយោល ដល់ការកាត់បន្ថយភាពក្រីក្រ ។

ការសិក្សា MOPS បានរកឃើញថា ភាពក្រីក្រក្នុងភូមិមានកំរិតខ្ពស់ បើសិនប្រជាជនពឹងផ្អែកលើធនធានទ្រព្យរួម ។ ការសិក្សាជាមូលដ្ឋាន បានកត់ត្រាពីធនធានរួមក្នុងភូមិនីមួយៗ ។ ទ្រព្យសម្បត្តិសហគមន៍ រួមមានធនធានទ្រព្យរួម និង ទ្រព្យ ៥ មុខទៀត គឺ ទ្រព្យធម្មជាតិ ទ្រព្យសង្គម ទ្រព្យមនុស្ស ទ្រព្យរូបវ័ន្ត និង ទ្រព្យសេដ្ឋកិច្ច ។

- ទ្រព្យធម្មជាតិរួមមានដីកសិកម្ម ព្រៃឈើ ឬ ព្រៃលិចទឹកនិងធនធានទឹក ។ ក្នុងចំណោមភូមិសិក្សា មានពាក់កណ្ដាលស្ថិតក្នុងតំបន់លិចទឹក ក្នុងនេះមានភូមិមួយចំនួន ដែលប្រជាជនអាចពុំមានសិទ្ធិកាន់កាប់ដីកសិកម្ម ទោះបី ពួកគេអាចដាំដំណាំនៅរដូវប្រាំងបានក្ដី ។ ការនេសាទរបស់ពួកគេពឹងលើព្រៃលិចទឹក និងតំបន់នេសាទរួមនានា ។ ភាពក្រីក្រក្នុងភូមិទាំងនេះ ច្រើនមានកំរិតខ្ពស់ជាងភូមិនៅដីគោក ពីព្រោះអ្នកភូមិនៅដីគោក គេអាចប្រើប្រាស់តំបន់នេសាទរួមនានានៅបឹងទន្លេសាប ហើយថែមទាំងអាចមានកម្មសិទ្ធិដីកសិកម្ម និងប្រភពចំណូលផ្សេងទៀត ដូចជា ការលក់ពលកម្ម និងការបេះប្រមូលអនុផលព្រៃឈើជាដើម ។ ទោះយ៉ាងនេះក្ដី ទំនាស់ពាក់ព័ន្ធនឹងឡូត៍នេសាទ បទប្បញ្ញត្តិអភិរក្សសម្បត្តិធម្មជាតិ និងច្បាប់នេសាទ បង្កឧបសគ្គជាច្រើនដល់តំបន់នេសាទ ។
- ទ្រព្យសង្គម ជាទំនាក់ទំនងរវាងអ្នកភូមិ និងជនខាងក្រៅដែលអាចគាំទ្រដល់ការងារអភិវឌ្ឍន៍សហគមន៍ ការចូលរួមជាទូទៅក្នុងការអភិវឌ្ឍសហគមន៍ សុខភាពប្រជាជនក្នុងភូមិ និងគំរោងអភិវឌ្ឍមួយចំនួន ។ នៅតាមភូមិសិក្សា ទំនាក់ទំនងបែបនេះគេឃើញមានក្នុងការដោះដូរពលកម្ម (ប្រវាស់ដៃ) គ្នាធ្វើសកម្មភាពកសិកម្ម ឬ ការសាងសង់ផ្ទះ ។ ប៉ុន្តែការដោះដូរពលកម្មកំពុងតែជំនួសជាបណ្ដើរៗដោយការជួលពលកម្ម ទាំងនៅក្នុងភូមិតំបន់ដីគោក និងភូមិលិចទឹក ។ គំរោងអភិវឌ្ឍន៍នានា ជាពិសេស ស្ថាប័នផ្ដល់កំចី ក៏បានជួយទ្រទ្រង់យ៉ាងច្រើនដល់សកម្មភាពចិញ្ចឹមជីវិតដែរ ទោះបីជា ក្រុមទន់ខ្សោយនានា មិនទាន់អាចប្រើសេវាកម្មទាំងនេះទេដោយសារតំរូវការវត្ថុសំរាប់ដាក់ធានាដើម្បីខ្ចីប្រាក់ ។ អ្នកចងការប្រាក់ឯកជន និងអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម ផ្ដល់កំចីដោយឈរលើមូលដ្ឋានការទុកចិត្តគ្នា និងទំនាក់ទំនងរវាងអ្នកជំនួញនិងអតិថិជន ដោយក្នុងនេះ អ្នកភូមិអាចទិញជឿនូវធាតុចូលសិកម្ម ហើយត្រូវសងវិញ ដោយការលក់កសិកផលដែលប្រមូលបានទៅឱ្យអ្នកផ្គត់ផ្គង់ ។ ការទិញសំភារៈនេសាទ នៅតាមភូមិបណ្ដែតទឹកក៏មានបែបបទដូចគ្នានេះដែរ ។
- ទ្រព្យមនុស្ស រងឥទ្ធិពលពីការបណ្ដុះបណ្ដាល ការអប់រំជាលក្ខណៈផ្លូវការ លទ្ធភាពទទួលបានការថែទាំសុខភាព និងសេវាកម្មផ្សេងៗទៀតក្នុងមូលដ្ឋាន ។ ជាទូទៅ អក្ខរកម្មមានកំរិតទាបក្នុង ក្រុមប្រជាជនទន់ខ្សោយនានា ដោយសារប្រាក់ចំណូលគ្មានស្ថិរភាព និងកង្វះសាលារៀន ។ គេរកឃើញថា កុមារនៅតាមភូមិបណ្ដែតទឹក តែងឈប់រៀនត្រឹមថ្នាក់ទី៦ ព្រោះភូមិទាំងនោះ មិនមានសាលារៀនខ្ពស់ជាងកំរិតបឋមសិក្សាទេ ។ ចំពោះកុមាររស់នៅតាមភូមិតំបន់ដីគោកវិញ គឺអាចចូលរៀនសាលាមធ្យមសិក្សាដែលស្ថិតនៅក្នុងភូមិឯទៀតបាន ប្រសិនបើភូមិរបស់ពួកគេ ពុំមានថ្នាក់រៀនកំរិតនេះ ប៉ុន្តែតាមការសង្កេតឃើញជាទូទៅ ពួកគេតែងឈប់រៀនត្រឹមថ្នាក់ទី៩ ។ ការពិភាក្សាតាមក្រុមស្នូលក៏បានកត់សំគាល់ពីកង្វះកន្លែងព្យាបាលសុខភាពដែរ ។ ឧទាហរណ៍ មានអ្នកភូមិក្រីក្រខ្លះបានសំរាលកូនដោយមានតែឆ្មបបូរាណប៉ុណ្ណោះ ដូច្នេះហើយបើសិនមានបញ្ហាអ្វីមួយ វាអាចស្មុគស្មាញលើសពីសមត្ថភាពដែលមានក្នុងភូមិ ឬមណ្ឌលសុខភាពនៅជិតនោះ ។
- ទ្រព្យរូបវ័ន្តក្នុងការសិក្សានេះ រួមមាន សត្វអូសទាញ និងហេដ្ឋារចនាសម្ព័ន្ធ

ដូចជា ទីកន្លែងខាងសាសនា ផ្លូវថ្នល់ ទីផ្សារ ការផ្គត់ផ្គង់ទឹក និងការដឹកជញ្ជូន ។ វត្តអារាម ជាធនធានរួមមួយ ទាំងនៅក្នុងភូមិតំបន់ដីគោក និងភូមិបណ្តែតទឹក ។ នៅតាមភូមិបណ្តែតទឹក វត្តអារាមជារឿយៗក្លាយជាទីជំរកទៀតផងនៅពេលមានទឹកជំនន់ខ្លាំង ក្រៅពីករណីធម្មតាជាកន្លែងសំរាប់ពិធីបុណ្យ ការជួបប្រជុំ និងការសិក្សាកំរិតបឋមសិក្សា ជាដើម ។ នៅតាមភូមិតំបន់ដីគោកភាគច្រើន ផ្លូវចេញចូលភូមិក៏បាន ប្រសើរឡើងដែរ ។ ប៉ុន្តែការចេញចូលទៅកាន់ភូមិបណ្តែតទឹកវិញនៅតែលំបាក ដោយសារការហាមឃាត់ មិនឱ្យប្រើទូកនៅជិតព្រំប្រទល់ឡូត៍នេសាទ និងដោយសារមានឧបករណ៍ចាប់ត្រីដូចជាលបជាដើម នៅក្នុងប្រលាយព្រែក ស្ទឹង របស់ឡូត៍នេសាទនានា ។ ឧទាហរណ៍ដូចជា ដើម្បីចូលទៅភូមិពាមបាំង តាមស្ទឹងស្ទោង គេត្រូវឆ្លងកាត់ឡូត៍នេសាទប្រហែលជា ១០កន្លែង ដែលមានដាក់លប និងឧបករណ៍ចាប់ ត្រីផ្សេងៗយ៉ាងច្រើន រីឯច្រកចូលតាមភូមិផ្សារក្រគរកាត់បឹងទន្លេសាបវិញ អាចមានគ្រោះថ្នាក់សំរាប់ទូកតូចៗ ព្រោះមានទឹកជោរ-ទឹកនាច និងរលកធំៗ ។

- ទ្រព្យសេដ្ឋកិច្ចក្នុងការសិក្សានេះ សំដៅដល់ទ្រព្យទាំងឡាយដែលអ្នកភូមិងាយនឹងប្តូរជាសាច់ប្រាក់ ។ ទ្រព្យទាំងនេះ រួមមាន គោក្របី មាន់ទា គ្រឿងយាន គ្រឿងអលង្ការ ដីកសិកម្ម និងដីលំនៅដ្ឋាន ។ ស្ថាប័នផ្តល់កំចី អ្នកចងការប្រាក់ឯកជន និងអ្នកជំនួញ ជាប្រភពទុនដ៏សំខាន់នៅពេលមានធុរៈបន្ទាន់ កើតឡើង ។ ក្រុមពិភាក្សាស្នូលបានបញ្ជាក់ថា អ្នកភូមិតំបន់ដីគោកភាគច្រើន ពឹងផ្អែកលើ គោក្របី ដីកសិកម្ម គ្រឿងយាន និងជួនកាលលើដីលំនៅដ្ឋាន ដើម្បីរកបានសាច់ប្រាក់ជាបន្ទាន់ រីឯអ្នកភូមិបណ្តែតទឹក ពឹងលើ ធនធានត្រី ទូក និងទូកម៉ាស៊ីន ដើម្បីដោះស្រាយ ។ស្ថាប័នផ្តល់កំចី ផ្តល់ការគាំទ្រដល់អ្នកភូមិបណ្តែតទឹកតិចជាង អ្នកភូមិដីគោក ដោយសារពួកគេមានវត្ថុតិចមុខជាង សំរាប់ដាក់ធានាប្រាក់កំចី ។ អ្នកចងការប្រាក់ឯកជន និងអ្នកជំនួញ ក៏ផ្តល់ឥណទានឱ្យដែរ ប៉ុន្តែ អ្នកភូមិត្រូវលក់ត្រីដែលចាប់បានឱ្យពួកគេវិញក្នុងតំលៃថោក ។

វត្ថុមាន ឬកង្វះ ទ្រព្យសកម្មរបស់សហគមន៍ មានផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល លើភាពក្រីក្រនៅតំបន់ជុំវិញបឹងទន្លេសាប ។ ទ្រព្យសកម្មខ្លះអាចកែលំអបានតាមរយៈការផ្តល់ចំណេះ និងសមត្ថភាព រីឯទ្រព្យសកម្មដទៃទៀត អាចធ្វើឱ្យកាន់តែសំបូរ និងងាយបានប្រើប្រាស់ សំរាប់តំបន់ភូមិសាស្ត្រ ឬតំរូវការដ៏ជាក់លាក់មួយចំនួន ។ TSSLP បានផ្តល់ការកសាងសមត្ថភាព និងការកែលំអហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ដូចនេះ ព័ត៌មានទទួលបានពីអង្កេតជាមូលដ្ឋានដែលស្តីពីទ្រព្យសកម្មរបស់ភូមិ អាចជួយកែលំអវិធីសាស្ត្រផ្សេងៗសំរាប់កាត់បន្ថយភាពក្រីក្រ ។

## ៦. ផលចំណេញសំរាប់ការវិភាគបន្ថែមទៀត

លទ្ធផលរកឃើញជាដំបូងៗបង្ហាញថា ក្រៅពីលទ្ធភាពមានកំរិតដើម្បីទទួលបានការថែទាំសុខភាព និងការអប់រំមូលដ្ឋាន កង្វះដីកសិកម្ម លទ្ធភាពបានប្រើប្រាស់តំបន់សំបូរត្រី សាច់ប្រាក់ និងឥណទាន គឺជាកត្តាចំបងដែលធ្វើឱ្យអ្នកភូមិ ជាប់ផុងក្នុងភាពក្រីក្រ ។ ចំណេះ និងសមត្ថភាពទាបក្នុងការប្រឈមមុខនឹង ឧបសគ្គដូចជា គ្រោះរាំងស្ងួត និងសត្វចង្រៃបំផ្លាញផលដំណាំ ក៏នាំឱ្យមានការខាតបង់កសិផល កង្វះអាហារ និងការជំពាក់បំណុលក្នុងពេលមានវិបត្តិដែរ ។

ផលិតកម្មកសិកម្ម នៅតែជាកត្តាស្នូលសំរាប់ការរកចំណូល និងការប្រើប្រាស់ប្រចាំថ្ងៃរបស់គ្រួសារនានា ។ ផ្លូវចេញចូលភូមិ និងទៅកាន់ទីផ្សារបានប្រសើរឡើងយ៉ាងច្រើន ប៉ុន្តែនៅចោទបញ្ហានៅឡើយសំរាប់ភូមិបណ្តែតផ្ទៃទឹក ។ ទូរស័ព្ទចល័ត មានសេវាគ្របដណ្តប់ទូទាំងប្រទេសគឺរាប់បញ្ចូលទាំងភូមិបណ្តែតទឹកផង ។រឿងនេះមានន័យថាព័ត៌មានលើការផ្គត់ផ្គង់និងតំរូវការធាតុចូលកសិកម្ម និងទីផ្សារ គេអាចទទួលងាយជាងមុន ។ ក្នុងស្ថានភាពនេះ តើអន្តរាគមន៍អ្វីដែលអាចជួយជនក្រីក្រឱ្យទទួលបានផលចំណេញ ? តើសេវាផ្សព្វផ្សាយបច្ចេកទេសនិងការបណ្តុះបណ្តាលសហគមន៍ជនបទអាចជួយអ្វីខ្លះដល់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រ ? ចំលើយបំភ្លឺលើសំនួរទាំងនេះមានបញ្ជាក់ក្នុងរបាយការណ៍ពេញលេញ ដែលនឹងចេញផ្សាយនៅខែមីនា ឆ្នាំ២០០៩ ។

### ឯកសារយោង


Ballard, Brett (ed.) (2007), *We Are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap* (CDRI: Phnom Penh)

Em, S. (2008), “Attributes of knowledge sharing among rice farmers in Ou Saray, Takeo, Cambodia”, master’s thesis (University of the Philippines Los Banos)

Fitzgerald, Ingrid & So Sovannarith (2007), *Moving Out of Poverty? Trends in Community Well-Being and Household Mobility in Nine Cambodian Villages* (CDRI: Phnom Penh)

Jalilian, Hossein (2008), “Approaches to Measurement and Analysis of Poverty: the Case of Cambodia”, *Cambodia Development Review,* Vol. 12, Issue 3, July–September 2008 (Phnom Penh: CDRI)

Swanson, B.E. (1985). *Agricultural extension: reference manual* (ROME: FAO)

Weiss, J. & J.A. Khan (eds.) (2006), *Poverty strategies in Asia: A growth plus approach,* (Cheltenham and Northampton, MA: Edward Elgar)

# ភាពក្រីក្រ និងស្ថានភាពខុសគ្នានៃកុមារនៅកម្ពុជា

*ដោយ នេត នាថ, ហ៊ាន ភូមិន្ទ និង កែវ បុប្ផា*[1]

## ១. សេចក្តីផ្តើម

ការវាយតំលៃពីភាពក្រីក្រ បានធ្វើឡើងនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣ ប៉ុន្តែមិនបានផ្តោតជាពិសេស លើភាពក្រីក្ររបស់កុមារទេ ។ នាពេលថ្មីៗ CDRI បានធ្វើការសិក្សានៅការិយាល័យស្តីពីភាពក្រីក្រនិងស្ថានភាពខុសគ្នានៃកុមារនៅកម្ពុជា ដោយប្រើទិន្នន័យប្រភពទីពីរ និងទិន្នន័យរដ្ឋបាលបានពីឯកសារពាក់ព័ន្ធផ្សេងៗ ។ អត្ថបទនេះជាខ្លឹមសារសង្ខេបនៃរបាយការណ៍លើការសិក្សាខាងលើ ដែលនឹងចេញផ្សាយនាពេលឆាប់ៗខាងមុខ ។

កុមារដែលជួបនឹងភាពក្រីក្រ ខ្វះខាតធនធានសំភារៈដូចជា អាហារ ទីជំរក សំលៀកបំពាក់ និងសេវាកម្ម ដ៏ចាំបាច់ផ្សេងៗ ។ កង្វះខាតនេះបានដាក់កំហិតដល់លទ្ធភាពរបស់កុមារដើម្បីប្រើប្រាស់ សក្តានុពលរបស់ខ្លួនឱ្យបានពេញលេញ ។ នៅកំរិតម៉ាក្រូ គេតែងសន្មត់ថា ឥទ្ធិពលនៃភាពក្រីក្រទៅលើកុមារ គឺដូចគ្នានឹង ឥទ្ធិពលនៃភាពក្រីក្រទៅលើមនុស្សពេញវ័យ ពីព្រោះកុមារក៏ជាចំណែកមួយនៃសង្គមដែរ ។ ប៉ុន្តែមតិនេះ ត្រឹមត្រូវតែមួយភាគប៉ុណ្ណោះ ព្រោះកុមារងាយរងគ្រោះដោយការប៉ះទង្គិចពីផ្នែកខាងក្រៅជាងមនុស្សពេញវ័យ ។ ការសិក្សានេះមានបំណងវាយតំលៃពីភាពក្រីក្ររបស់កុមារ និងកំណត់ពីរូបភាពរបស់វា តាមរយៈវិធីសាស្ត្រចំនួន ៣ ដែលមានលើកឡើងក្នុងការសិក្សាសកលស្តីពីភាពក្រីក្រ និងស្ថានភាពខុសគ្នានៃកុមារ របស់ UNICEF ។ ការសិក្សានេះក៏មានលើកដោយសង្ខេបពីផលប៉ះពាល់ខាងគោលនយោបាយផ្សេងៗ ដែលអាចដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិនាពេលអនាគត ។

## ២. គ្របខ័ណ្ឌខាងទស្សនាទាន

អង្គការ UNICEF (2004) បានកំណត់និយមន័យភាពក្រីក្ររបស់កុមារថាជាកង្វះខាតរបស់កុមារនូវធនធានខាង សំភារៈ ស្មារតី និងផ្លូវចិត្ត ដែលត្រូវមានដើម្បីរស់រាន ធំធាត់ និងរីកចំរើន ហើយកង្វះខាតធនធានទាំងនេះធ្វើឱ្យកុមារមិនអាចប្រើប្រាស់សិទ្ធិ សក្តានុពលឱ្យបានពេញលេញ និងចូលរួមជាសមាជិកស្មើភាពនៅក្នុងសង្គម ។ ធនធានសំភារៈ គឺមាន ប្រាក់ចំណូល អាហារ ការសិក្សា សេវាថែទាំសុខភាព និង ការការពារពីហានិភ័យដូចជាគ្រោះថ្នាក់ពាក់ព័ន្ធនឹងការងារប្រើកំលាំងធ្ងន់ជាដើម ។ ធនធានខាងផ្លូវស្មារតី គឺមាន កំលាំងចិត្ត ជីវិតមានន័យ ការរំពឹងសង្ឃឹម ជនគំរូគួរត្រងត្រាប់ និងទំនាក់ទំនងជាមួយអ្នកឋានៈស្មើ ។ ធនធានខាងផ្លូវចិត្ត គឺមានៈ សេចក្តីស្រលាញ់ ទំនុកចិត្ត ការទទួលស្គាល់ ការរាប់បញ្ចូល និងការចាកផុតពីស្ថានភាពមានការរំលោភបំពាន ។ ធនធានទាំងនេះ ជាពិសេសធនធានស្មារតី និងធនធានផ្លូវចិត្ត មិនអាចធ្វើការវាស់វែងបានទេ ដោយសារកង្វះទិន្នន័យនៅកម្ពុជា ។

ឯកសារនេះប្រើប្រាស់វិធីសាស្ត្រ ៣យ៉ាង ក្នុងការវិភាគពីភាពក្រីក្ររបស់កុមារ ។ វិធីសាស្ត្រទី១ ចាត់ទុកភាពក្រីក្ររបស់កុមារជាចំណែកមួយនៃភាពក្រីក្ររបស់ប្រជាជាតិ ពីព្រោះកុមារស្ថិតក្នុងនិយមន័យដ៏ធំទូលាយនៃប្រជាជាតិនេះ ។ វិធីសាស្ត្រទី២ ចាត់ទុកភាពក្រីក្ររបស់កុមារជាភាពក្រីក្ររបស់ ក្រុមគ្រួសារដែលចិញ្ចឹមពួកគេ ដូច្នេះភាពក្រីក្ររបស់គ្រួសារដែលមិនមានកូនចៅជាកុមារ គឺពុំមានដាក់បញ្ចូលក្នុងការសិក្សាទេ ។ វិធីសាស្ត្រទី២នេះ ផ្តោតខ្លាំងលើកុមារ និងព្យាយាមកំណត់ពីចំណូល និងផលវិបាកខាងពលកម្មផ្សេងៗ នៃគ្រួសារដែលមានកុមារ ដោយគ្រួសារត្រូវតែថ្លឹងថ្លែងឱ្យមានតុល្យភាពល្អរវាងការងារ និងទំនួលខុសត្រូវរបស់ គ្រួសារ ។ វិធីសាស្ត្រទាំងពីរខាងលើ សិក្សាពីភាពក្រីក្ររបស់កុមារដោយពិនិត្យលើចំណាយប្រើប្រាស់ ។ វិធីសាស្ត្រទី៣ សិក្សាពីភាពក្រីក្ររបស់កុមារ ដោយពិនិត្យពីសុខុមាលភាពរបស់ពួកគេ ជាពិសេសតាមរយៈតំរូវការ ៥យ៉ាង គឺ អាហារូបត្ថម្ភ សុខភាព ការអប់រំ ការការពារកុមារ និងការគាំពារខាងសង្គមកិច្ច ។ វិធីសាស្ត្រនេះ ហាក់ដូចគួរអនុវត្តជាងគេ ពីព្រោះវាពិនិត្យពីភាពក្រីក្ររបស់កុមារដោយផ្ទាល់តែម្តង ។

សូចនាករនៃកង្វះអាហារូបត្ថម្ភរបស់កុមារគឺ ការចុះស្គម/ខ្សោយជាបន្តបន្ទាប់ ការក្រិនកំពស់ និង ទម្ងន់មិនគ្រប់ ។ ចំពោះសូចនាករនៃសុខភាពកុមារវិញគឺ អត្រាមរណៈរបស់កុមារអាយុក្រោម ៥ឆ្នាំ (U5MR) អត្រាមរណៈរបស់ទារក (IMR) និងសមាមាត្រនៃការចាក់ថ្នាំបង្ការ ជំងឺរាគរូស និងគ្រុនក្តៅ ។ សូចនាករនៃការសិក្សារបស់កុមារគឺ អត្រាចុះឈ្មោះចូលរៀនសុទ្ធនៅកំរិតបឋមសិក្សា និងមធ្យមសិក្សា និង អត្រាបន្តការសិក្សានៅកំរិតបឋមសិក្សា ។ ចំនែកសូចនាករនៃការគាំពារកុមារគឺ ពលកម្មកុមារ ការចុះបញ្ជីកំណើតកុមារ ចំនួនកុមារកំព្រា និង ការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ។ ចំពោះសូចនាករនៃការគាំពារសង្គមវិញគឺ សមាមាត្រប្រជាជនដែលមានការធានារ៉ាប់រងសុខភាព ធានារ៉ាប់រងសង្គម ឬការផ្ទេរប្រាក់ ឬផ្ទេរសំភារៈពីអាជ្ញាធរសាធារណៈ ។ ដោយសារកង្វះទិន្នន័យ យើងមិនអាចពិនិត្យលំអិតលើការគាំពារកុមារ និងការគាំពារខាងសង្គមកិច្ចបានទេ ប៉ុន្តែអត្ថបទនេះក៏មានរៀបរាប់ដោយ សង្ខេបខ្លះដែរ ។

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ទិន្នន័យប្រភពទី២ គឺជាមូលដ្ឋាននៃការវិភាគនេះ ហើយរួមមាន អង្កេតពីសុខភាព និងប្រជាសាស្ត្រកម្ពុជា (CDHS) ឆ្នាំ២០០៥, អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤, ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំ

---

១ នេត នាថ ជាអ្នកស្រាវជ្រាវផ្នែកអភិវឌ្ឍសង្គម នៅ CDRI, ហ៊ាន ភូមិន្ទ ជាអតីតអ្នកគ្រប់គ្រងកម្មវិធីសន្តិសុខមនុស្ស កសាងសន្តិភាព និងការបង្ការទំនាស់ នៃ CDRI ហើយ កែវ បុប្ផា ជាទីប្រឹក្សាខាងស្រាវជ្រាវ នៅ CDRI ។ ឯកសារនេះផ្អែកលើគំរោងភាពក្រីក្រ និងស្ថានភាពខុសគ្នានៃកុមារនៅកម្ពុជា ដែលទទួលមូលនិធិពី UNICEF ។ CDRI សូមសំដែងការអរគុណចំពោះ UNICEF សំរាប់ការគាំទ្រជាហិរញ្ញវត្ថុ និងការផ្តល់យោបល់ស្ថាបនាដល់ការសិក្សានេះ ។

ឆ្នាំ២០០៧-០៨ អង្កេតពីពលកម្មកុមារនៅកម្ពុជា ឆ្នាំ២០០១, អង្កេតពាក់កណ្ដាលជំរឿននៅកម្ពុជាឆ្នាំ២០០៤ និង ទិន្នន័យរដ្ឋបាលបានពី របាយការណ៍ និងឯកសារផ្សេងៗរបស់រដ្ឋ កម្មវិធីថ្នាក់ជាតិទាក់ទងនឹងសុខភាព ការសិក្សា អាហារូបត្ថម្ភរបស់កុមារ ព្រមទាំងកម្មវិធីការពារ និងគាំពារខាងសង្គមកិច្ច ។ បច្ចេកទេសជាច្រើន (probit model, regression techniques) បានយកមកប្រើដើម្បីកំណត់នូវកត្តាផ្សេងៗ ដែលចូលរួមបង្កភាពក្រីក្ររបស់កុមារ ។ សូហ្វវែរ Stata បានយកមកប្រើដើម្បីស្រង់យក និងវិភាគទិន្នន័យដែលបានពីកំរងទិន្នន័យខាងលើ ។

## ៤. លទ្ធផល

### *ភាពក្រីក្រសរុបទូទាំងប្រទេស*

ភាពក្រីក្រនៅកម្ពុជា បានធ្លាក់ចុះពី ៣៩% ក្នុងឆ្នាំ១៩៩៣ មកត្រឹម ៣៤,៧% នៅឆ្នាំ២០០៤ ។ ភាពក្រីក្រនៅតាម ទីជនបទ នៅតែខ្ពស់ជាងនៅភ្នំពេញ និងតំបន់ទីក្រុងដទៃទៀត ។ ប្រជាជននៅជនបទជាង ៣៩% ជាអ្នកក្រ ធៀបនឹង ៥% ប៉ុណ្ណោះនៅភ្នំពេញ ។ តំបន់ជនបទដែលមានអត្រាភាពក្រីក្រខ្ពស់ជាងគេបំផុតគឺ តំបន់ភ្នំ/ខ្ពង់រាប និងតំបន់ទន្លេសាប (៥២% និង ៤៣%) ។[២] សន្ទស្សន៍គំលាតភាពក្រីក្រកំរិតជាតិ[៣] គឺ ៩% និង សន្ទស្សន៍ភាពក្រីក្រធ្ងន់ធ្ងរ[៤] គឺ ៣,៣៤% ។ អត្រាភាពក្រីក្ររបស់ក្រុមជនជាតិផ្សេងៗក៏ខុសគ្នាដែរ ។ ជនជាតិឡាវ និងជនជាតិភាគតិចនៅតាមមូលដ្ឋាន—ព្នង និង កួយ—មានអត្រាភាពក្រីក្រខ្ពស់ជាងគេ គឺ ៥៥,៩% និង ៥១,៦% ។ បន្ទាប់មកទៀត គឺ មានជនជាតិខ្មែរ (៣៤,៦%) និងជនជាតិចាម (២៩,០%) ហើយជនជាតិវៀតណាម (១៨,៩%) និងជនជាតិចិន (៨,៩%) មានអត្រាទាបជាងគេបំផុត ។ និន្នាការ ប្រហាក់ប្រហែលគ្នានេះ ក៏បានសង្កេតឃើញសំរាប់ គំលាតភាពក្រីក្រ និង ភាពក្រីក្រធ្ងន់ធ្ងរ ផងដែរ ។

### *ភាពក្រីក្ររបស់គ្រួសារ និងកត្តាកំណត់*

តាមការប៉ាន់ស្មានផ្អែកលើ CSES 2004 សមាមាត្រនៃគ្រួសារស្ថិតក្រោមខ្សែបន្ទាត់ភាពក្រីក្រ[៥]ដែលមាន កូនអាយុតិចជាង ១៨ឆ្នាំ គឺ ៣៦,៦៣% នៃចំនួនសរុប ។ ក្នុងចំណោមគ្រួសារក្រីក្រទាំងនេះ មាន ៨៧២៣គ្រួសារនៅក្នុងក្រុងភ្នំពេញ, ៤១.៥៨៦គ្រួសារនៅក្នុងតំបន់ទីក្រុងឯទៀត និង ៨៥១.៤២៤គ្រួសារនៅតំបន់ជនបទ ។ គ្រួសារទាំងនេះភាគច្រើន រស់នៅតំបន់វាលទំនាប បន្ទាប់មកគឺ តំបន់ខ្ពង់រាប/តំបន់ភ្នំ និង តំបន់ជុំវិញបឹងទន្លេសាប ។ គ្រួសារដែលមានកូនអាយុតិចជាង១៨ឆ្នាំ មានសន្ទស្សន៍គម្លាតភាពក្រីក្រ ៩,៥៩% និង សន្ទស្សន៍ភាពក្រីក្រធ្ងន់ធ្ងរ ៣,៥៦% ។

ផ្អែកលើទិន្នន័យទាំងនេះគេប៉ាន់ស្មានថា មានកុមារអាយុតិចជាង១៨ឆ្នាំ ចំនួន ២លាននាក់ រស់នៅក្នុងភាពក្រីក្រ និងក្នុងគ្រួសារដែលមានសមាជិក ៥ ឬ ៦នាក់ ហើយ កុមារអាយុតិចជាង ១៨ឆ្នាំ ចំនួន ០,៥លាននាក់ រស់នៅក្នុងភាពក្រីក្រ ជាមួយនឹងគ្រួសារមានសមាជិក ៣នាក់ ឬតិចជាងនេះ ។ ចំនួនអ្នកក្រីក្រកើនឡើង ទៅតាមទំហំគ្រួសារ : គ្រួសារក្រីក្រតំណាងឱ្យ ៣៥%នៃគ្រួសារមានសមាជិក ៥ ឬ ៦នាក់ និង ៤៧% នៃគ្រួសារមានសមាជិក ៧នាក់ឬលើសពីនេះ ប៉ុន្តែត្រឹមតែ ៩%ប៉ុណ្ណោះនៃគ្រួសារមានសមាជិកតិចជាង ៣នាក់ ។ អត្រាភាពក្រីក្រ គម្លាតភាពក្រីក្រ និង អត្រាភាពក្រីក្រធ្ងន់ធ្ងរ តែងថយចុះទៅតាមចំនួនសមាជិកក្នុងបន្ទុកគ្រួសារ ក្នុងនេះ អត្រាសំរាប់គ្រួសារមានសមាជិកតិចជាង ៣នាក់ គឺ ៩,៣% ១,៩% និង ០,៦% ហើយសំរាប់ គ្រួសារមានសមាជិកលើសពី ៧នាក់ គឺ ៤៦,៦% ១២,៥% និង ៥,៤% ។ និន្នាការស្រដៀងគ្នាក៏បានពិនិត្យឃើញ ទាក់ទិននឹងចំនួនសមាជិកក្នុងបន្ទុកគ្រួសារដែរ ។ ក្នុងនេះ អត្រាសំរាប់គ្រួសារមានកូន ៤នាក់ ដែលមានអាយុពី ០-១៤ឆ្នាំ គឺ ៥៩,៥% ១៨% និង ៧,២% ហើយ សំរាប់គ្រួសារមានកូន ៤នាក់ អាយុពី ០-១៧ឆ្នាំវិញគឺ ៥៣,៦% ១៥,៧% និង ៦,៣% ។ គេបានប៉ាន់ស្មានថា ក្នុងចំណោមគ្រួសារក្រីក្រទាំងអស់នៅកម្ពុជា មានកុមារ ៧០០០នាក់ ជាជនពិការ និង លើសពី ៣៣០.០០០នាក់ ត្រូវរស់នៅពឹងផ្អែកលើមនុស្សពេញវ័យតែម្នាក់ (CSES 2004) ។

ការវិភាគ (probit model regression analysis) បានបង្ហាញថា មានកត្តាបន្ថែមច្រើនទៀត ដែលទំនងមានឥទ្ធិពលទៅលើភាពក្រីក្ររបស់កុមារ ។ កត្តាទាំងនេះ គឺមាន អាយុកុមារ កំរិតអប់រំរបស់កុមារ ការរៀបការនៅវ័យក្មេងពេក ចំនួនម៉ោងធ្វើការ កំរិតអប់រំរបស់គ្រួសារកុមារ ចំណាយរបស់គ្រួសារគិតក្នុងមនុស្សម្នាក់លើការថែទាំសុខភាព ចំណាយលើការអប់រំគិតក្នុងមនុស្សម្នាក់ ឧបត្ថម្ភធនខាងផ្នែកសុខភាព លទ្ធភាពបានប្រើប្រាស់ទឹកជំរក និងបង្គន់អនាម័យ ជនជាតិរបស់កុមារ និង ចរិតលក្ខណៈសហគមន៍ ។

កុមារអាយុពី ០-២ឆ្នាំ មានហានិភ័យក្លាយជាអ្នកក្រ ខ្ពស់ជាងកុមារនៅក្រុមអាយុច្រើនជាងនេះ ប៉ុន្តែកត្តាភេទ មិនឃើញមានឥទ្ធិពលអ្វីទេក្នុងរឿងនេះ ។ កុមារដែលបានបញ្ចប់មធ្យមសិក្សា មានហានិភ័យក្លាយជាអ្នកក្រទាបជាងកុមារដែលបានបញ្ចប់ត្រឹមតែបឋមសិក្សា ។ កុមារដែលធ្វើការ មានហានិភ័យកំរិតទាបក្លាយជាអ្នកក្រ ពីព្រោះចំណូលរបស់ពួកគេជួយកែលំអសុខុមាលភាពគ្រួសារ ប៉ុន្តែរឿងនេះពុំមានចីរភាពល្អទេ ប្រសិនបើម៉ោងធ្វើការរបស់ពួកគេមិនល្អប្រសើរ ។កុមារដែលរៀបការនៅវ័យក្មេងពេក មានហានិភ័យក្លាយជាអ្នកក្រ ខ្ពស់ជាងកុមារមិនទាន់រៀបការ ។ កុមារក្នុងគ្រួសារមានមេគ្រួបានរៀនចប់មធ្យមសិក្សា ឬកំរិតខ្ពស់ជាងនេះ មានហានិភ័យក្លាយជាអ្នកក្រ ទាបជាងកុមារក្នុងគ្រួសារដែលមេគ្រួមិនបានរៀនចប់មធ្យមសិក្សា ។ គ្រួសារធូរធារ មានចំណាយគ្រួសារគិតក្នុងមនុស្សម្នាក់

---

២ តំបន់ភ្នំ/ខ្ពង់រាប គ្របដណ្ដប់លើខេត្តកំពង់ស្ពឺ ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និង ក្រចេះ ។ តំបន់បឹងទន្លេសាប គ្របដណ្ដប់លើខេត្តកំពង់ឆ្នាំង កំពង់ធំ សៀមរាប បន្ទាយមានជ័យ និង បាត់ដំបង ។ រីឯតំបន់វាលទំនាប គ្របដណ្ដប់លើ ក្រុងភ្នំពេញ ខេត្តកណ្ដាល កំពង់ចាម ស្វាយរៀង ព្រៃវែង និង តាកែវ ។

៣ តួលេខដែលគិតជាភាគរយនៃខ្សែបន្ទាត់ភាពក្រីក្រនេះ បញ្ជាក់ថា តើក្រុមគ្រួសារស្ថិតនៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ ឆ្ងាយប៉ុណ្ណា ។

៤ តួលេខនេះបញ្ជាក់ពី ភាគរយនៃអ្នកក្រីក្រធ្ងន់ធ្ងរក្នុងចំណោមអ្នកក្រទាំងអស់ ។

៥ ខ្សែបន្ទាត់ភាពក្រីក្រកំណត់ឡើង តាមការគណនាពីតំលៃនៃតំរូវការជាមូលដ្ឋាននូវអាហារ និងសំភារៈមិនមែនអាហារ ដោយប្រើ វិធីសាស្ត្រតំលៃនៃតំរូវការជាមូលដ្ឋាន (Cost of Basics Method)

លើការអប់រំនិងការថែទាំសុខភាពកូនៗ ច្រើនជាងគ្រួសារក្រីក្រ ។ ឧបត្ថម្ភធនខាងការថែទាំសុខភាព[6] ដូចជា ការលើកលែងលើការបង់ថ្លៃប្រើប្រាស់សេវា និងមូលនិធិសមធម៌ផ្នែកសុខភាពជាដើម មានសារៈសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ កត្តាជនជាតិ និងចរិកលក្ខណៈសហគមន៍ មានការពាក់ព័ន្ធច្រើនដល់ភាពក្រីក្ររបស់កុមារ ប៉ុន្តែ កង្វះទឹក មិនពាក់ព័ន្ធទេ ។

### *សុខុមាលភាពរបស់កុមារ*

គោលនយោបាយ ផែនការ និងកម្មវិធីថ្នាក់ជាតិជាច្រើន បានដោះស្រាយដោយចំហ និងមិនចំហ នូវតំរូវការទាំង ៥យ៉ាង របស់កុមារ ។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-១០ គឺជាចំលើយតបរបស់ជាតិ ចំពោះតំរូវការផ្សេងៗរបស់កុមារក្រៅពីការគាំពារខាងសង្គមកិច្ច ។

សេចក្ដីព្រាងយុទ្ធសាស្ត្រអាហារូបត្ថម្ភជាតិ យុទ្ធសាស្ត្រដើម្បីការរស់រានរបស់កុមារឆ្នាំ២០០៦ និងកម្មវិធីពាក់ព័ន្ធផ្សេងៗ កម្មវិធីអាហារូបត្ថម្ភជាតិ និងកម្មវិធីជាតិផ្ដល់ថ្នាំបង្ការ មានសារៈសំខាន់បំផុតសំរាប់ អាហារូបត្ថម្ភ និងសុខភាពរបស់កុមារ ។ ច្បាប់ស្ដីពីការអប់រំ គោលនយោបាយសាលារៀនអំណោយផលដល់កុមារ (ឆ្នាំ២០០៧), ផែនការជាតិនៃការអប់រំសំរាប់ទាំងអស់គ្នា (២០០៣-២០១៥), ផែនការយុទ្ធសាស្ត្រខាងអប់រំ ឆ្នាំ២០០៦-២០១០ និង កម្មវិធីទ្រទ្រង់ដល់វិស័យអប់រំឆ្នាំ២០០៦-២០១០ បានជួយដោះស្រាយដោយផ្ទាល់នូវ ការអប់រំរបស់កុមារ ។

មានច្បាប់ ផែនការ និងកម្មវិធីជាច្រើនទៀតសំរាប់ជួយការពារកុមារដែរ ហើយបានជះឥទ្ធិពលដោយប្រយោល ទៅលើស្ថានភាពក្រីក្ររបស់ពួកគេ ដូចជា ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៦-២០១០ ច្បាប់ការងារឆ្នាំ១៩៩៧ សេចក្ដីព្រាងផែនការជាតិបង្ក្រាបការជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ផែនការជាតិស្ដីពីសកម្មភាពចំពោះពលកម្មកុមារមិនសមស្របឆ្នាំ២០០៨-២០១២, ផែនការជាតិស្ដីពីសកម្មភាពចំពោះកុមារកំព្រា កុមារមានផ្ទុកមេរោគអេដស៍ និងកុមារងាយទទួលរងគ្រោះនានានៅកម្ពុជាឆ្នាំ២០០៨-២០១០ ។ ច្បាប់ស្ដីពីប្រព័ន្ធសន្តិសុខសង្គមឆ្នាំ២០០៤ ក៏ពាក់ព័ន្ធនឹងការគាំពារសង្គមដែរ ។

### *អាហារូបត្ថម្ភ*

ការក្រិនកំពស់ ការចុះស្គម/ខ្សោយជាបន្តបន្ទាប់ និង ទម្ងន់មិនគ្រប់ គេតែងសង្កេតឃើញជារឿយៗក្នុងចំណោមកុមារទាំងពីរភេទអាយុពី១៨-២៣ខែ ។ ចំពោះកុមារក្រីក្របំផុត អត្រាសំរាប់បញ្ហាសុខភាពទាំងបីខាងលើ គឺ ៤៦,៧%, ៨,៣% និង ៤២,៩% ធៀបនឹង ១៩,៤%, ៦,៧% និង ៣២,១% ចំពោះកុមារធូធារបំផុត ។ កុមារដែលមាតាគ្មាន ឬមានការអប់រំទាបជាងកំរិតមធ្យមសិក្សា គឺមានអត្រាក្រិនកំពស់ ៤៥,៨% និងអត្រាទម្ងន់មិនគ្រប់ ៤៣,៥% ធៀបនឹង ២២,២% និង ២៥,១% សំរាប់កុមារដែលមាតាមានការអប់រំកំរិតមធ្យមសិក្សា ឬខ្ពស់ជាង ។ សន្ទស្សន៍ម៉ាសរាងកាយ (body mass index: BMI) របស់មាតា ក៏មានទំនាក់ទំនងនឹងស្ថានភាពអាហារូបត្ថម្ភរបស់កុមារដែរ ហើយ BMI ទាបជាង ១៨,៥% អាចបង្ក ការចុះស្គម/ខ្សោយជាបន្តបន្ទាប់ ការក្រិនកំពស់ និង បញ្ហាទម្ងន់មិនគ្រប់ ដល់កុមារ ។ កុមារនៅតំបន់ជនបទ មានអត្រាក្រិនកំពស់ ៣០,៥% អត្រាចុះស្គម/ខ្សោយជាបន្តបន្ទាប់ ៨,៣% និង អត្រាទំងន់មិនគ្រប់ ៣៤,៧% ហើយកុមារនៅទីក្រុងមានអត្រា ៣០,៥% ៧,១% និង ៣៥,៧% ។ កុមារនៅខេត្តពោធិ៍សាត់ មានស្ថានភាពអាហារូបត្ថម្ភយ៉ាប់យ៉ឺនជាងគេក្នុងប្រទេសកម្ពុជា រីឯកុមារនៅក្រុងភ្នំពេញមាន ស្ថានភាពអាហារូបត្ថម្ភប្រសើរជាងគេ ។

### *សុខភាព*

អត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំ និង អត្រាមរណៈរបស់ទារក ខុសប្លែកគ្នាជាខ្លាំង រវាង កុមារា និង កុមារី ប៉ុន្តែចំពោះសូចនាករដទៃទៀតវិញ កត្តាយេនឌ័រនេះគ្មានឥទ្ធិពលអ្វីច្រើនទេ ។ អត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំ និង អត្រាមរណៈរបស់ទារក គឺ ១២៧ និង ១០១ ក្នុង ១០០០កំណើតរស់ ក្នុងចំណោមកុមារក្រីក្របំផុត ធៀបនឹង ៤៣ និង ៣៤ ក្នុង ១០០០កំណើតរស់ ក្នុងចំណោមកុមារធូរធារបំផុត ។ អត្រាជំងឺរាគរូស និង ជំងឺឆ្លងតាមផ្លូវដង្ហើមធ្ងន់ធ្ងរ ក៏ខុសប្លែកគ្នាខ្លាំងរវាង កុមារក្រីក្រ និងកុមារធូរធារ ។ អត្រាមរណៈរបស់កុមារក្រោមអាយុ៥ឆ្នាំ និង អត្រាមរណៈរបស់ទារក ដែលមានម្ដាយបានសិក្សាបញ្ចប់ថ្នាក់មធ្យមសិក្សា ឬ ថ្នាក់ខ្ពស់ជាងនេះ មានកំរិតទាបជាង កុមារមានម្ដាយបានទទួលការអប់រំតិចតួច ប៉ុន្តែសំរាប់អត្រាជំងឺគ្រុនក្ដៅវិញ គ្មានអ្វីខុសគ្នាច្រើនទេរវាងកុមារទាំងពីរក្រុម ។ អត្រាជំងឺឆ្លងតាមផ្លូវដង្ហើម ជំងឺរាគរូស ជំងឺគ្រុនក្ដៅ និង មរណភាព តែងមានកំរិតខ្ពស់ជាងសំរាប់កុមារនៅជនបទ ។ ខេត្តរតនគិរី និងមណ្ឌលគិរីរួមបញ្ចូលគ្នា មានអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំ និង អត្រាមរណៈរបស់ទារក ខ្ពស់ជាងគេ គឺ ១៦៥/១០០០ និង ១២២/១០០០ នៃកំណើតរស់ ហើយក្រុងភ្នំពេញមានអត្រាទាបជាងគេ គឺ ៥២/១០០០ និង ៤២/១០០០ នៃកំណើតរស់ ។

### *ការអប់រំ*

ការអប់រំរបស់កុមារ ប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ និងសុខភាពរបស់កុមារ ប៉ុន្តែមិនប្រែប្រួលទៅតាមយេនឌ័រទេ ។ អត្រាចុះឈ្មោះចូលរៀនបឋមសិក្សា គ្មានការខុសប្លែកគ្នាខ្លាំងទេរវាងតំបន់ជនបទ និងទីក្រុង ប៉ុន្តែខុសគ្នាជាខ្លាំងរវាងតំបន់ដាច់ស្រយាល និង តំបន់ទីក្រុងឬតំបន់ជនបទ ។ គេសង្កេតឃើញថា ខេត្តកណ្ដាល មានអត្រាចុះឈ្មោះចូលរៀនសុទ្ធនៅបឋមសិក្សាខ្ពស់ជាងគេ (៩៨,២%) រីឯខេត្តរតនគិរីមាន អត្រានេះទាបជាងគេ (៧៧%) ។ ក្រុងភ្នំពេញ មានអត្រាសិស្សចុះឈ្មោះចូលរៀនសុទ្ធនៅមធ្យមសិក្សាកំរិត១ ខ្ពស់ជាងគេ (៦៨,៧%) រីឯ ខេត្តមណ្ឌលគិរី មានអត្រាទាបជាងគេ (១១,៤%) ។ ចំពោះការចុះឈ្មោះចូលរៀនសុទ្ធនៅមធ្យមសិក្សាកំរិត២វិញ ក្រុងភ្នំពេញមានអត្រាខ្ពស់ជាងគេ (៥២,៩%) រីឯខេត្តឧត្តរមានជ័យមានអត្រាទាបជាងគេ (៣,១%) ។ ខេត្តតាកែវ មានអត្រាសិស្សបន្តការសិក្សាពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ខ្ពស់ជាងគេ (៧៥%) ហើយខេត្តកោះកុង

---

៦ ចំណាយសាធារណៈទៅលើការថែទាំសុខភាពក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំ

មានអត្រាទាបជាងគេ (៣៨,៤%) ។ អត្រាចុះឈ្មោះចូលរៀនបឋមសិក្សា និង ចូលរៀនមធ្យមសិក្សា មានភាពខុសគ្នាខ្លាំង រវាងកុមារធូរធារ និង កុមារក្រីក្រ ។

### ការគាំពារ

មានមូលហេតុជាច្រើនដែលជំរុញឱ្យឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ អនុញ្ញាតឱ្យពួកគេចូលធ្វើការ ។ ក្នុងចំណោមមូលហេតុ ៩ប្រភេទធំៗ មានតែ ២ប្រភេទប៉ុណ្ណោះដែលលេចធ្លោជាងគេ គឺ ការពុំមានកម្មវិធីបណ្តុះបណ្តាល និងកម្មវិធីអប់រំដែលសមស្រប (៧,៣%) និង ការទទួលបានបទពិសោធន៍ (៣,៩%) ។ ដោយឡែកកត្តាភាពក្រីក្រក្នុងគ្រួសាររួមចំនែកត្រឹមតែ ០,២% ហើយកត្តាឯទៀតរួមចំនែក ៨៤,៦% ។ លទ្ធផលនៃការស្រាវជ្រាវមិនសូវរឹងប៉ឹងប៉ុន្មានទេ គឺមូលហេតុចំបងអាចគេក្លាប់វាមិនបានល្អ រឺមួយមិនបានពិចារណាទាញការសន្និដ្ឋានឱ្យបានសមស្រប (វិទ្យាស្ថានជាតិស្ថិតិ និងអង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០០២) ។

យោងតាម អង្កេតពីសុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ២០០៥ យុវជន/នារីដែលរៀបការលើកដំបូង មានអាយុមធ្យម (មេដ្យាន) នៅក្មេង គឺ ២០,១ឆ្នាំសំរាប់នារី និង ២១,៨ឆ្នាំសំរាប់បុរស ។ នៅទីជនបទ អាយុមេដ្យាននៃការរៀបការលើកទី១ គឺ ២០ឆ្នាំ ចំពោះនារី និង ២១,៥ឆ្នាំ ចំពោះបុរស ហើយនៅទីក្រុង គឺ ២០,៧ឆ្នាំសំរាប់នារី និង ២៣,៩ឆ្នាំសំរាប់បុរស ។ អាយុមេដ្យាននៃការរៀបការលើកដំបូងនៃនារីរស់នៅទីក្រុង និងជនបទ បានថយចុះជាបន្តបន្ទាប់ ។គិតទូទាំងប្រទេសសំរាប់ស្ត្រីដែលសព្វថ្ងៃមានអាយុ ៤៥-៤៩ឆ្នាំ អាយុមេដ្យានកាលពីជំនាន់ពួកគាត់រៀបការលើកទី១ គឺ ២០,៤ឆ្នាំ ធៀបនឹង ២០,១ឆ្នាំ សំរាប់ ស្ត្រីសព្វថ្ងៃ មានអាយុ ២៥-២៩ឆ្នាំ ។

វិទ្យាស្ថានជាតិសុខភាពសាធារណៈ (ឆ្នាំ២០០៦) បានបង្ហាញថា ភាគរយនៃកុមារដែលបានចុះបញ្ជីកំណើត ប្រែប្រួលទៅតាមអាយុ ស្ថានភាពទ្រព្យសម្បត្តិគ្រួសារ និងទីតាំងដែលពួកគេរស់នៅ ។ សមាមាត្រកុមារអាយុ ២-៤ឆ្នាំដែលបានចុះបញ្ជីកំណើត គឺ ៧៣,៩% រីឯកុមារអាយុតិចជាង ២ឆ្នាំ គឺ ៥៥,៧% ។ កុមារនៅទីក្រុង មានអត្រាចុះបញ្ជីកំណើត ខ្ពស់ជាងកុមារនៅជនបទ ។ ខេត្តកណ្តាល មានអត្រាកុមារចុះបញ្ជីកំណើតខ្ពស់ជាងគេ រីឯខេត្តពោធិ៍សាត់មានអត្រានេះទាបជាងគេ ។ កុមារក្នុងក្រុមគ្រួសារធូរធារបំផុត មានអត្រាចុះបញ្ជីកំណើត ខ្ពស់ជាងកុមារក្នុងក្រុមគ្រួសារក្រីក្របំផុត (៧៦,៥% ធៀបនឹង ៥៩,៣%) ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា និង អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ (ឆ្នាំ២០០៨) បានរាយការណ៍ថា សមាមាត្រកុមារកំព្រាប្រែប្រួលតិចតួចណាស់ពីឆ្នាំ២០០០-២០០៥ (៧,៦% ធៀបនឹង ៧,៤%) ។ ប៉ុន្តែចំនួនកុមារកំព្រា បានកើនឡើងពី ៥៧៥១នាក់នៅឆ្នាំ២០០៥ ដល់ ៦៦១៦នាក់នៅឆ្នាំ២០០៦ និង ៨៦៦៤នាក់នៅឆ្នាំ២០០៧ ។ វិទ្យាស្ថានជាតិសុខភាពសាធារណៈ (ឆ្នាំ២០០៦) រកឃើញថា ខេត្តឧត្តរមានជ័យ មានសមាមាត្រកុមារកំព្រាកំរិតខ្ពស់ជាងគេ (១៣,៥%) បន្ទាប់មកគឺ ខេត្តបាត់ដំបង/ប៉ៃលិន និងខេត្តសៀមរាប ហើយខេត្តក្រចេះមានសមាមាត្រនេះទាបជាងគេបំផុត (៦,៥%) ។ សមាមាត្រកុមារកំព្រាមានកំរិត ៨,០% សំរាប់គ្រួសារធូរធារ និង ១០,៦% សំរាប់គ្រួសារក្រីក្របំផុត ។

### ការគាំពារសង្គម

នៅឆ្នាំ២០០៤ កម្ពុជាបានអនុម័ត ច្បាប់ស្តីពីប្រព័ន្ធសន្តិសុខសង្គម ដែលមានសេចក្តីចែងអំពី ប្រាក់ឧបត្ថម្ភសំរាប់វ័យជរា ប្រាក់អត្ថប្រយោជន៍ដល់ជនរស់រានជីវិត ប្រាក់ឧបត្ថម្ភសំរាប់ការរងរបួសដោយការងារ និង ប្រាក់ឧបត្ថម្ភលើជំងឺពាក់ព័ន្ធនឹងវិជ្ជាជីវៈ ។ នាពេលបច្ចុប្បន្ន មានប្រព័ន្ធមួយចំនួនតូចប៉ុណ្ណោះ ដូចជា ការលើកលែងការបង់ថ្លៃព្យាបាលផ្លូវការ មូលនិធិសមធម៌ផ្នែកសុខភាព ការធានារ៉ាប់រងសុខភាពសង្គម និង ការធានារ៉ាប់រងសុខភាពផ្អែកលើសហគមន៍ជាដើម ដែលកំពុងអនុវត្តនៅតាមតំបន់មួយចំនួននៅកម្ពុជា ។

ការលើកលែងការបង់ថ្លៃព្យាបាលដែលបានណែនាំឡើងនៅឆ្នាំ១៩៨៦ កំពុងដាក់អនុវត្តនៅតាម ៧៧៩មណ្ឌលសុខភាព ៦៩មន្ទីរពេទ្យបង្អែក ៦មន្ទីរពេទ្យជាតិ និង ៣ស្ថាប័នថែទាំសុខភាពថ្នាក់មធ្យម ។ លទ្ធភាពបានប្រើប្រព័ន្ធទាំងនេះ ប្រែប្រួលទៅតាមក្រុមកំរិតប្រាក់ចំណូល ហើយថ្លៃព្យាបាលនៅតែជាឧបសគ្គចំបងសំរាប់ជនក្រីក្រ ទោះបីមានការព្យាបាលជំងឺដោយមិនយកថ្លៃលើ ១,៣លានករណី និងមនុស្ស ៦៥.០១៣នាក់ នៅឆ្នាំ២០០៧ ដែលក្នុងនេះ ៨៩% ធ្វើឡើងដោយមណ្ឌលសុខភាព ៩% ដោយមន្ទីរពេទ្យបង្អែក និង ១% ដោយស្ថាប័នមធ្យមក្តី (ការិយាល័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចផ្នែកសុខភាព ឆ្នាំ២០០៨) ។

មូលនិធិសមធម៌ផ្នែកសុខភាព គឺជាការផ្តួចផ្តើមគំនិតថ្មីមួយផ្តល់មូលនិធិដោយអ្នកផ្តល់ជំនួយផ្សេងៗ និងរដ្ឋាភិបាល ដើម្បីជួយចេញថ្លៃថែទាំសុខភាពឱ្យជនក្រីក្រដែលទទួលការព្យាបាលជំងឺដោយឥតគិតថ្លៃ ឬដោយបញ្ចុះថ្លៃ នៅតាមកន្លែងថែទាំសុខភាពសាធារណៈមួយចំនួន ។ បច្ចុប្បន្នក្រសួងសុខាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន កំពុងធ្វើវិមជ្ឈការមូលនិធិនេះទៅឱ្យស្រុកប្រតិបត្តិ (operational districts) ។ មូលនិធិនេះក៏ជួយចេញឱ្យដែរនូវថ្លៃធ្វើដំណើរ និងថ្លៃម្ហូបអាហារក្នុងពេលកំពុងព្យាបាល (ការិយាល័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចផ្នែកសុខភាព ឆ្នាំ២០០៨) ។ មកទល់សព្វថ្ងៃ មូលនិធិសមធម៌ផ្នែកសុខភាពនេះ មានអនុវត្តនៅក្នុង ៣៩ស្រុកប្រតិបត្តិ និង ៩មន្ទីរពេទ្យនៅទូទាំងប្រទេស ។

ប្រព័ន្ធធានារ៉ាប់រងសហគមន៍ ដែលផ្អែកលើការដាក់ហានិភ័យរួមជាមួយគ្នា និងការបង់ប្រាក់ជាមុនលើ ការថែទាំសុខភាព បច្ចុប្បន្នកំពុងអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិមួយចំនួន នៅតាម ៩ស្រុកប្រតិបត្តិ ដែលមានអ្នកទទួលផលចំនួន ៤២.២៨២នាក់ (ការិយាល័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចផ្នែកសុខភាព ឆ្នាំ២០០៨) ។ អង្គការទាំងនោះលក់ប័ណ្ណធានារ៉ាប់រងមានតំលៃថោកដែលផ្តល់អត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រមួយចំនួនជាក់លាក់ ។

## ៥. សេចក្តីសន្និដ្ឋាន និង ផលប៉ះពាល់ខាងគោលនយោបាយ

ទ្រព្យសម្បត្តិគ្រួសារ (បង្ហាញដោយ ចំណាយគិតក្នុងមនុស្សម្នាក់របស់គ្រួសារទៅលើផ្នែកសុខភាព និងការអប់រំកូនៗ, ការសិក្សារបស់មេគ្រួសារ, ទំហំគ្រួសារ, អាយុកុមារ, ការសិក្សារបស់កុមារ, ការរៀបការនៅវ័យក្មេង,

ចំនួនម៉ោងការងាររបស់កុមារ, លទ្ធភាពបានប្រើប្រាស់ទឹក ជំរក និងបង្គន់អនាម័យ, ជនជាតិ, លក្ខណៈសហគមន៍, ទីតាំងភូមិសាស្ត្រ និងឧបត្ថម្ភធនខាងសុខភាព ទាំងអស់នេះគឺជាកត្តាកំនត់ភាពក្រីក្ររបស់គ្រួសារ និងរបស់កុមារ ។

កុមារក្រីក្រភាគច្រើន កំពុងរស់ក្នុងគ្រួសារមានសមាជិកយ៉ាងច្រើន នៅតាមតំបន់ជនបទ ជាពិសេសនៅតំបន់ខ្ពង់រាប/តំបន់ភ្នំ និងតំបន់ទន្លេសាប ។ ខេត្តរតនគិរី មណ្ឌលគិរី និង ឧត្តរមានជ័យ ទំនងជាខេត្តដែលមានសេវាអប់រំទន់ខ្សោយជាងគេ ។ ម្យ៉ាងទៀតខេត្តកំពង់ចាម កណ្តាល តាកែវ និងបន្ទាយមានជ័យ ហាក់ដូចជាមានអត្រាពលកម្មកុមារកំរិតខ្ពស់ ដូច្នេះហើយគោលដៅផ្សេងៗខាងការអប់រំ និងពលកម្មកុមារ ប្រហែលមិនអាចសំរេចបានទេ ។

ការសិក្សានេះបានផ្តល់ជាមតិខាងគោលនយោបាយជាច្រើន ដែលអាចសង្ខេបបានដូចខាងក្រោមៈ

កង្វះអាហារូបត្ថម្ភ ឃើញមានភាគច្រើនក្នុងចំណោមកុមារនៅតំបន់ជនបទ ជាពិសេសខេត្តពោធិ៍សាត់ មណ្ឌលគិរី និង រតនគិរី ។ ជាការចាំបាច់ណាស់ដែលកម្មវិធីផ្តល់អាហារូបត្ថម្ភត្រូវប្រឹងប្រែងថែមទៀត ពិសេសសំរាប់កុមារអាយុ ១២-១៧ខែ ពីព្រោះរោគសញ្ញានៃការក្រិនកំពស់ ការចុះស្គម/ខ្សោយ និង ទំងន់មិនគ្រប់ តែងលេចឡើងចំពោះកុមារក្នុងក្រុមអាយុនេះ ។ កម្មវិធីអប់រំមាតាស្តីពីអាហារូបត្ថម្ភកុមារ និងស្ត្រីមានផ្ទៃពោះ គួរអនុវត្តឡើង ដើម្បីជួយទ្រទ្រង់ដល់អ្នករស់នៅតំបន់ជនបទ និងមានការអប់រំទាបជាងកំរិតមធ្យមសិក្សា ។ តួនាទីរបស់ឪពុក ក៏គួរលើកឡើងផងដែរនៅក្នុងកម្មវិធីអាហារូបត្ថម្ភកំរិតជាតិ ។

កម្មវិធីផ្នែកសុខភាព គួរប្រឹងប្រែងថែមទៀតសំរាប់កុមារនៅទីជនបទ ជាពិសេសនៅខេត្តមណ្ឌលគិរី និងរតនគិរី ដែលមានអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំ និងអត្រាមរណៈរបស់ទារកខ្ពស់ជាងគេ ។ កម្មវិធីនេះក៏គួរផ្តល់អាទិភាពដល់ខេត្តកំពង់ចាម កំពង់ធំ និងឧត្តរមានជ័យផងដែរ ព្រោះខេត្តទាំងនេះមានអត្រាកើតជំងឺគ្រុនក្តៅ ជំងឺរាគរូស និងជំងឺឆ្លងតាមផ្លូវដង្ហើម ខ្ពស់ជាងគេ ។ ត្រូវប្រឹងប្រែងថែមទៀតផ្តោតលើកុមារអាយុ ៦-១១ខែ ព្រោះអត្រាជំងឺឆ្លងតាមផ្លូវដង្ហើម ជំងឺគ្រុនក្តៅ និងជំងឺរាគមានកំរិតខ្ពស់ក្នុងក្រុមអាយុនេះ ។ កម្មវិធីអប់រំមាតា ស្តីពីការថែទាំសុខភាពកុមារ គួរផ្តោតលើខេត្តទាំងអស់នេះ ។ កម្មវិធីថែទាំសុខភាពផ្អែកលើសហគមន៍នៅទីជនបទ ជាពិសេសនៅខេត្តរតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ និងកំពង់ធំ គួរជំរុញថែមទៀត ដើម្បីបង្កើនតំរូវការសេវាថែទាំសុខភាពកុមារ ជាពិសេសដោយសារគ្រួសារនានាមានចំណេះដឹង និងចំណាប់អារម្មណ៍ទាបពីរឿងនេះ ។ ឆ្មប និងបុគ្គលិកសុខាភិបាល គួរតែមានការបណ្តុះបណ្តាល ការដាក់ពង្រាយ ការផ្តល់ប្បៀវត្សរ៍ និងការត្រួតពិនិត្យ ។

កម្មវិធីអប់រំ គួរផ្តោតខ្លាំងថែមទៀតលើថ្នាក់មធ្យមសិក្សាកំរិត១ និងកំរិត២ ពីព្រោះមានអត្រាសិស្សឈប់រៀនខ្ពស់ ជាពិសេសនៅតំបន់ដាច់ស្រយាល ពីព្រោះមានអត្រាចុះឈ្មោះចូលរៀនសុទ្ធនៅគ្រប់កំរិត ទាបជាងតំបន់ទីក្រុង និងតំបន់ជនបទយ៉ាងច្រើន ។ ខេត្តរតនគិរី មណ្ឌលគិរី ឧត្តរមានជ័យ និងកោះកុង មានអត្រាចុះឈ្មោះចូលរៀនសុទ្ធ ទាបជាងគេនៅកម្ពុជា ។ គេគួរជ្រើសរើស និងដាក់ពង្រាយគ្រូបង្រៀនមានគុណភាពល្អច្រើននាក់ទៀតនៅ តំបន់ជនបទដាច់ស្រយាល ជាពិសេសសហគមន៍ក្រីក្របំផុត ។ ប្រាក់លើកទឹកចិត្តពិសេស គួរផ្តល់ទៅដល់គ្រូៗមានគុណភាពល្អទាំងឡាយដែលស្ម័គ្រចិត្តទៅបង្រៀននៅតំបន់ដាច់ស្រយាល ។ ខេត្តប៉ៃលិន សៀមរាប រតនគិរី និងឧត្តរមានជ័យ មានអត្រាសិស្សធៀបនឹងគ្រូបង្រៀនខ្ពស់បំផុត ។

កម្មវិធីគាំពារ គួរផ្តោតការប្រឹងប្រែងថែមទៀតលើកុមារាកំពុងធ្វើការដែលមានអាយុ ១០-១៤ឆ្នាំ និងជាពិសេស កុមារាអាយុ ១៥-១៧ឆ្នាំ ដែលពួកនិយោជកត្រូវការច្រើនជាងគេ ។ ខេត្តកំពង់ចាម កណ្តាល តាកែវ និងបន្ទាយមានជ័យ មានអត្រាកុមារកំពុងធ្វើការខ្ពស់ជាងគេ ។ ការតស៊ូមតិទ្រទ្រង់សិទ្ធិកុមារ និង ការពង្រឹងអនុវត្តន៍ច្បាប់ពលកម្ម គួរផ្តោតលើក្រុងភ្នំពេញដែលមានកុមារជាច្រើន កំពុងដំណើរការគ្រឿងចក្រក្នុងបរិយាកាសមិនល្អ ត្រូវទទួលរងការរំលោភបំពានខាងផ្លូវកាយ និងផ្លូវចិត្ត និងទទួលបានប្រាក់កំរៃទាប ( វិទ្យាស្ថានជាតិស្ថិតិ និង អង្គការពលកម្មអន្តរជាតិ ឆ្នាំ២០០២) ។ គេគួរធ្វើអង្កេតពីពលកម្មកុមារថ្មីមួយទៀត ពីព្រោះអង្កេតលើកទីមួយ បានធ្វើឡើង ៨ឆ្នាំហើយ មកទល់នឹងពេលនេះ ។ ទិន្នន័យមានស្រាប់បានបង្ហាញថា អាពាហ៍ពិពាហ៍របស់នារីក្នុងវ័យក្មេងខ្ចី គឺក្រុមគ្រួសាររបស់ពួកនាងជាអ្នកសំរេចចាត់ចែង ដូច្នេះត្រូវមាន កម្មវិធីគាំពារផ្សេងៗដើម្បីតស៊ូមតិ និងការពារសិទ្ធិកុមារ ។ ទិន្នន័យបានបង្ហាញទៀតថា មូលហេតុចំបងនៃការក្លាយជាកុមារកំព្រា គឺ អត្រាខ្ពស់នៃបុរសមានជំងឺអេដស៍ ជំងឺផ្សេងៗទៀត ការរងរបួស និងអំពើហិង្សា ។ ដូច្នេះត្រូវបំផុសការយល់ដឹងជាសាធារណៈពី មូលហេតុនៃការរងរបួស និងការពង្រឹងអនុវត្តន៍ច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ នៅតាមតំបន់ដែលមានអត្រាអំពើហិង្សាខ្ពស់ ។

មូលនិធិសមធម៌ផ្នែកសុខភាព និងការធានារ៉ាប់រងសុខភាពផ្អែកលើសហគមន៍ គួរពង្រីកឱ្យបានទូទាំងប្រទេស និងគួរផ្តល់អាទិភាពដល់តំបន់ជនបទនានាដែលមានអត្រាកុមារក្រីក្រកំរិតខ្ពស់ ។

## ឯកសារយោង


Bureau of Health Economics and Financing (2008), *Annual Health Financing Report 2007* (Phnom Penh: Department of Planning and Health Information, Ministry of Health)

Ministry of Social Affairs, Veterans and Youth Rehabilitation & National Aids Authority (2008), *Orphans, Children Affected by HIV and Other Vulnerable Children in Cambodia: A Situation and Response Assessment 2007*. (Phnom Penh: National Muilti-Sectoral Orphans and Vulnerable Children Task Force)

National Institute of Public Health, National Institute of Statistics & ORC Macro (2006), *Cambodia Demographic and Health Survey 2005* (Phnom Penh: NIS, Ministry of Planning)

National Institute of Statistics & International Labour Organisation (2002), *Cambodia Child Labour Survey 2001* (Phnom Penh: NIS, Ministry of Planning)

UNICEF (2004), *The State of the World's Children 2005—Childhood under Threat* (New York: UNICEF)

UNICEF (2007), *Global Study on Child Poverty and Disparity 2007–2008 Guide* (New York: Global Policy Section, Division of Policy and Planning, UNICEF)

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីស្ថានភាពសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ីខាងកើត នៅត្រីមាសទី៣ ឆ្នាំ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៨ ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក កើន 0,៥% ដែលបង្ហាញពីការធ្លាក់ចុះកំនើនយ៉ាងខ្លាំង ។ ការធ្លាក់ចុះនេះបណ្តាលមកពីការរួមចំនែកអវិជ្ជមាននៃចំនាយប្រើប្រាស់ផ្ទាល់ខ្លួន (៣,៨%), វិនិយោគលើទ្រព្យសកម្មជាប់លាប់ និងលើគ្រឿងបរិក្ខារនិងសូហ្វវែរ ។ កំណើនសេដ្ឋកិច្ចយឺតក៏មានជាក់ស្តែងនៅតំបន់អឺរ៉ូដែរ ដោយកំនើន ផសស ប្រចាំឆ្នាំធ្លាក់ចុះមកត្រឹម 0,៦% នៅត្រីមាសនេះ ។ ការចុះខ្សោយនៃការនាំចេញសុទ្ធ និងចំណាយវិនិយោគ ជាឧបសគ្គចំបងដល់កំនើនសេដ្ឋកិច្ច ។ ក្នុងត្រីមាសនេះដែរ កំនើន ផសស ពិតនៅជប៉ុន មានតួលេខធ្លាក់ទាបបំផុតដល់ -0,៥% ដែលបញ្ជាក់ពីការធ្លាក់ចុះសេដ្ឋកិច្ចយ៉ាងខ្លាំង ។ មូលហេតុចំបងនៃការធ្លាក់ចុះបែបនេះ គឺ ការថយចុះតំរូវការពីប្រទេសក្រៅ ដែលបណ្តាលឱ្យមានការកាត់បន្ថយ វិនិយោគ និងផលិតកម្មរបស់ក្រុមហ៊ុន ។

នៅត្រីមាសទី៣ នេះដែរ កំនើន ផសស ពិតនៅចិន បន្តថយចុះមកត្រឹម ៩% ដែលជាកំនើនយឺតបំផុត គិតចាប់ពីត្រីមាសទី២ ឆ្នាំ២០០៣ ។ ការធ្លាក់ចុះក្នុងផ្នែកនាំចេញដែលជាសសរទ្រូដ៏សំខាន់មួយនៃការលូតលាស់ វាផុសចេញពីការធ្លាក់ចុះសេដ្ឋកិច្ច និងការរីករវ៉ផ្នែកហិរញ្ញវត្ថុនៅលើពិភពលោក ហើយវាជាកត្តាដ៏សំខាន់ដែលនាំឱ្យមានការលូតលាស់យឺតនេះ ។ ផសស ពិតសរុបនៅកូរ៉េខាងត្បូងកើនឡើងយឺតបានត្រឹម ៣,៨% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការរួមចុះក្នុងឧស្សាហកម្មផលិតកម្មដូចជា ការផលិតរថយន្ត អង្គធាតុពាក់កណ្តាលចំលង និងកុំព្យូទ័រ ។ កំនើន ផសស ពិតរយៈពេល ១២ខែ របស់ហុងកុង និង តៃវ៉ាន់ ធ្លាក់ចុះយ៉ាងខ្លាំងពី ៤,២% និង ៤,៣% នៅត្រីមាសទី២ មកត្រឹម ១,៧% និង -១,0% នៅត្រីមាសទី៣ ។ ការប្រែប្រួលកំនើន ផសស នៅហុងកុងបណ្តាលមកពីការធ្លាក់ចុះក្នុងផ្នែកនាំចេញ និងតំរូវការក្នុងស្រុក រីឯការធ្លាក់ចុះនៅតៃវ៉ាន់ គឺមកពី ការថយចុះតំរូវការក្នុងស្រុក និងការថយចុះយ៉ាងខ្លាំងនៃការនាំចេញ ។

នៅត្រីមាសទី៣ ឆ្នាំ២០០៨ កំនើន ផសស ពិតប្រចាំឆ្នាំនៅម៉ាឡេស៊ី គឺ ៤,៧% ធៀបនឹង ៦,៣% នៅត្រីមាសមុន ។ ការថយចុះនេះ បណ្តាលមកពីការលូតលាស់យឺតក្នុងវិស័យកសិកម្ម រ៉ែ និងផលិតកម្ម ។កំនើន ផសស ពិតនៅសិង្ហបុរី ក្នុងរយៈពេល១២ខែមុនបានរួមចុះអស់ ២ត្រីមាសជាបន្តបន្ទាប់ មកត្រឹម -0,៦% ដែលបង្កមកពី កំនើនអវិជ្ជមានក្នុងវិស័យផលិតកម្ម (-១១,៤%) និងកំនើនយឺតក្នុងវិស័យសំណង់ (១២,៨% ធៀបនឹង ១៩,៨% នៅត្រីមាសមុន) ។ កំនើន ផសស ពិតនៅថៃ បន្តនៅខ្លាំងដដែល គឺ ៣,៩% ទោះថយចុះបន្តិច ធៀបនឹងកំរិត ៥,៣% នៅត្រីមាសទី២ ក្តី ។ កំនើនយឺតជាងមុននេះ បណ្តាលមកពី ការធ្លាក់កំនើនក្នុងផ្នែកផលិតកម្មផលដំណាំ សត្វចិញ្ចឹម វត្ថុធាតុដើម និងទំនិញមូលធន ដូចជា យានយន្ត និងគ្រឿងម៉ាស៊ីនប្រើក្នុងការិយាល័យ ជាដើម ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០០៨ កំនើនថ្លៃទំនិញប្រើប្រាស់សរុបពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក គឺ ៥,៣% ដែលជាតួលេខខ្ពស់បំផុតគិតតាំងពីឆ្នាំ២០០៣ បើទោះជាថាមពលបានចុះថ្លៃយ៉ាងខ្លាំងតាំងពីពាក់កណ្តាលខែកក្កដាមកក្តី ។ អតិផរណានៅតំបន់អឺរ៉ូនៅតែមានកំរិតខ្ពស់ គឺ ៣,៨% ធៀបនឹង ១,៩% នៅត្រីមាសដូចគ្នាឆ្នាំមុន ដែលបណ្តាលមកពី ការឡើងថ្លៃជាបន្តបន្ទាប់នៃ ម្ហូបអាហារ និងសេវាកម្ម ។ ថ្លៃទំនិញប្រើប្រាស់សរុបក្នុងរយៈពេល ១២ខែ នៅជប៉ុនកើនឡើង ២,២% ដែលជាអត្រាកំនើនខ្ពស់បំផុត ក្នុងរយៈមួយទសវត្សរ៍ ហើយបង្កចេញពីការឡើងថ្លៃមួយជាពីរនៃការដឹកជញ្ជូនជាឯកជន ។

នៅត្រីមាសទី៣ ប្រាក់ដុល្លារUS ធ្លាក់ថ្លៃបន្តិចទល់នឹង ប្រាក់យ៉ុនចិន ដោយប្តូរបាន ៦,៨យ៉ុន/ដុល្លារUS ប៉ុន្តែវាឡើងថ្លៃទល់នឹង ប្រាក់ដុល្លារសិង្ហបុរី (៤,៤%), ប្រាក់អឺរ៉ូ (១0,៩%), ប្រាក់វ៉ុនកូរ៉េខាងត្បូង (១៨,៥%) និង ប្រាក់ដុល្លារតៃវ៉ាន់ (២,៥%) ។ ប្រាក់ ដុល្លារUS នៅថេរទល់នឹង ប្រាក់ដុល្លារហុងកុង និង ប្រាក់យ៉េនជប៉ុន ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៨ ថ្លៃផលិតផលកសិកម្មជាច្រើននៅលើទីផ្សារអន្តរជាតិ បង្ហាញនូវនិទស្សន៍មិនល្អមួយ សំរាប់ផលិតករ ។ ប្រេងឆា (នៅអឺរ៉ុបខាងពាយព្យ) និងអង្ករ (Thai 100% B) ធ្លាក់ថ្លៃយ៉ាងខ្លាំងអស់ ១២,៧% និង ២១,៦% ប៉ុន្តែ ពោត (US លេខ២) និងសណ្តែកសៀង (US លេខ១) ឡើងថ្លៃ ៧,១% និង ១0,៣% ។ សាំងឡើងថ្លៃបន្តិចដល់ ៨១,៣សេន/លីត្រ ប៉ុន្តែប្រេងឆៅចុះថ្លៃអស់ ១,៨% ដល់ ១១៥,៣0ដុល្លារUS/ធុង ហើយម៉ាស៊ូតចុះថ្លៃអស់ ៧,២% ដល់ ៨៨,៤សេន/លីត្រ ។

*រៀបរៀងដោយ*
*សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | 8.1 | 13.6 | - | - | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | 6.5 | 6.5 | 6.3 | 6.4 | 6.1 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 6.7 | 7.3 | 7.1 | 6.3 | 4.7 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 8.9 | 6.0 | 7.2 | 1.9 | -0.6 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 4.8 | 5.7 | 6.0 | 5.3 | 3.9 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.4 | 11.2 | 10.6 | 10.1 | 9.0 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 6.2 | 6.7 | 6.8 | 4.2 | 1.7 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 5.2 | 5.7 | 5.7 | 4.8 | 3.8 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 6.9 | 6.4 | 6.4 | 4.3 | -1.0 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 2.7 | 2.2 | 2.2 | 1.4 | 0.6 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 1.9 | 2.0 | 1.3 | 1.0 | -0.5 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 4.9 | 2.5 | 2.5 | 2.8 | 0.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 6.0 | 9.6 | 16.5 | 24.9 | 21.7 |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.5 | 6.7 | 7.6 | 10.1 | 11.9 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 1.8 | 2.2 | 2.6 | 4.8 | 8.4 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 2.7 | 4.1 | 6.6 | 7.5 | 6.5 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 1.7 | 2.9 | 5.0 | 7.7 | 7.2 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 8.6 | 10.7 | 16.4 | 24.4 | 29.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 6.1 | 6.6 | 8.0 | 7.8 | 5.3 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 1.6 | 3.5 | 4.6 | 5.7 | 4.6 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.3 | 3.3 | 3.7 | 4.8 | 5.5 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 1.4 | 4.5 | 2.3 | 4.2 | 4.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.9 | 2.9 | 3.4 | 3.8 | 3.8 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | -0.1 | 0.5 | 1.0 | 1.4 | 2.2 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 2.4 | 3.9 | 4.1 | 4.4 | 5.3 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា ( រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4078 | 4026 | 3995.3 | 4030.3 | 4117.4 |
| ឥណ្ឌូនេស៊ី ( រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 9257.8 | 9246.3 | 9248.2 | 9265.3 | 9216.3 |
| ម៉ាឡេស៊ី ( រីងហ្គីត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.46 | 3.35 | 3.22 | 3.21 | 3.37 |
| សិង្ហបុរី ( ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.52 | 1.45 | 1.41 | 1.37 | 1.43 |
| ថៃ ( បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 31.4 | 33.87 | 32.37 | 32.25 | 34.0 |
| វៀតណាម ( ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,206 | 16,084 | 15,896 | 16,881 | 16,517 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន ( យ៉ន់) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.55 | 7.43 | 7.16 | 6.96 | 6.82 |
| ហុងកុង ( ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.81 | 7.77 | 7.79 | 7.80 | 7.77 |
| កូរ៉េខាងត្បូង ( វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 927 | 921.23 | 955.89 | 1018.84 | 1207.0 |
| តៃវ៉ាន់ ( ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 32.9 | 32.4 | 31.52 | 30.45 | 31.20 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ ( អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.73 | 0.69 | 0.7 | 0.64 | 0.71 |
| ជប៉ុន ( យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 117.7 | 113.07 | 105.2 | 104.53 | 104.03 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ ( មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 Q3 | Q4 | 2008 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 139.81 | 156.9 | 198.39 | 238.03 | 254.99 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 745.86 | 841.39 | 1048.49 | 1086.89 | 949.03 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 304.75 | 323.92 | 444.43 | 839.58 | 657.88 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 299.99 | 366.59 | 449.64 | 479.97 | 529.30 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 72.48 | 82.88 | 93.77 | 117.48 | 115.30 |
| សាំង - US Gulf Coast ( សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 55.49 | 59.48 | 64.21 | 80.90 | 81.27 |
| ម៉ាស៊ូត ( ស្ពាន់ធ័រតិច លេខ២) - US Gulf Coast ( សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 56.62 | 66.54 | 73.99 | 95.37 | 88.46 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅត្រីមាសទី៣ ឆ្នាំ២០០៨ វិស័យភាគច្រើនក្នុងសេដ្ឋកិច្ចកម្ពុជា មានកំណើនគួរកត់សំគាល់ ។ ក្នុងនោះ អនុមតិគំរោងវិនិយោគលើការសាងសង់បានកើនឡើងយ៉ាងលឿន ហើយអនុមតិគំរោងវិនិយោគសរុបក្នុងវិស័យទាំងបី ក៏កើនឡើងបន្តិចដែរ ។ ឱនភាពពាណិជ្ជកម្ម បានធូរស្រាលឡើង រីឯចំនួនភ្ញៀវមកដល់កម្ពុជាមានការធ្លាក់ចុះតិចតួច ។

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៣ ឆ្នាំ២០០៨ អនុមតិគំរោងវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់បានកើនឡើងបន្តិច ។ តំលៃអនុមតិគំរោងវិនិយោគសរុប កើនដល់ ៤៥៦០,៧លានដុល្លារ ឬកើន ៩,២% ធៀបនឹងត្រីមាសមុន ។ ការកើនឡើងនេះ ជំរុញឡើងដោយកំណើនក្នុងវិស័យសេវាកម្មដែលកើន ៩,៥% ដល់ ៤៤៥០,៥លានដុល្លារ និងវិស័យកសិកម្មដែល កើន ១១% ដល់ ១៨,៦លានដុល្លារ ។ អនុមតិគំរោងវិនិយោគក្នុងអនុវិស័យទេសចរណ៍ ក្នុងនេះមានទាំងការអភិវឌ្ឍសណ្ឋាគារ និងមណ្ឌលកំសាន្តផងមានចំណែក ៧៨% ក្នុងអនុមតិគំរោងវិនិយោគសរុបខាងវិស័យសេវាកម្ម រីឯអនុមតិគំរោងវិនិយោគលើការសាងសង់ មានចំនួន ២,៣លានដុល្លារ ហើយអនុមតិគំរោងវិនិយោគខាងសេវាកម្មផ្សេងទៀតមាន ៩៧៦,៨លានដុល្លារ ។ តំលៃអនុមតិគំរោងក្នុងវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៣,៥% ធៀបនឹងត្រីមាសមុន មកត្រឹម ៩១,៦លានដុល្លារ ក្នុងនេះ អនុមតិគំរោងកាត់ដេរធ្លាក់ចុះ ៣៤% មកត្រឹម ៣១,៣លានដុល្លារ ។ នៅត្រីមាសទី៣នេះ អនុមតិគំរោងក្នុងអនុវិស័យថាមពល ដែលជាយូរមកហើយគេតែងចាត់ទុកជាកត្តាសំខាន់ក្នុងកំណើនសេដ្ឋកិច្ចជាតិ មានចំនួន ៤៦,៥លានដុល្លារ ។ តាមការប៉ាន់ស្មាន ប្រសិនបើអនុមតិគំរោងវិនិយោគទាំងអស់អនុវត្តបានពេញលេញ វានឹងបង្កើតបាន ៤៣.២៩៤ការងារ គឺ ខាងកសិកម្មមាន ១៩៤៤ ខាងសេវាកម្មមាន ១៨.០៦៦ និងខាងឧស្សាហកម្ម ២៣.២៨៤ ។

នៅត្រីមាសទី៣ អនុមតិគំរោងសាងសង់នៅរាជធានីភ្នំពេញ មានតំលៃ ៤៨៦,៩លានដុល្លារ ឬកើនឡើង ២ដងកន្លះ ធៀបនឹងត្រីមាសទី២ ។ អនុមតិភូមិគ្រឹះ និងផ្ទះ កើនមួយជាបី ដល់ ៥២,១លានដុល្លារ ហើយអនុមតិគំរោងសាងសង់ផ្ទះល្វែង កើន ១៩% ដល់ ៦៥,៦លានដុល្លារ ។ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អនុមតិគំរោងសាងសង់សរុបកើនមួយជាបី អនុមតិភូមិគ្រឹះនិងផ្ទះកើនមួយជាពីរ រីឯអនុមតិគំរោងសាងសង់ផ្ទះល្វែងធ្លាក់ចុះ ៤៤% ។

នៅត្រីមាសទី៣ ឱនភាពពាណិជ្ជកម្មកម្ពុជា បានប្រសើរឡើងដោយសារការនាំចេញកើនយ៉ាងខ្លាំងបាន ៧២% ដល់ ៩២៨,៧លានដុល្លារ ចំណែកឯការនាំចូលសរុប ធ្លាក់ចុះ ១៣% មកត្រឹម ១០២៧,១លានដុល្លារ ។ កំនើនការនាំចេញ បណ្តាលមកពីសន្ទុះនៃការនាំចេញសំលៀកបំពាក់ដែលកើនបាន ៨៧% ។ ការនាំចេញត្រី និងកៅស៊ូ កើន ៧៩% និង ១៧% ដល់ ០,៦លានដុល្លារ និង ១២,៩លានដុល្លារ ។

ចំពោះការនាំចូលក្នុងត្រីមាសទី៣ ការនាំចូលបារីសរុប មានតំលៃ ២៨,៧លានដុល្លារ ធៀបនឹង ៤១,៥លានដុល្លារ នៅត្រីមាសមុន ។ ការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ១៣% មកត្រឹម ៣៥,៦លានដុល្លារ ក្នុងនោះ ការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ១២% មកត្រឹម ១១,៤លានដុល្លារ និងការនាំចូលដែកថែប ធ្លាក់ចុះ ៣៥% មកត្រឹម ១០,៣លានដុល្លារ ។ ការនាំចូលបរិក្ខារសំណង់ កើន ១៧% ដល់ ១៣,៩លានដុល្លារ ។ នៅត្រីមាសទី៣ នេះ ការនាំចូលទំនិញភាគច្រើនបានធ្លាក់ចុះគួរកត់សំគាល់ រួមទាំងផលិតផលប្រេងដែលធ្លាក់ចុះ ៥,៨% មកត្រឹម ៦៨,៣លានដុល្លារ ហើយនិង ក្រណាត់និងសំលៀកបំពាក់ដែលធ្លាក់ចុះ ២០% មកត្រឹម ១៣,២លានដុល្លារ ។

នៅត្រីមាសទី៣ ឆ្នាំ២០០៨ ភ្ញៀវមកដល់កម្ពុជា មាន ៤៤៥.៤៦៧នាក់ ធៀបនឹង ៤៤២.២៣៣នាក់នៅត្រីមាសមុន ។ ភ្ញៀវមកដល់តាមផ្លូវអាកាស មាន ២៥៩.១៩០នាក់ ឬ ធ្លាក់ចុះ ១,១% ធៀបនឹងត្រីមាសទី២ ។ នៅត្រីមាសទី៣ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបាន ១៣៣.៥០៨នាក់ ហើយអាកាសយានដ្ឋានសៀមរាប ទទួលបាន ១២៥.៦៨២នាក់ ។ ភ្ញៀវមកដល់តាមផ្លូវគោក ថយចុះ ៤,៩% មកត្រឹម ១៧២.០៥១នាក់ ចំណែកឯភ្ញៀវមកដល់តាមផ្លូវទឹក កើន ២៨% ដល់ ១៤.២២៦នាក់ ។ ភ្ញៀវមកសំរាកលំហែ មាន ៣៩០.៦៦៣នាក់ ឬ ថយចុះ ០,៩% ធៀបនឹង ត្រីមាសមុន ។ តួលេខរបស់ក្រសួងទេសចរណ៍ បានបង្ហាញថា ក្នុងត្រីមាសទី៣នេះ ចំនួនភ្ញៀវមកដល់ខេត្តសៀមរាប ធ្លាក់ចុះ ៦,០% មកត្រឹម ២០៩.០០៥នាក់ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឱនភាពថវិកាសរុបរបស់រដ្ឋាភិបាល មានសភាពកាន់តែយ៉ាប់យ៉ឺន ដោយកើនដល់ ៣៦៥,៨ពាន់លានរៀល ធៀបនឹង ២៨១,១ពាន់លានរៀលនៅត្រីមាសទី២ ។ ស្ថានភាពនេះបណ្តាលមកពីការធ្លាក់ចុះចំណូលសរុប ១១% និង ចំណាយសរុប ៤,៧% ។ ចំណូលសរុប មានចំនួន ១២៩៧,០ពាន់លានរៀល ក្នុងនេះ ៨៣% ទទួលបានពីការប្រមូលពន្ធ ។ ការប្រមូលពន្ធសរុប ធ្លាក់ចុះ ១៥% ធៀបនឹងត្រីមាសមុន ដោយចំណូលពន្ធក្នុងស្រុក ធ្លាក់ចុះ ១៩% មកត្រឹម ៧៧៦,៧ពាន់លានរៀល និង ពន្ធលើពាណិជ្ជកម្មអន្តរជាតិ ធ្លាក់ចុះ ១,៦% មកត្រឹម ២៩៤,៥ពាន់លានរៀល ។ ចំណូលមិនមែនពន្ធ រួមទាំងចំណូលបានមកពីអចលនទ្រព្យ ការលក់ទំនិញនិងសេវាកម្ម កើនឡើង ១៣% ដល់ ២១៧,១ពាន់លានរៀល ។ ចំណូលមូលធនធ្លាក់ចុះ ៤៨% មកត្រឹម ៨,៧ពាន់លានរៀល ។

ចំណាយរបស់រដ្ឋាភិបាល ធ្លាក់ចុះពី ១៧៤៤,៧ពាន់លានរៀលក្នុងត្រីមាសទី២ មកត្រឹម ១៦៦២,៨ពាន់លានរៀល នៅត្រីមាសទី៣ ដែលបណ្តាលមកពីការធ្លាក់ចុះឧបត្ថម្ភធន និងចំណាយសង្គម អស់ ៦៦% មកត្រឹម ១១១,៩ពាន់លានរៀល ។ ចំណាយលើប្រាក់បៀវត្សរ៍ ធ្លាក់ចុះ ០,៩% មកត្រឹម ៣៦៣,៦ពាន់លានរៀល ។ ចំណាយមូលធន ក៏បានធ្លាក់ចុះអស់ ១,១% ដែរធៀបនឹងត្រីមាសទី២ មកត្រឹម ៦៤១,២ពាន់លានរៀល ។ ក្នុងចំណាយមូលធន មាន ៦៣% ដោះស្រាយដោយប្រភពទុនខាងក្រៅ ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅរាជធានីភ្នំពេញ ក្នុងត្រីមាសទី៣នេះ ថ្លៃទំនិញប្រើប្រាស់ទូទៅ មានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ២១,៧% ធៀបនឹង ២៤,៩%នៅត្រីមាសមុន និង ៦% នៅត្រីមាសទី៣ ឆ្នាំ២០០៧ ។ ថ្លៃម្ហូបអាហារ និងភេសជ្ជៈ ដែលជាកត្តាសំខាន់នៃអតិផរណា កើនឡើងយ៉ាងខ្លាំងដល់ ៣៥,២% ហើយចំណាយលើការដឹកជញ្ជូន កើន ២៥,៤% ។ ចំណាយលើគ្រឿងសង្ហារឹមក្នុងផ្ទះ និងចំណាយក្នុងផ្ទះ ស្ទុះឡើង ២៧,៤% ។ ចំណាយថែទាំសុខភាព កើនឡើង ១២,៩% ចំណែកឯចំណាយលើសំលៀកបំពាក់ និងស្បែកជើង កើន ០,៦% ។

នៅត្រីមាសទី៣ ប្រាក់រៀលធ្លាក់ថ្លៃទល់នឹងដុល្លារUS ដោយប្តូរបាន ៤១១៧រៀល/ដុល្លារUS ធៀបនឹង ៤០៣០រៀល/ដុល្លារUS នៅត្រីមាសមុន ។ ប្រាក់រៀល ឡើងថ្លៃទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ដោយប្តូរបាន ១២១,៨រៀល/បាត ឬ ឡើងថ្លៃ ២,៨% និង ២៤,៧រៀល/១០០ដុង ឬ ឡើងថ្លៃ ០,៥% ។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## ការវិវត្តរូបិយវត្ថុ

នៅខែកញ្ញា ២០០៨ រូបិយវត្ថុទូទៅ (M2) កើនដល់ ១២.៥៩៧,២ពាន់លានរៀល ធៀបនឹង ៩៩០៨,២ពាន់លានរៀលកាលពីមួយឆ្នាំមុន ។ ប្រាក់រៀលចរាចរ កើន ៣៤% ដល់ ២២៥៨,៩ពាន់លានរៀល និង ប្រាក់បញ្ញើជារៀល កើន ៤៦% ដល់ ២៥៦,៥ពាន់លានរៀល ។ ក្នុងពេលជាមួយគ្នា ប្រាក់បញ្ញើជារូបិយវត្ថុបរទេស កើន ២៥% ដល់ ១០.០៤១,៧ពាន់លានរៀល ។

ទ្រព្យសកម្មបរទេសសុទ្ធ កើន ១១% ធៀបនឹងខែកញ្ញា ២០០៧ ដល់ ១០.៨០៨,៧ពាន់លានរៀល ដោយសារកំនើនទ្រព្យសកម្មបរទេស ២៩% និង កំនើនបំណុលបរទេស ២៥៥% ដល់ ២៧៩២,៥ពាន់លានរៀល ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើនយ៉ាងខ្លាំង ដល់ ១៧៤៨,៤៧៨ពាន់លានរៀល ធៀបនឹង ១៤០,២ពាន់លានរៀល នៅខែកញ្ញា ២០០៧ ។ កំនើនខ្លាំងបែបនេះបណ្ដាលមកពី កំនើនឥណទានក្នុងស្រុក ដល់ ៧១២៨,១ពាន់លានរៀល និង កំនើនបំណុលផ្សេងទៀត ដល់ ៥៣៧៩,៦ពាន់លានរៀល ។ ប្រាក់បញ្ញើរបស់រដ្ឋាភិបាលដែលជា សមាសធាតុមួយនៃឥណទានក្នុងស្រុក កើន ៥៩% ដល់ ២៩២៣,០ពាន់លានរៀល ចំណែកឯគណនីឥណទានរបស់រដ្ឋាភិបាល ថយចុះ ៨,៨% មកត្រឹម ២៧០,៥ពាន់លានរៀល ។ ឥណទានដល់វិស័យឯកជន កើនដល់ ៩៧៨០,៧ពាន់លានរៀល ធៀបនឹង ៥៣៧៦,៤ពាន់លានរៀលនៅខែកញ្ញា ២០០៧ ។

## ស្ថានភាពភាពក្រីក្រ-ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

នៅខែវិច្ឆិកា ២០០៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានធ្វើអង្កេតលើ ពលករងាយរងគ្រោះចំនួន ១០ក្រុម ក្នុងនេះមាន ៩ក្រុម នៅរាជធានីភ្នំពេញ និង ១ក្រុម (អ្នកស៊ីឈ្នួលធ្វើស្រែ) នៅក្នុងខេត្តកណ្ដាល និងខេត្តកំពង់ស្ពឺ ។ ការអង្កេតនេះ បង្ហាញពីទស្សនៈរបស់ប្រជាជននៅក្នុងក្រុមតូចៗ ដូចនេះ វាមិនតំណាងឱ្យថ្នាក់ជាតិទាំងមូលនោះទេ ។

អ្នកធាក់ស៊ីក្លូភាគច្រើនមកពីខេត្តផ្សេងៗ ហើយប្រហែល ៧២% មានដីកសិកម្ម តិចជាង ១ហិកតា ។ ដោយសារមានដីតូចពេកសំរាប់ដាំដុះ ពួកគេក៏ធ្វើចំណាកស្រុកមកធាក់ស៊ីក្លូនៅភ្នំពេញ ។ នៅខែវិច្ឆិកា ២០០៨ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ កើនដល់ ១២.៦២៨រៀល ធៀបនឹង ៩៣៩៣រៀលនៅខែដូចគ្នាឆ្នាំមុន ។ កំនើននេះ ទទួលឥទ្ធិពលដោយប្រយោលពីកំនើនថ្លៃម្ហូបអាហារនិងទំនិញប្រើប្រាស់ផ្សេងៗតាំងពីដើមឆ្នាំ២០០៨ ។ ទោះបីប្រាក់ចំណូលរបស់គាត់កើនឡើង ៣៤%ក្ដី ប៉ុន្តែអ្នកធាក់ស៊ីក្លូភាគច្រើនត្អូញត្អែរថា ប្រាក់រកបាន វាមិនស៊ីគ្នានឹងថ្លៃទំនិញប្រើប្រាស់ឡើយ ។ ពួកគាត់រាយការណ៍ថា កាលពីមុនគាត់ចំណាយលើម្ហូបអាហារអស់ប្រហែល ៥០០០រៀលប៉ុណ្ណោះក្នុងមួយថ្ងៃ ប៉ុន្តែឥឡូវនេះត្រូវចំណាយអស់ ៨៦០០រៀលក្នុងមួយថ្ងៃ ។ ថ្វីបើប្រាក់ចំណូលបានកើនឡើង ប៉ុន្តែវាមិនគ្រប់គ្រាន់សំរាប់ដោះស្រាយតំរូវការជាមូលដ្ឋានឡើយ ។ គ្រួសារពួកគាត់ត្រូវខ្វះស្បៀងអាហារ ហើយនេះជាមូលហេតុនាំឱ្យជំពាក់បំណុលគេ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប គឺ ១៥.៦០០រៀល ឬកើន ៣៦% ធៀបនឹងខែដូចគ្នា ឆ្នាំ២០០៧ ។ ប្រាក់ចំណូលរកបាន វាគ្រប់គ្រាន់សំរាប់តែចំណាយលើម្ហូបអាហារ ហើយគ្មាននៅសល់សំរាប់បង្កើតមុខរបរអ្វីថ្មី បានឡើយ ។ អ្នករត់ម៉ូតូឌុបឆ្លើយសំភាសន៍ ប្រមាណ ២០% មិនទាន់រៀបការទេ ប៉ុន្តែពួកគេបានឈប់រៀន ដើម្បីរកប្រាក់ចិញ្ចឹមជីវិត ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ និងគ្មានជំនាញ កើនឡើង ១៦% ដែលជាការឆ្លើយតបនឹង ការស្ទុះឡើងថ្លៃទំនិញប្រើប្រាស់ ជាពិសេស ម្ហូបអាហារ និង ការដឹកជញ្ជូន ។ កម្មករសំណង់មានជំនាញរកបាន ១២.៧១០រៀលក្នុងមួយថ្ងៃ រឺ ៤៥% ខ្ពស់ជាងកម្មករគ្មានជំនាញ ។ កម្មករគ្មានជំនាញភាគច្រើនរាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេគ្រប់គ្រាន់សំរាប់តែទិញម្ហូបអាហារ ហើយគ្មានសន្សំអ្វីបានសំរាប់ជួយទ្រទ្រង់ជីវភាពគ្រួសារទេ ។ ទាំងពីរក្រុមបានប្រាប់ពីមូលហេតុដែលមកធ្វើការនៅភ្នំពេញថា ដោយសារពួកគេមិនមានដីធ្វើកសិកម្មគ្រប់គ្រាន់ ។ ទោះយ៉ាងនេះក្ដី ពួកគេចំណាយពេលធ្វើការនៅទីក្រុង តែ៧ខែ ប៉ុណ្ណោះក្នុងមួយឆ្នាំ ។

អ្នកលក់បន្លែតូចតាចចំនួន ៩៣% មកពីខេត្តស្វាយរៀង តាកែវ ព្រៃវែង និង កណ្ដាល ។ ពួកគេមកភ្នំពេញដោយរំពឹងថា អាចលក់បន្លែបានថ្លៃខ្ពស់ជាង ។ នៅខែវិច្ឆិកា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគេ កើន ១៩% ដល់ ៩៨៩៣រៀល ប៉ុន្តែមាន ៦៧% នៅតែត្អូញត្អែរថា ប្រាក់ចំណូលនេះមិនគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតឡើយ ។

សំរាប់អ្នកស៊ីឈ្នួលធ្វើស្រែ អង្កេតបានបង្ហាញពីកំណើនគួរគត់សំគាល់នៃប្រាក់ចំណូលប្រចាំថ្ងៃ ដល់ទៅ ៥៧% ធៀបនឹងកាលពីមួយឆ្នាំមុន ។ ពួកគេចំណាយពេលតែ ២-៣ខែប៉ុណ្ណោះក្នុងមួយឆ្នាំ ដើម្បីលក់កម្លាំងពលកម្មធ្វើការងារស្រែចម្ការ ។ ប៉ុន្តែអ្នកស៊ីឈ្នួលធ្វើស្រែភាគច្រើនរាយការណ៍ថា ចំនួនអ្នកធ្វើការនៅក្នុងកសិដ្ឋាន បានថយចុះ ដោយសារមានយុវជនកាន់តែច្រើនបានចាកចេញទៅធ្វើការនៅតំបន់ទីក្រុង ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ ថយចុះ ១៦,៣ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន មកត្រឹម ៤៦៥០រៀលក្នុងមួយថ្ងៃ ។ តាមសំដីរបស់ឈ្មួញកណ្ដាល ការថយចុះនេះបណ្ដាលមកពីការធ្លាក់ថ្លៃរបស់អេតចាយ ដោយសារតំហយចុះការនាំចេញរបស់អេតចាយទៅកាន់ប្រទេសវៀតណាម និងថៃ ។ អ្នករើសអេតចាយប្រមាណ ៩៥% មកពីខេត្ត ហើយមាន ៧៥% បានមកភ្នំពេញទាំងគ្រួសារដើម្បីរើសអេតចាយ ។ កន្លែងស្នាក់នៅរបស់ពួកគេ ស្ថិតនៅក្បែរកន្លែងចាក់សំរាម ហើយពួកគេត្រូវចំណាយលុយ ៤០.០០០រៀលក្នុងមួយខែជាថ្លៃជួលកន្លែង ។ ដោយសារថ្លៃអេតចាយធ្លាក់ចុះ អ្នករើសអេតចាយ ៣០% បានខ្ចីប្រាក់គេដើម្បីទិញម្ហូបអាហារ និងព្យាបាលជម្ងឺ ។ ពួកគេបានបញ្ជាក់បន្ថែមថា ជីវភាពរបស់ពួកគេពឹងផ្អែកទាំងស្រុងលើថ្លៃអេតចាយ ហើយប្រសិនបើថ្លៃនេះនៅតែទាបអញ្ចឹង ពួកគេនឹងរីតតែយ៉ាប់យ៉ឺនថែមទៀត ។

នៅខែវិច្ឆិកា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ ធ្លាក់ចុះពី ៨២០៧រៀលក្នុងមួយថ្ងៃកាលពីមួយឆ្នាំមុន មកត្រឹម ៧៥៨២រៀលក្នុងមួយថ្ងៃ ។ កម្មករកាត់ដេរចំនួន ៦៧,៥% បានរាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះ ដោយសារការងារបន្ថែមម៉ោងបានថយចុះ ។ នៅពេលនេះ មានអ្នកឆ្លើយសំភាសន៍ ២០% មិនបានធ្វើការបន្ថែមម៉ោងទេ ។ ប៉ុន្តែមានកម្មករកាត់ដេរ៨០%នៅតែផ្ញើប្រាក់ទៅផ្ទះដើម្បីផ្គត់ផ្គង់គ្រួសារដដែល ។ ពួកគេបានប្រាប់ទៀតថា ប្រាក់ដែលរកបានមិនគ្រប់គ្រាន់សំរាប់ការរស់នៅក្នុងទីក្រុងឡើយ ពីព្រោះពួកគេត្រូវចំណាយអស់ប្រហែល ៥០ដុល្លារក្នុងមួយខែសំរាប់ចិញ្ចឹមជីវិត ។

*រៀបចំដោយ*
*ផាន់ ដាលីស និងប៊ុន ដូរីណា*

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2* | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 40.3 | 3.7 | 12.3 | 26.8 | 498.0 | 19.1 | 2.1 | 12.0 | 102.4 | 52.3 | 16.7 | 18.6 |
| ឧស្សាហកម្ម | 67.7 | 137.2 | 187.9 | 914.6 | 365.3 | 142.7 | 51.2 | 187.2 | 328.0 | 52.9 | 95.0 | 91.6 |
| *កាត់ដេរ* | *27.2* | *68.1* | *132.6* | *174.4* | *89.4* | *36.6* | *24.3* | *40.7* | *69.1* | *42.3* | *47.8* | *31.3* |
| សេវាកម្ម | 145.3 | 168.4 | 91.8 | 155.5 | 2939.1 | 335.7 | 138.0 | 957.7 | 311.1 | 148.2 | 4064.9 | 4450.5 |
| *សណ្ឋាគារ និងទេសចរណ៍* | *47.1* | *124.1* | *55.9* | *102.6* | *345.0* | *140.3* | *55.0* | *653.8* | *199.2* | *93.7* | *4015.0* | *3481.3* |
| សរុប | 253.3 | 309.3 | 292.0 | 1096.9 | 3802.4 | 497.5 | 191.3 | 1156.9 | 741.5 | 253.4 | 4176.5 | 4560.7 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -48.8 | -61.6 | 504.7 | -35.9 | -78.1 | 1548.2 | 9.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 13.1 | 22.1 | -5.6 | 275.6 | 246.6 | 118.9 | 91.8 | 334.6 | -23.7 | -49.1 | 2083.2 | 294.2 |

*Including expansion project approvals. Source: Cambodian Investment Board, * Revised data.*

តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 23.4 | 20.0 | 30.3 | 45.5 | 33.1 | 14.4 | 22.8 | 21.7 | 20.2 | 45.3 | 17.6 | 52.1 |
| ផ្ទះល្វែង | 179.9 | 91.6 | 167.6 | 204.2 | 213.3 | 88.9 | 33.2 | 117.5 | 57.6 | 40.9 | 55.1 | 65.6 |
| ផ្សេងៗ | 16.6 | 87.3 | 65.6 | 109.1 | 76.8 | 35.9 | 88.8 | 40.6 | 94.3 | 51.2 | 68.2 | 369.3 |
| សរុប | 219.9 | 198.9 | 263.5 | 358.8 | 323.3 | 139.2 | 144.7 | 179.7 | 172.2 | 137.3 | 140.9 | 486.9 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 78.0 | 3.9 | 24.2 | -4.2 | -1.4 | 2.6 | 245.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 12.0 | -9.5 | 32.5 | 36.2 | -9.9 | 106.5 | 76.0 | 88.2 | 120.2 | -1.4 | -2.6 | 170.9 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 1453.2 | 1708.1 | 2108.1 | 2352.8 | 2799.9 | 707.8 | 705.0 | 890.8 | 793.4 | 803.1 | 539.6 | 928.7 |
| រួមមាន: សំលៀកបំពាក់ | 1355.8 | 1628.4 | 2027 | 2253.3 | 2698.9 | 677.5 | 688.2 | 846.1 | 727.1 | 773.4 | 463.8 | 868.8 |
| កៅស៊ូ | 29.7 | 35.1 | 38.3 | 36.7 | 41.4 | 8.4 | 6.9 | 11.7 | 14.6 | 7.0 | 11.0 | 12.9 |
| ឈើ | 16.0 | 10.2 | 11.1 | 10.3 | 8.6 | 2.1 | 2.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ត្រី | 4.3 | 2.8 | 10.6 | 10.1 | 5.9 | 0.7 | 0.4 | 1.2 | 0.9 | 0.7 | 0.3 | 0.6 |
| ការនាំចូលសរុប | 1707.8 | 1824.9 | 2149.0 | 2513.0 | 3057.0 | 790.9 | 911.6 | 924.5 | 982.7 | 983.8 | 1178.5 | 1027.1 |
| រួមមាន: ផលិតផលប្រេងកាត | 157.5 | 191.6 | 187.0 | 184.8 | 238.5 | 66.5 | 68.5 | 71.0 | 58.9 | 60.0 | 64.6 | 68.3 |
| សំភារៈសំណង់ | 12.9 | 80.8 | 95.3 | 134.7 | 154.4 | 44.1 | 31.6 | 34.9 | 32.5 | 39.7 | 40.7 | 35.6 |
| ផ្សេងៗ | 1568.2 | 1601.3 | 1914.0 | 2245.0 | 2731.0 | 699.2 | 807.5 | 818.6 | 891.3 | 884.1 | 1073.2 | 923.2 |
| ជញ្ជីងពាណិជ្ជកម្ម | -254.6 | -116.8 | -40.9 | -160.1 | -257.1 | -83.1 | -208.1 | -30.7 | -189.3 | -180.7 | -638.9 | -98.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | -5.4 | 1.6 | 22.9 | -14.1 | 6.4 | -40.0 | 87.3 |
| ការនាំចេញសរុប | - | - | - | - | - | -3.9 | 0.4 | 26.4 | -10.9 | 1.2 | -32.8 | 72.1 |
| ការនាំចូលសរុប | - | - | - | - | - | -2.0 | 15.3 | 1.4 | 6.3 | 0.1 | 19.8 | -12.8 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 9.2 | -54.1 | -64.9 | 291.4 | 19.8 | 19.2 | 8.8 | 8.2 | 1.6 | 14.2 | -32.6 | 2.7 |
| ការនាំចេញសរុប | 14.6 | 17.5 | 23.4 | 11.6 | 19.0 | 17.3 | 8.0 | 10.3 | 7.7 | 13.5 | -23.5 | 4.3 |
| ការនាំចូលសរុប | 13.7 | 6.9 | 17.8 | 16.9 | 21.6 | 14.5 | 17.6 | 17.9 | 21.7 | 24.4 | 29.3 | 11.1 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by NBC*

តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2008 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 523.0 | 456.0 | 626.1 | 856.5 | 1029.0 | 373.6 | 275.6 | 278.5 | 368.8 | 402.0 | 262.0 | 259.2 |
| តាមផ្លូវគោក និងទឹក | 263.5 | 245.0 | 428.9 | 565.1 | 672.9 | 177.2 | 148.9 | 153.3 | 239.2 | 242.2 | 192.0 | 186.3 |
| សរុប | 786.5 | 701.1 | 1055.0 | 1421.6 | 1701.9 | 550.8 | 424.5 | 431.8 | 608.0 | 644.2 | 454.0 | 445.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 6.7 | -22.9 | 1.7 | 40.8 | 6.0 | -29.5 | -1.9 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.0 | -10.9 | 50.5 | 34.7 | 19.7 | 20.4 | 19.2 | 16.5 | 17.8 | 17.0 | 6.9 | 3.2 |

*Source: Ministry of Tourism*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០២-០៨ (ពាន់លានរៀល)

| | 2002 | 2003 | 2004 | 2005 | 2006 | 2007<br>Q1 | Q2 | Q3 | Q4 | 2008<br>Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1744 | 1764 | 2126 | 2625 | 3259.2 | 824.9 | 1016.8 | 1031.4 | 1146.1 | 1194.1 | 1463.6 | 1297.0 |
| ចំណូលចរន្ត | 1728 | 1733 | 2107 | 2474 | 2881.8 | 824.9 | 1012.4 | 1031.4 | 1141.6 | 1189.4 | 1447.0 | 1288.3 |
| ចំណូលពន្ធ | 1227 | 1220 | 1577 | 1911 | 2270.9 | 699.9 | 887.7 | 844.6 | 965.2 | 978.0 | 1255.0 | 1071.2 |
| ពន្ធក្នុងស្រុក | - | - | - | - | - | 487.9 | 642.1 | 584.8 | 661.8 | 719.9 | 955.5 | 776.7 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | 212.1 | 245.6 | 259.8 | 303.5 | 258.1 | 299.5 | 294.5 |
| ចំណូលមិនមែនពន្ធ | 501 | 513 | 530 | 563 | 610.9 | 125.0 | 124.7 | 186.9 | 176.4 | 211.4 | 192.1 | 217.1 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 | 2.9 | 53.9 | 11.0 |
| លក់ទំនិញ និងសេវា | - | - | - | - | - | 88.8 | 93.0 | 100.1 | 124.3 | 118.9 | 96.3 | 99.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | - | 8.3 | 16.2 | 72.0 | 38.5 | 89.6 | 41.9 | 106.4 |
| ចំណូលជាមូលធន | 16 | 31 | 19 | 152 | 377.4 | 0.0 | 4.5 | 0.0 | 4.5 | 4.8 | 16.5 | 8.7 |
| ចំណាយសរុប | 2948 | 2757 | 2932 | 3295 | 4174.7 | 923.9 | 1098.7 | 1126.1 | 1689.7 | 1059.1 | 1744.7 | 1662.8 |
| ចំណាយជាមូលធន | 1388 | 1171 | 1163 | 1328 | 1638.1 | 367.1 | 408.1 | 355.1 | 807.4 | 411.0 | 648.2 | 641.2 |
| ចំណាយចរន្ត | 1560 | 1586 | 1769 | 1967 | 2536.8 | 556.8 | 681.6 | 771.0 | 882.3 | 648.1 | 1096.5 | 918.0 |
| បៀវត្សរ៍ | 587 | 615 | 640 | 711 | 822.0 | 199.7 | 242.7 | 253.4 | 362.6 | 250.7 | 367.0 | 363.6 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 | 104.3 | 325.7 | 111.9 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | - | 295.2 | 254.9 | 402.6 | 325.5 | 193.1 | 403.8 | 442.6 |
| សមតុល្យជាទូទៅ | -1204 | -993 | -806 | -706 | -915.6 | -99.0 | -81.9 | -78.7 | -543.6 | 135.0 | -281.1 | -365.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1249 | 886 | 864 | 1127 | 1360.7 | 344.0 | 313.9 | 290.3 | 741.5 | 299.2 | 615.8 | 438.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -45 | 106 | 148 | -396 | -445.1 | -245.0 | -213.0 | -148.0 | -185.8 | -294.1 | -236.5 | 35.1 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០២-០៨

| (October-December 2006:100) | 2002 | 2003 | 2004 | 2005 | 2006 | 2007<br>Q1 | Q2 | Q3 | Q4 | 2008<br>Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | |
| ខេត្ត | 3.3 | 1.1 | 3.9 | 5.8 | 4.7 | 3.0 | 4.6 | 6.0 | 9.7 | 16.5 | 24.9 | 21.7 |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 1.8 | 1.5 | 6.4 | 8.6 | 6.4 | 3.0 | 7.2 | 11.3 | 18.1 | 27.6 | 43.5 | 35.2 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 0.3 | 4.9 | 9.7 | 11.4 | 9.1 | 5.2 | 5.0 | 3.1 | 9.9 | 18.8 | 25.3 | 25.4 |
| - ដឹកជញ្ជូន | 0.3 | 4.9 | 9.7 | 11.4 | 10.1 | 6.8 | 5.2 | 5.0 | 3.1 | 9.9 | 18.8 | 25.3 |
| | | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3912.1 | 3973.3 | 4016.3 | 4119.7 | 4119.0 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 | 4030.2 | 4117.5 |
| រៀលក្នុង ១ បាតថៃ | 91.1 | 95.8 | 99.9 | 102.6 | 108.7 | 113.7 | 118.0 | 130.0 | 129.3 | 129.1 | 125.4 | 121.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.6 | 25.5 | 25.8 | 25.1 | 24.6 | 24.7 | 25.3 | 25.2 | 25.2 | 24.9 | 24.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.8 | 41.4 | 46.3 | 54.0 | 70.6 | 77.7 | 79.8 | 80.8 | 94.4 | 111.6 | 107.7 | 106.0 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1521 | 1508 | 2088 | 2633 | 3140 | 3067 | 3100 | 3203 | 3679 | 3982 | 4975 | 5495 |
| ថ្លៃសាំង (រៀល/លីត្រ) | 2084 | 2150 | 2833 | 3442 | 4004 | 3750 | 3900 | 4002 | 4368 | 4580 | 5171 | 5391 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០២-០៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | 2007<br>Q1 | Q2 | Q3 | Q4 | 2008<br>Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3737 | 4027 | 4797 | 5475 | 7224 | 8056 | 9048 | 9768 | 10735 | 10911 | 11353 | 10809 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -849 | -698 | -467 | -450 | -282 | -263 | -172 | 140 | 576 | 1136 | 1345 | 1748 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -119 | -128 | -209 | -421 | -953 | -1176 | -1403 | -1547 | -1816 | -2400 | -2678 | -2653 |
| ឥណទានដល់ផ្នែកឯកជន | 1059 | 1337 | 1817 | 2394 | 3630 | 4066 | 4537 | 5376 | 6386 | 8050 | 9206 | 9781 |
| រូបិយវត្ថុទូទៅ M2 | 2888 | 3329 | 4330 | 5025 | 6942 | 7793 | 8876 | 9908 | 11311 | 12047 | 12698 | 12557 |
| រូបិយវត្ថុ M1 | 813 | 937 | 1153 | 1323 | 1658 | 1794 | 1748 | 1750 | 2052 | 2389 | 2467 | 2335 |
| រូបិយវត្ថុផ្សេងៗ | 2075 | 2392 | 3177 | 3702 | 5285 | 5999 | 7128 | 8158 | 9259 | 9658 | 10231 | 10223 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 31.0 | 15.2 | 30.0 | 16.1 | 38.1 | 36.5 | 46.8 | 53.4 | 62.9 | 54.5 | 43.1 | 26.7 |
| រូបិយវត្ថុ M1 | 33.5 | 15.3 | 23.0 | 14.7 | 25.3 | 23.9 | 15.7 | 12.0 | 23.8 | 33.2 | 41.1 | 33.4 |
| រូបិយវត្ថុផ្សេងៗ | 30.0 | 15.2 | 32.8 | 16.6 | 42.8 | 40.7 | 57.3 | 66.5 | 75.2 | 61.0 | 43.5 | 25.3 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000<br>វិច្ឆិកា | 2003 | 2004 | 2005 | 2006<br>វិច្ឆិកា | 2007<br>ឧសភា | សីហា | វិច្ឆិកា | 2008<br>វិច្ឆិកា | 2007<br>សីហា | វិច្ឆិកា | 2008<br>វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 9245 | 7126 | 9393 | 12,628 | 18 | 27 | 34 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 9798 | 7704 | 8852 | 9004 | 47 | 26 | 2 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 8951 | 9116 | 8303 | 9893 | 75 | 36 | 19 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 5533 | 6038 | 5560 | 4651 | 42 | 42 | -16 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 5150 | 4193 | 4508 | 4327 | -2 | 0 | -4 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4531 | 4561 | 4790 | 7541 | 10 | 3 | 57 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 8347 | 9033 | 8207 | 7582 | -2 | -8 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 12,886 | 8979 | 11,525 | 15,658 | 33 | 37 | 36 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 6075 | 5901 | 7550 | 8779 | -2 | 43 | 16 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 11,892 | 11,723 | 10,956 | 12,710 | 24 | 7 | 16 |

* *Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ២៤* **ព័ត៌មានថ្មីពី ...**

ឯកភាពពី Sida DFID និង CDRI ហើយផ្តោតលើលទ្ធផលរបស់ CDRI ក្នុងការស្រាវជ្រាវដោយឯករាជ្យពីគោលនយោបាយនិងផលប៉ះពាល់ផ្សេងៗ ក្នុងការងាររដ្ឋបាលនិងគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្សនិងអភិវឌ្ឍន៍សមត្ថភាព ការធ្វើផែនការយុទ្ធសាស្រ្ត ការអនុវត្ត និងការត្រួតពិនិត្យ និងតំរូវការពង្រឹងវិទ្យាស្ថាន CDRI ទៅអនាគត ។

## ផ្នែកស្រាវជ្រាវ

ការស្រាវជ្រាវ និងសកម្មភាពជាប់ទាក់ទិននានាដូចខាងក្រោម មានដំណើរការនៅ CDRI ក្នុងរយៈពេលពីខែមករា ដល់ មីនា ២០០៩ ។

**កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនិងកំណែទំរង់សាធារណៈ** កំពុងអនុវត្តការស្រាវជ្រាវ និងសកម្មភាពជាទីប្រឹក្សា ចំនួន ៤ សំខាន់ៗនៅខាងក្នុង និងខាងក្រៅវិទ្យាស្ថាន CDRI ។ គំរោងទី១ ដែលស្តីពីការដឹកនាំនយោបាយនៅតាមមូលដ្ឋាន នឹងបង្ហើយឯកសារពិភាក្សាទី១ នៅដំណាច់ត្រីមាសទី១ ហើយឯកសារសង្ខេបគោលនយោបាយផ្អែកលើការសិក្សានេះក៏នឹងមានបោះពុម្ពផ្សាយដែរ ។ សំរាប់គំរោងទី២ ស្តីពីអភិបាលកិច្ចធនធានទ្រព្យរួម (គំរោងទឹក) ជំពូកជាច្រើននៃឯកសារពិភាក្សាទី១ ដែលតាក់តែងឡើងដោយអ្នកនិពន្ធពីរនាក់ នឹងយកមកដាក់បញ្ចូលគ្នានៅពាក់កណ្តាលខែមីនា ហើយបន្ទាប់មក នឹងចាប់ផ្តើមសរសេរឯកសារពិភាក្សាទី២ ទៀត ។ គំរោងទី៣ ស្តីពីថវិកា នយោបាយ និងការអភិវឌ្ឍន៍មូលដ្ឋាន នឹងចាប់ផ្តើមចងក្រងទិន្នន័យដែលប្រមូលបាន ហើយសរសេរចេញជារបាយការណ៍។ ចំពោះគំរោងទី ៤ ក្រុមទីប្រឹក្សាដែលគេបានចុះកិច្ចសន្យាឱ្យធ្វើការជាមួយក្រុមគោលនយោបាយនៃក្រសួងមហាផ្ទៃ ដើម្បីដឹកនាំ ៩ ក្រសួងជំនាញក្នុងការអនុវត្តកំណែទំរង់វិសហមជ្ឈការ គឺបានបញ្ចប់ពីរដំណាក់កាលដំបូងដ៏សំខាន់ៈ ការធ្វើសិក្ខាសាលាស្តីពីការប្រគល់តួនាទីចាត់តាំង និងការផ្ទេរហិរញ្ញវត្ថុ ។ ក្នុងត្រីមាសនេះ ក្រុមទីប្រឹក្សាកំពុងធ្វើការលើបញ្ហាគណនេយ្យភាព (ដំណាក់កាលទី៣) ព្រមទាំង សិក្ខាសាលាស្តីពីគណនេយ្យភាព ដែលគ្រោងធ្វើនៅថ្ងៃទី ១៩ កុម្ភៈ ២០០៩ និងសិក្ខាសាលាស្តីពីការគ្រប់គ្រងបុគ្គលិក ដែលគ្រោងធ្វើនៅថ្ងៃទី ០៥ មីនា ២០០៩ ។ ដំណាក់កាលទី៤ ដែលផ្តោតលើការកសាងសមត្ថភាព គ្រោងចាប់ផ្តើមនៅដើមខែមេសា ក្រោយពេលបញ្ចប់ដំណាក់កាលទី៣ ។ វិទ្យាស្ថាន CDRI បានជ្រើសរើសអ្នកស្រាវជ្រាវថ្មីម្នាក់ គឺលោក លន់ ពិដេ មកជំនួសលោក គឹម ស៊ានសូមាត្រា ដែលទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅបរទេស ។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់** បានអនុវត្តជឿនលឿនទៅមុខនូវគំរោងសិក្សាអំពី សេដ្ឋកិច្ចនយោបាយនៃមហាអនុតំបន់មេគង្គ ដោយបានបញ្ចប់មួយភាគធំនៃកិច្ចសំភាសន៍ស៊ីជម្រៅជាមួយនឹងមន្ត្រីរដ្ឋាភិបាលសំខាន់ៗ ព្រមទាំងបានចាប់ផ្តើមសរសេររបាយការណ៍ព្រាងលើកដំបូងហើយ ។ ការសិក្សាអំពីជំនួញសេវាកម្ម បានបញ្ចប់ការចុះសិក្សាដល់កន្លែង ហើយរបាយការណ៍ព្រាងលើកដំបូងក៏បានសរសេររួចរាល់ និងបានផ្ញើទៅឱ្យមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ដើម្បីប្រមូលមតិយោបល់ ។ ការសិក្សាអំពីលក្ខណៈប្រកួតប្រជែងនៃផលិតផលកៅស៊ូ កំពុងធ្វើវិភាគ និងសរសេររបាយការណ៍ ទោះបីផែនការចុះសិក្សាដល់កន្លែងបានលុបចោលក្តី ។ ទិន្នន័យអង្កេតការសិក្សាពីឌីណាមិកភាពក្រីក្រ បានធ្វើស្តង់ដានីយកម្ម ទៅជាទិន្នន័យជាក្រុម ហើយបានដាក់ជូនទៅធនាគារពិភពលោករួចហើយ ។ ក្រុមការងារនៃគំរោងបានចាប់ផ្តើមធ្វើវិភាគលើទិន្នន័យជាក្រុម ដែលទទួលបានពី ៦អង្កេតស្តីពីទិដ្ឋភាពផ្សេងៗនៃភាពក្រីក្រ ដូចជាការកំណត់ពីលក្ខណៈញឹកញាប់នៃភាពក្រីក្រ (ក្រីក្រមួយរយៈ និងក្រីក្ររហូត) ព្រមទាំងកត្តានានាដែលបង្កភាពក្រីក្រទាំងពីរ ។ លទ្ធផលនៃការសិក្សាមានសារៈសំខាន់បំផុតសំរាប់ជួយអ្នកកសាងគោលនយោបាយ ក្នុងការកំណត់អាទិភាពយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រដល់តំបន់ផ្សេងៗ ។ ដោយឡែកក្រុមស្រាវជ្រាវសំរាប់គំរោងវិនិយោគទុនចិននៅកម្ពុជា ត្រូវបានរៀបចំឡើងវិញហើយៗរំពឹងថា នឹងអាចអនុវត្តគំរោងបានសំរេចតាមផែនការកែតំរូវថ្មីដែលត្រូវបញ្ចប់នៅខែមីនា ២០០៩ ។

**កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន** បានបញ្ចប់អង្កេតគោលមួយសំរាប់សមាសធាតុសេដ្ឋកិច្ចនៃ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក (WRMRCDP) ។ កម្មវិធីនេះ មានរៀបចំការប្រជុំគណៈកម្មការពិគ្រោះយោបល់ ដើម្បីធានាថា សកម្មភាពស្រាវជ្រាវ និងលទ្ធផលនានាត្រឹមត្រូវតាមសកម្មភាព និងសូចនាករនានាដែលបានលើកឡើងនៅក្នុងឯកសារកម្មវិធី ។ ម្យ៉ាងទៀត នឹងមានបោះពុម្ពផ្សាយឯកសារពិភាក្សាមួយ ស្តីពី វិធីសាស្រ្តស្រាវជ្រាវការគ្រប់គ្រងធនធានទឹក សំរាប់ដោះស្រាយប្រធានបទខាងអភិបាលកិច្ច សេដ្ឋកិច្ច និងធនធានរូបវន្ត នៃ WRMRCDP ។ ការពិនិត្យវាយតំលៃពាក់កណ្តាលអាណត្តិនៃ WRMRCDP នឹងចាប់ផ្តើមនៅខែមីនា ។ កម្មវិធីបានបង្ហើយការបញ្ចូលទិន្នន័យសំរាប់គំរោងរួមគ្នាមួយស្តីពី ព្រៃត្រូពិចសំរាប់កាត់បន្ថយភាពក្រីក្រ ដែលក្នុងនេះមានការវិភាគទិន្នន័យតាំងពីកំរិតគ្រួសារ ដល់កំរិតសាកល ។ ទិន្នន័យមួយឈុតសំរាប់គំរោងនេះ បានដាក់ជូនមជ្ឈមណ្ឌលស្រាវជ្រាវព្រៃអន្តរជាតិ ដើម្បីសំអាត និងអនុម័ត ហើយឯកសារពិភាក្សាមួយស្តីពី គំរោងព្រៃត្រូពិច នឹងត្រូវរៀបចំឡើង ។ គំរោងកសាងសមត្ថភាពសហគមន៍សំរាប់គំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រនៅអាងទន្លេសាប បានបង្ហើយ អង្កេតជាមូលដ្ឋាននៅក្នុងតំបន់ជ្រើសរើសនានានៅជុំវិញបឹងទន្លេសាប ។ សេចក្តីព្រាងរបាយការណ៍ជាមូលដ្ឋានមួយក៏បានរៀបចំឡើង និងដាក់ជូនទៅ ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីពិនិត្យផ្តល់យោបល់ ។ កម្មវិធីបានបន្តការពិភាក្សាជាមួយវិទ្យាស្ថានបរិស្ថានស្តុកខម ស្តីពីមាគ៌ាដ៏មានចីរភាពដើម្បី សំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងការវាយតំលៃបរិស្ថានជាយុទ្ធសាស្រ្តនៃការអភិវឌ្ឍន៍វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ នៅអាងមេគង្គក្រោម ។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងការអភិវឌ្ឍន៍ជនបទ** បានបង្ហើយទិន្នន័យស្តង់ដារពីឆ្នាំ២០០១ ដល់ ២០០៨ សំរាប់ការសិក្សាពីឌីណាមិកភាពក្រីក្រ

(PDS) ហើយទិន្នន័យជាក្រុមបែបបរិមាណ បានដាក់ជូនទៅធនាគារពិភពលោករួចហើយ ។ ការសំអាតទិន្នន័យបែបបរិមាណនៃ PDS ក៏បានបញ្ចប់រួចរាល់ដែរ ហើយឈុតទិន្នន័យនានាដែលសំអាតរួចហើយ បានផ្ញើទៅធនាគារពិភពលោករួចរាល់ ។ លទ្ធផលមួយនៃ PDS គឺអត្ថបទស្រាវជ្រាវស្តីពី "ផលប៉ះពាល់នៃកំណើនថ្លៃម្ហូបអាហារ លើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា" ដែលកំពុងតាក់តែងឡើងសំរាប់ចុះផ្សាយ ក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ។ចំពោះរបាយការណ៍PDSវិញនឹងមានការពិគ្រោះយោបល់ជាមួយជំនាញការខាងភាពក្រីក្រ នៃធនាគារពិភពលោក ។ ក្រុមជំនាញការប្រចាំប្រទេសកម្ពុជារបស់អង្គការយូនីសេហ្វ បានទទួលយករបាយការណ៍ព្រាងចុងក្រោយស្តីពី គំរោងវិភាគស្ថានភាពយុវជន ដែលមានកិច្ចសហការពីកម្មវិធីអភិវឌ្ឍន៍សង្គមនៃ CDRI ហើយលទ្ធផលចុងក្រោយបានផ្សព្វផ្សាយទៅដល់ក្រុមជំនាញការយូនីសេហ្វ និងអ្នកឯទៀតរួចរាល់ ។ លទ្ធផលវិភាគស្ថានភាពយុវជនបានយកមកប្រើប្រាស់ផលិតអត្ថបទស្រាវជ្រាវមួយ មានចំណងជើងថា "*ការវិភាគស្ថានភាពយុវជននៅកម្ពុជា : បញ្ហាប្រឈម ការយល់ដឹង និងឱកាសសំរាប់យុវជន*" ដែលចុះផ្សាយនៅក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជាលេខនេះ ។ ឧបករណ៍ស្រាវជ្រាវក៏បានកែលំអឡើងសំរាប់ប្រើក្នុងគំរោងបង្កើនប្រសិទ្ធភាពប្រព័ន្ធផ្តល់សេវាកម្មផលិតកម្មនៅជនបទ និងការចុះអង្កេតប្រមូលទិន្នន័យដល់កន្លែង ហើយការសំភាសន៍ពាក់កណ្តាលរៀបរយជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ និងការពិភាក្សាតាមក្រុមគោលដៅជាមួយកសិករ បានចប់រួចរាល់ ក្នុងនោះ របាយការណ៍ព្រាងដំបូងស្តីពី ៦ករណីសិក្សា កំពុងតែសរសេរ ។

**កម្មវិធីអភិវឌ្ឍន៍សង្គម** បានបង្ហើយការសិក្សាស្តីពីភាពក្រីក្រ និងស្ថានភាពខុសគ្នានៃកុមារនៅកម្ពុជា និងការវិភាគស្ថានភាពយុវជន ហើយកំពុងធ្វើការស្រាវជ្រាវអំពី ការបង្កើនប្រសិទ្ធភាពប្រព័ន្ធផ្តល់សេវាកម្មផលិតកម្មនៅជនបទកម្ពុជា ដែលផ្តល់ទុនដោយអង្គការអភិវឌ្ឍន៍កសិកម្ម និងម្ហូបអាហារអន្តរជាតិ (IFAD) ។ គំរោងពីរខាងក្រោយនេះ ជាកិច្ចសហការជាមួយកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃ CDRI ។ ផ្នែកបណ្តុះបណ្តាលដែលស្ថិតនៅក្នុងកម្មវិធីអភិវឌ្ឍន៍សង្គម បានដំណើរការ:

- វគ្គ "ការកសាងសន្តិភាព" នៅ CDRI សំរាប់បណ្តុះបណ្តាលអ្នកអនុវត្តជាក់ស្តែងមកពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងជំនាញការគ្រប់គ្រង ដោះស្រាយទំនាស់ និងសំរាប់បណ្តុះបណ្តាលអ្នកបណ្តុះបណ្តាលជំនាញកសាងសន្តិភាព ។
- វគ្គ "ធ្វើការរួមគ្នាដើម្បីសន្តិភាព និងអភិវឌ្ឍន៍" នៅស្រុកបានលុង និងស្រុកអូរជុំ ខេត្តរតនគិរី សំរាប់បណ្តុះបណ្តាលមន្ត្រីឃុំ និងស្រុក និងអ្នកដឹកនាំសហគមន៍
- វគ្គ "តួនាទីសារព័ត៌មាន ដើម្បីកសាងសន្តិភាព" នៅ CDRI សំរាប់បណ្តុះបណ្តាលសមាជិកសមាគមសារព័ត៌មាន និងអ្នកយកព័ត៌មាននានា ។

កម្មវិធីនេះក៏បានបញ្ចប់ យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល) ដែលបានបង្កើតឡើងដើម្បីផ្តល់វេទិកាអព្យាក្រឹត្យ និងបើកចំហសំរាប់ពិភាក្សាបញ្ហាជាប់ទាក់ទិននឹងការបោះឆ្នោត ការបង្កាទំនាស់អំពើហិង្សា និងការខ្វែងគំនិតលើការងារបោះឆ្នោត ។

## Cambodia Development Review—2009 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដោយរួមសហការជាដៃគូជាមួយ ធនាគារអេអិនហ្សេតរ៉ូយ៉ាល់ (ANZ Royal Bank) នឹងរៀបចំធ្វើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៩ នៅភ្នំពេញ នាថ្ងៃទី១២ មីនា ឆ្នាំ២០០៩ ក្រោមប្រធានបទ "ប្រទេសកម្ពុជា និងវិបត្តិសាកល: ផលប៉ះពាល់ ចម្លើយជាគោលនយោបាយ និងសកម្មភាព" ។ សំរាប់សន្និសីទប្រចាំឆ្នាំលើកទី៣នេះ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នឹងថ្លែងសុន្ទរកថាគន្លឹះបើក ព្រមទាំងផ្ដល់មតិសំណេះសំណាលជាមួយអ្នកចូលរួមជាថ្នាក់ដឹកនាំប្រហែល ៣០០នាក់ មកពីខាងរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍អន្តរជាតិ សហគមន៍ស្រាវជ្រាវ និងសង្គមស៊ីវិល ។ វគ្គនានានៃសន្និសីទ នឹងផ្ដោតលើផលប៉ះពាល់ពីសាកលលោក តំបន់ និងប្រទេសជាតិយើង ទៅលើកំណើន ការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ សន្និសីទនឹងផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើបញ្ហាគន្លឹះសំរាប់កម្ពុជា ដូចជា ការអភិវឌ្ឍន៍ធនធានមនុស្ស ការអភិវឌ្ឍន៍ជនបទនិងកសិកម្ម ទេសចរណ៍ ការពង្រីកវិស័យកម្មន្តសាល អចលនទ្រព្យ និងសំណង់ ហេដ្ឋារចនាសម្ព័ន្ធនិងថាមពល និងអាជីវកម្មជីកយករ៉ែ ។ ព្រមពេលគ្នាជាមួយសន្និសីទនេះដែរ នឹងមានចេញផ្សាយរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៨-០៩របស់CDRI ។ដោយឡែកទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជាក្នុងលេខចេញផ្សាយសំរាប់ខែមេសា-មិថុនា ២០០៩ នឹងចុះផ្សាយបទបង្ហាញ និងប្រធានបទមួយចំនួនដែលជ្រើសរើសចេញពីសន្និសីទចក្ខុវិស័យ ហើយឯកសារសន្និសីទទាំងអស់ នឹងមានចុះនៅក្នុងវេបសាយរបស់ CDRI ។

មួយថ្ងៃក្រោយសន្និសីទចក្ខុវិស័យឆ្នាំ២០០៩ វិទ្យាស្ថានក៏នឹងធ្វើការប្រជុំក្រុមប្រឹក្សាភិបាល CDRI ប្រចាំឆ្នាំ២០០៩ដែរ ហើយនេះជាការប្រជុំលើកទី១ របស់កញ្ញា អ៊ូច ច័ន្ទតារានី ដែលទើបជាប់ឆ្នោតជាតំណាងបុគ្គលិកថ្មីរបស់CDRI ។ កញ្ញា អ៊ូច ច័ន្ទតារានី ទើបបានបញ្ចប់ដោយជោគជ័យនូវការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ នៅឯសាលាគោលនយោបាយសាធារណៈលីក្វានយូ នៅប្រទេសសិង្ហបុរី ។ ក្រុមប្រឹក្សាភិបាលនឹងពិភាក្សាលើអាទិភាពនានាសំរាប់ឆ្នាំ២០០៩-១០ ដែលបានកំណត់ឡើងក្នុងការពិនិត្យវាយតំលៃពាក់កណ្ដាលអាណត្តិ ដែលទើបបញ្ចប់នាពេលថ្មីៗលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-១០ ។ អាទិភាពទាំងនេះរួមមាន កំណែលំអការគ្រប់គ្រង និងគុណភាពការស្រាវជ្រាវ ការផលិតឯកសារស្រាវជ្រាវខាងគោលនយោបាយជាភាសាខ្មែរ និងអង់គ្លេស ឱ្យបានច្រើនថែមទៀត ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកជាប្រព័ន្ធ និងការកំណត់ដំណើរការមួយក្នុងឆ្នាំ២០០៩-១០ ដើម្បីកសាងយុទ្ធសាស្ត្រស្រាវជ្រាវរបស់ CDRI សំរាប់ប្រទេសកម្ពុជារហូតដល់ឆ្នាំ២០២០ ។ យុទ្ធសាស្ត្រស្រាវជ្រាវថ្មីនេះ បង្ហាញពីតំរូវការអភិវឌ្ឍន៍ជាអាទិភាពរបស់ប្រទេសកម្ពុជា និងបញ្ហាផ្សេងៗ ហើយត្រូវក្លាយជាមូលដ្ឋាននៃផែនការយុទ្ធសាស្ត្របន្ទាប់ទៀតរបស់ CDRI ព្រមទាំងសំរាប់ប្រើប្រាស់ដើម្បីស្វែងរកមូលនិធិដែលមានលក្ខណៈផ្អែកលើកម្មវិធី អំពីដៃគូអភិវឌ្ឍន៍នានារបស់កម្ពុជា ។

ក្រុមប្រឹក្សាភិបាលនៃ CDRI ក៏នឹងពិនិត្យពិចារណាលើលទ្ធផល និងអនុសាសន៍នានា នៃការពិនិត្យវាយតំលៃពាក់កណ្ដាលអាណត្តិលើជំនួយឧបត្ថម្ភរបស់ Sida-DFID សំរាប់ចំណាយលើប្រតិបត្តិការស្នូលរបស់ CDRI និងកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនិងកំណែទំរង់សាធារណៈ ដែលមានដំណាក់កាលអនុវត្តរហូតដល់ឆ្នាំ២០១០ ។ការពិនិត្យវាយតំលៃនេះបានធ្វើឡើងនៅខែមករា ២០០៩ ដោយទីប្រឹក្សាឯករាជ្យ ដែលមានការ

(តទៅទំព័រ ២២)

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៣ លេខ១ ខែមករា_មីនា ឆ្នាំ២០០៩

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខា ប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdrimail@online.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: គឹម ចិត្រា និង អ៊ុំ ចាន់ថា
ជំនួយការកែសំរួល: ខេង សេង
រោងពុម្ពដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០០៨ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។
ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្ដល់ឱ្យដោយឥតគិតថ្លៃតាមរយៈវេបសាយ: http://www.cdri.org.kh